# បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ
# ក្នុងស្រះ ក្នុងស្រែ
# និងក្នុងស្រះក្រាលកៅស៊ូប្លាស្ទិក



នាយកដ្ឋានអភិវឌ្ឍវារីវប្បកម្ម រដ្ឋបាលជលផល

ខែ មករា ឆ្នាំ ២០១៥


ប្រភពធនធានចម្រុះសម្រាប់ចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ
លាមកសត្វ
ត្រី ស្រូវ

# បច្ចេកទេស ចិញ្ចឹមត្រី ក្នុងស្រះ ក្នុងស្រែ និង ក្នុងស្រះក្រាលកៅស៊ូប្លាស្ទិក ជាលក្ខណៈគ្រួសារ

រៀបចំដោយនាយកដ្ឋានអភិវឌ្ឍវារីវប្បកម្មនៃរដ្ឋបាលជលផល

ខែ មករា ឆ្នាំ២០១៥


ម.ភ.ឯ.ក AIDOC
Code: 147-027
Date:
Donated by:


ផលិតដោយ ៖

គម្រោងបង្កើនផលិតភាព និងផ្សព្វផ្សាយវារីវប្បកម្មទឹកសាប ដំណាក់កាលទី២ ( FAIEX 2 )


រក្សាសិទ្ធិគ្រប់យ៉ាងដោយ រដ្ឋបាលជលផល នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ

១២. របៀបដាក់ជី ក្រោយពេលលែងកូនត្រីក្នុងស្រែ.....៤៥
១៣. ការគ្រប់គ្រងស្រែចិញ្ចឹមត្រី.....៤៦
១៤. កត្តាសំខាន់ៗមួយចំនួនដែលត្រូវយកចិត្តទុកដាក់.....៤៧
ផ្នែកទី៣៖ បច្ចេកទេសចិញ្ចឹមត្រីអណ្តែងដាលក្នុងលក្ខណៈគ្រួសារក្នុងស្រះក្រាលកៅស៊ូប្លាស្ទិក
១.ការជ្រើសរើសទីតាំងជីកស្រះ.....៤៩
២. លក្ខណៈស្រះចិញ្ចឹមត្រី.....៥០
៣. របៀបជីកស្រះចិញ្ចឹមត្រី.....៥១
៤. ការរៀបចំស្រះមុនពេលដាក់កូនត្រីចិញ្ចឹម.....៥២
៥. ការលែងកូនត្រីចិញ្ចឹមចូលស្រះ.....៥៤
៦. កម្រិតដង់ស៊ីតេ ឬចំនួនកូនត្រីដាក់ចិញ្ចឹម.....៥៥
៧. ប្រភេទចំណី និងការផ្តល់ចំណី.....៥៦
៨. ការតាមដាន និងគ្រប់គ្រងស្រះចិញ្ចឹមត្រី.....៥៨
៩. វិធីការពារជំងឺ.....៥៩
១០. ការប្រមូលផល.....៦០
១១. ការកត់ត្រាទិន្នន័យ.....៦១
ឯកសារយោង.....៦៣
ផ្នែកទី៤ ៖ ការកត់ត្រាទិន្នន័យ និងវិភាគព័ត៌មាន
- តារាងប្រមូលទិន្នន័យប្រចាំខែ.....៦៥

# អារម្ភកថា

ជាច្រើនជំនាន់មកហើយប្រទេសកម្ពុជាជាសង្គមមួយនិយមបរិភោគត្រីដែលជារបបអាហារប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ជាពិសេសប្រជាកសិករតម្រូវការចាំបាច់ដែលមិនអាចខ្វះបានក្នុងជីវភាពរស់នៅរបស់គាត់ដោយហូបទាំងត្រីស្រស់និងផលិតផលកែច្នៃដូចជា ប្រហុក ផ្អក ទឹកត្រី ត្រីងៀត ត្រីឆ្អើរជាដើម ។ល។ ជាពិសេសប្រហុកដែលជាគ្រឿងផ្សំយ៉ាងសំខាន់របស់ម្ហូបខ្មែរ ដូចជាជនជាតិអឺរ៉ុបចូលចិត្តហូបប៊ឺរ ដូចជាប្រជាជនខ្មែរចូលចិត្តហូបប្រហុកដូចគ្នាដែរ។ យ៉ាងហោចណាស់ក៏ប្រជាជនខ្មែរត្រូវការទឹកត្រីសម្រាប់មកធ្វើជាម្ហូបប្រចាំថ្ងៃដែរ ។ តាមការសិក្សារបស់គណៈកម្មការជាតិទន្លេមេគ្គងបានរកឃើញថា បច្ចុប្បន្នប្រជាជនម្នាក់ហូបត្រីប្រមាណ ៥២.៤ គ.ក្រ ក្នុង១ឆ្នាំ ដូចនេះរៀងរាល់ឆ្នាំប្រជាជនកម្ពុជាត្រូវការបរិភោគសាច់ត្រីកាន់តែច្រើនឡើងៗ(តាមកំណើនស្ថិតិប្រជាជន។)ប្រទេសកម្ពុជាសម្បូរធនធានធម្មជាតិដែលមាននៅក្នុងទន្លេ ស្ទឹង បឹងបួរ ព្រែក អូរ ប្រឡាយនានា។ ប៉ុន្តែមកដល់បច្ចុប្បន្ននេះដោយសារមានការប្រែប្រួលបរិស្ថានធម្មជាតិ និងកំណើនប្រជាជនបានធ្វើឲ្យតម្រូវការត្រីកាន់តែកើនឡើងជាលំដាប់ ហើយបរិមាណផលត្រីក្នុងធម្មជាតិមិនអាចផ្គត់ផ្គង់បានតាមតម្រូវការ។

ដើម្បីដោះស្រាយបាននូវបញ្ហាតម្រូវការចាំបាច់នេះ មានតែយកចិត្តទុកដាក់អភិវឌ្ឍសកម្មភាពវារីវប្បកម្មទេ ដែលបាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយការខ្វះខាតសាច់ត្រីទទួលទាន និងការចាប់ត្រីពីធម្មជាតិ ព្រមទាំងអាចជួយរក្សាបាននូវប្រភេទត្រីក្នុងស្រុកមួយចំនួនដែលកំពុងឈានទៅរកការដាច់ពូជផងដែរ។ មូលហេតុនេះហើយ បានជាធ្វើឲ្យរដ្ឋបាលជលផលបានកំណត់ទិសដៅ និងយកចិត្តទុកដាក់សម្រេចយកការអភិវឌ្ឍ និងផ្សព្វផ្សាយសកម្មភាពវារីវប្បកម្មជាកត្តាចម្បង ហើយជាជំហានដំបូងត្រូវចាប់ផ្តើមអនុវត្តនៅតាមតំបន់ដែលមានសក្តានុពលក្នុងការអភិវឌ្ឍ ជាពិសេសតំបន់ដែលនៅឆ្ងាយពីដែនឡូត៍នេសាទ ដើម្បីដោះស្រាយបាននូវការខ្វះខាតសាច់ត្រីទទួលទានរបស់ប្រជាកសិករ។ ទាំងនេះស្របទៅតាមប្រសាសន៍របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទដែលបានថ្លែងកន្លងមកថា ដើម្បីជម្រុញកិច្ចអភិវឌ្ឍការងារវារីវប្បកម្មពិសេសនៅតាមជនបទ រដ្ឋបាលជលផលត្រូវបន្តការខិតខំផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រីឲ្យបានគ្រប់ទីកន្លែង និងបង្កើតកសិដ្ឋានផលិតកូនត្រីឲ្យបានច្រើនកន្លែងនៅតាម ឃុំ ស្រុក ដើម្បីបង្កលក្ខណៈងាយស្រួលឲ្យកសិកររកទិញកូនត្រីមកចិញ្ចឹមទៀតផង។

ដើម្បីជម្រុញកិច្ចអភិវឌ្ឍវារីវប្បកម្មឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត រដ្ឋបាលជលផលបានរៀបចំចងក្រងសៀវភៅ **បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ** នេះឡើង ដោយផ្អែកតាមបទពិសោធន៍ដែលបានអនុវត្តកន្លងមក ដើម្បីផ្សព្វផ្សាយបន្តដល់ភ្នាក់ងារផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្ម និងកសិករដទៃទៀតយកទៅអនុវត្តទទួលបានជោគជ័យ។

## សេចក្ដីផ្ដើម

ប្រទេសកម្ពុជាសម្បូរធនធានជលផលដែលមាននៅក្នុង ទន្លេ ស្ទឹង បឹងបួរ ព្រែក អូរ ប្រឡាយនានា។ ប៉ុន្តែមកដល់បច្ចុប្បន្ននេះ ដោយសារមានការប្រែប្រួលបរិស្ថានធម្មជាតិ និងកំណើនប្រជាជនបានធ្វើឲ្យតម្រូវការត្រីកាន់តែកើនឡើងជាលំដាប់ ហើយបរិមាណផលត្រីក្នុងធម្មជាតិមិនអាចផ្គត់ផ្គង់បានតាមតម្រូវការឡើយ។

ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននឹងកំពុងយកចិត្តទុកដាក់ផ្សព្វផ្សាយដល់ប្រជាកសិករនូវវិធីសាស្ត្រគ្រប់គ្រងធនធានជលផលឲ្យមានប្រសិទ្ធភាពនៅតាមតំបន់ដែនទឹកធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ដោយជួយរៀបចំបង្កើតឲ្យមានសហគមន៍គ្រប់គ្រងធនធានជលផលនៅតាមមូលដ្ឋាន ដើម្បីឲ្យប្រជាកសិករយល់ច្បាស់ពីតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងការគ្រប់គ្រងធនធានជលផលក្នុងតំបន់របស់ខ្លួន។

ក្រៅពីនេះ រដ្ឋបាលជលផលបាននឹងកំពុងអនុវត្តការងារផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រី ដោយសហការជាមួយអង្គការជាតិ និងអន្តរជាតិនានា ក្នុងគោលបំណងដើម្បីធានាការផ្គត់ផ្គង់សាច់ត្រីទៅគ្រប់តំបន់ដែលប្រជាកសិករកំពុងទទួលការខ្វះខាតសាច់ត្រីទទួលទាន។ បច្ចុប្បន្នមានប្រជាកសិករជាច្រើនគ្រួសារបានទទួលការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រីពីមន្ត្រីជំនាញនៃរដ្ឋបាលជលផលសហការជាមួយបណ្តាអង្គការនានា និងដោយមានការចូលរួមពីកសិករផង ទាំងនេះបានធ្វើឲ្យពួកគាត់កំពុងមានសកម្មភាពចិញ្ចឹមត្រីកាន់តែច្រើនឡើងៗពីមួយឆ្នាំ ទៅមួយឆ្នាំ។ ម្យ៉ាងទៀត ដើម្បីដោះស្រាយបានការផ្គត់ផ្គង់កូនត្រីពូជដល់ប្រជាកសិករនៅតាមមូលដ្ឋាន រដ្ឋបាលជលផលក៏បាននឹងកំពុងយកចិត្តទុកដាក់ផ្សព្វផ្សាយបច្ចេកទេសផលិតកូនត្រីពូជ ឲ្យមានតាមភូមិ ឃុំ ងាយស្រួលកសិករទំនាក់ទំនងរកជាវកូនត្រីពូជមកដាក់ចិញ្ចឹមបាន។

ដើម្បីពង្រីកការងារផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រីនេះ ឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀតនោះ រដ្ឋបាលជលផលបានរៀបចំសៀវភៅ(**បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ ក្នុងស្រះ ក្នុងស្រែ និងស្រះក្រាលកៅស៊ូប្លាស្ទិក**) នេះឡើងសំដៅជួយប្រជាកសិករនៅគ្រប់ទីកន្លែងឲ្យចេះបច្ចេកទេសចិញ្ចឹមត្រី និងចូលរួមសកម្មភាពចិញ្ចឹមត្រីឲ្យបានផុសផុលទាំងអស់គ្នា ដើម្បីដោះស្រាយម្ហូបអាហារប្រចាំថ្ងៃ បង្កើនប្រាក់ចំណូលក្នុងគ្រួសារ និងកាត់បន្ថយការចាប់ត្រីពីធម្មជាតិផង។





# ជំពូកទី១

# បច្ចេកទេសចិញ្ចឹមត្រីក្នុងស្រះជាលក្ខណៈគ្រួសារ





## ១- ការជ្រើសរើសទីតាំងជីកស្រះ

### គោលបំណង៖

- ជ្រើសរើសទីតាំងជីកស្រះចិញ្ចឹមត្រីបានត្រឹមត្រូវតាមបច្ចេកទេស ដើម្បីចិញ្ចឹមត្រីទទួលបានជោគជ័យ។
- និងបង្កលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រងស្រះចិញ្ចឹមត្រី។



### តើយើងត្រូវជ្រើសរើសទីតាំងជីកស្រះចិញ្ចឹមត្រីយ៉ាងដូចម្តេច?

ស្រះគួរជីក:

- នៅជិតផ្ទះងាយស្រួលគ្រប់គ្រង
- ស្រះគួរជីកនៅកន្លែងទំនាប ប៉ុន្តែមិនលិចទឹកនៅរដូវវស្សា(ឬលិចតិចតួចតែអាចលើកភ្លឺទប់បាន)។
- ស្ថិតនៅទីវាលស្រឡះ គ្មានដើមឈើព័ទ្ធជុំវិញ និងដីគ្មានជាតិអាស៊ីត។
- ដីមិនជ្រាបទឹកឬមានកម្រិតជ្រាបតិចតួច
- ជិតប្រភពទឹក ប្រសិនបើមាន
- ស្រះជាប់ស្រែកាន់តែប្រសើរ
- នៅឆ្ងាយពីតំបន់ ដែលមានការប្រើប្រាស់ថ្នាំពុលកសិកម្មផ្សេងៗ។





ពុំគួរជីកស្រះមានដើមឈើធំៗព័ទ្ធជុំវិញ



ពុំគួរជីកស្រះក្នុងតំបន់ប្រើប្រាស់ថ្នាំពុលកសិកម្ម



## ២- លក្ខណៈស្រះចិញ្ចឹមត្រី

### គោលបំណង៖

ដើម្បីយល់ច្បាស់ពី

- ទ្រង់ទ្រាយ ឬរូបរាង និងទំហំស្រះដែលអាចចិញ្ចឹមត្រីបាន។
- លក្ខណៈបច្ចេកទេសនៃស្រះចិញ្ចឹមត្រី។
- ការរៀបចំស្រះចិញ្ចឹមត្រីឲ្យបានត្រឹមត្រូវតាមបច្ចេកទេស ដើម្បីអនុវត្តទទួលបានជោគជ័យ។

ស្រះចិញ្ចឹមត្រីគួរ

- ជីកមានរាងបួនជ្រុងទ្រវែង ដើម្បីងាយស្រួលគ្រប់គ្រង។
- ស្រះគួរមានទំហំពី ១០០ម៉ែត្រការឡើងទៅ សមស្របដល់ការចិញ្ចឹមត្រីបានធំធាត់ល្អ។
- ស្រះមានជម្រៅសមស្របពី ១.៥ម៉ែត្រ ទៅ ២.៥ម៉ែត្រ អាស្រ័យទំហំស្រះដែលត្រូវជីក។
- ស្រះត្រូវមានភ្លឺខ្ពស់ និងមាំល្អ ដើម្បីការពារទឹកលិច។



គំរូស្រះចិញ្ចឹមត្រី

- ស្រះត្រូវមានចំណោតភ្លឺស្រះ ដើម្បីការពារភ្លឺស្រះហូរច្រោះបាក់ដី។
- ស្រះចិញ្ចឹមត្រីគួរមានទំហំ និងលក្ខណៈដូចក្នុងតារាងខាងក្រោម :

| លរ | ក្រឡាផ្ទៃស្រះ (ម៉ែត្រការេ) | បណ្ដោយស្រះ (ម៉ែត្រ) | ទទឹងស្រះ (ម៉ែត្រ) | ជម្រៅស្រះ (ម៉ែត្រ) | ចំណោតភ្លឺស្រះ (ម៉ែត្រ) | ទទឹងភ្លឺស្រះ (ម៉ែត្រ) |
|---|---|---|---|---|---|---|
| ១ | ៣០០ | ២០ | ១៥ | ២.៥ | ១ | ១ |
| ២ | ២៤០ | ២០ | ១២ | ២.៥ | ១ | ១ |
| ៣ | ២០០ | ២០ | ១០ | ២.៥ | ១ | ១ |
| ៤ | ១៥០ | ១៥ | ១០ | ២ | ០.៥ | ១ |
| ៥ | ១២០ | ១២ | ១០ | ១.៥ | ០.៥ | ១ |

- ក្នុងករណីស្រះ២ជីកជាប់គ្នា ទទឹងភ្លឺស្រះត្រូវរៀបអោយបាន២ម៉ែត្រ ដើម្បីចៀសវាងភ្លឺស្រះបាក់ដី ដែលនាំអោយស្រះពីរលាយចូលគ្នា ។

- ស្រះត្រូវមានជើងទេរ(ជម្រាល)សមស្រប ដើម្បីការពារការហូរច្រោះ ឬបាក់ដី។
- បាតស្រះត្រូវរាបស្មើ ហើយមានជម្រាលទៅជ្រុងម្ខាង ដើម្បីងាយស្រួលពង្រីងទឹក និងប្រមូលផលត្រី។
- ស្រះត្រូវដាំស្មៅនៅលើភ្លឺស្រះ និងដាំនៅលើជើងទេរភ្លឺស្រះ ដើម្បីការពារការហូរច្រោះ បាក់ដីនៅពេលមានភ្លៀងធ្លាក់។
- នៅតាមភ្លឺស្រះគួរបង្កប់បំពង់ សម្រាប់បង្ហូរទឹកចូលស្រះ។
- ស្រះគួរធ្វើរបងព័ទ្ធជុំវិញ ដើម្បីការពារសត្វគោ ក្របី ជ្រូក ចុះទឹកស្រះនាំឲ្យខូចភ្លឺស្រះ និងល្អក់ទឹកស្រះ។ ម្យ៉ាងទៀត ការពារកុំឲ្យក្មេងទៅលេងក្បែរស្រះទឹក ដែលអាចនាំឲ្យលង់ទឹកស្រះបាន។
- ក្រៅពីនេះ ត្រូវរៀបចំរណ្ដៅជីលាមកសត្វឲ្យនៅជាប់នឹងភ្លឺស្រះ ដើម្បីងាយស្រួលបង្ហូរទឹកជីចូលក្នុងស្រះចិញ្ចឹមត្រី។ រណ្ដៅជីគួរជីកដីទំហំបណ្ដោយប្រវែង ២ម៉ែត្រ ទទឹងប្រវែង ១ម៉ែត្រ ជម្រៅ ១ម៉ែត្រ សម្អាតបាតរណ្ដៅ ជីរួចក្រាលកម្រាលកៅស៊ូប្លាស្ទិក ដើម្បីការពារទឹកជីលាមកសត្វជ្រាបចូលក្នុងដី។ យើងអាចប្រើពាងទឹកធ្វើជារណ្ដៅជីត្រាំជីលាមកសត្វក៏បាន ឬប្រើកង់អណ្ដូងរៀបធ្វើជារណ្ដៅជីក៏បាន។



*គំរូស្រះចិញ្ចឹមត្រី*

## ៣- របៀបជីកស្រះចិញ្ចឹមត្រី

### គោលបំណងៈ

*ដើម្បីយល់ច្បាស់ពី*

- បច្ចេកទេសជីកស្រះចិញ្ចឹមត្រីតាមលំដាប់លំដោយ។
- ការរៀបចំស្រះចិញ្ចឹមត្រីត្រឹមត្រូវតាមលក្ខណៈ(បច្ចេកទេស)ដើម្បីចិញ្ចឹមត្រីទទួលបានជោគជ័យ។

**ឧទាហរណ៍ៈ** យើងត្រូវជីកស្រះមានរាងជាចតុកោណកែងដែលមានបណ្ដោយ ១៥.ម៉ែត្រ ទទឹង ១០ម៉ែត្រ និងជម្រៅ ២ម៉ែត្រ ដូចនេះផ្ទៃក្រឡាស្រះមានទំហំ=បណ្ដោយ ១៥ម៉ែត្រ X ទទឹង ១០ម៉ែត្រ=១៥០ម៉ែត្រការេ។

- ដំបូងយើងត្រូវវាស់ទំហំបណ្ដោយ និងទទឹងស្រះដែលត្រូវជីកដោយបោះបង្គោលនៅជ្រុងទាំង៤នៃស្រះ រួចចងខ្សែព័ទ្ធជុំវិញ។
- បន្ទាប់មកយើងត្រូវកំណត់រកផ្ទៃបាតស្រះដែលត្រូវជីកតាមរូបមន្តដូចខាងក្រោមៈ
- Sb= ( L- LS ) X ( W- LS )

Sb = ផ្ទៃបាតស្រះ

( L- LS ) = ប្រវែងបណ្ដោយបាតស្រះ

( W- LS ) = ប្រវែងទទឹងបាតស្រះ



L- ប្រវែងបណ្ដោយស្រះ

LS- ប្រវែងគម្លាតជើងទេរស្រះ

W- ប្រវែងទទឹងស្រះ

- ជាទូទៅ ជើងទេរស្រះត្រូវឲ្យមានជម្រាល 1: 1.5 ។
- រួចបោះបង្គោលនៅជ្រុងទាំង៤ នៃបាតស្រះដោយចងខ្សែព័ទ្ធជុំវិញ។
- បន្ទាប់មកត្រូវចាប់ផ្ដើមជីកស្រះឲ្យមានជម្រាល 1: 1.5 ជាគំរូចាប់ពីគែមមាត់ស្រះចុះក្រោមរហូតដល់ចំណុចគែមបាតស្រះ និងឲ្យបានជម្រៅស្រះ ២ម៉ែត្រ។ រួចយកខ្សែទាញវាស់ជម្រាលជើងទេរ ក្នុងករណីជើងទេរស្រះរាបស្មើល្អ យើងចាប់ផ្ដើមជីកស្រះដែលមានជើងទេរស្រះគំរូនេះបន្តរហូតដល់ចប់។
- យើងអាចជីកស្រះ ដោយកំណត់យកជើងទេរគំរូជារាងកាំជណ្ដើរដូចក្នុងរូបភាពខាងក្រោម។
- ជាទូទៅ អាចម៍ដីដែលជីកបាននៅស្រទាប់លើជាប្រភេទដីមានជីវជាតិល្អ ដូចនេះត្រូវប្រមូលអាចម៍ដីនេះ ទុកសម្រាប់ដាក់នៅលើភ្លឺស្រះសម្រាប់ដាំស្មៅ ការពារការហូរច្រោះបាក់ភ្លឺ និងជើងទេរស្រះ នៅពេលមានភ្លៀងធ្លាក់។




- គួរជីកស្រះដោយទុកចំណីភ្លឺពី ០.៧ម៉ែត្រ ទៅ ១ម៉ែត្រ ឬតាមស្ថានភាពដីជាក់ស្ដែង។
- លើកភ្លឺព័ទ្ធជុំវិញស្រះ រួចដាំស្មៅដើម្បីកាត់បន្ថយការហូរច្រោះដែលធ្វើឲ្យទឹកល្អក់។



*ត្រូវបុកបង្ហាប់ភ្លឺ និងជើងទេរស្រះ*



*ត្រូវដាំស្មៅពីលើភ្លឺស្រះ*



*គំរូស្រះចិញ្ចឹមត្រី*



បច្ចេកទេសជីកស្រះរាងជាកាំជណ្ដើរ



ស្រះចិញ្ចឹមត្រីជីកមិនបានត្រឹមត្រូវ

## ៤- ការរៀបចំស្រះមុនពេលដាក់ត្រីចិញ្ចឹម

**គោលបំណង៖**

១. កម្ចាត់ត្រីកាច និងសត្វកាចដទៃទៀតដូចជា កង្កែប អន្ទង់ ពស់ ក្ដាម កុំឲ្យស៊ីកូនត្រី ក្រោយពេលដាក់កូនត្រីពូជចិញ្ចឹមក្នុងស្រះ។

២. សម្លាប់មេរោគដែលមាននៅក្នុងស្រះចិញ្ចឹមត្រី

៣. បង្កើនសារធាតុចិញ្ចឹមក្នុងស្រះត្រី

៤. និងការពារត្រីកាច និងសត្វកាចដទៃទៀតដូចជា កង្កែប អន្ទង់ ពស់ ក្ដាម កុំឲ្យចូលស្រះស៊ីកូនត្រី ក្រោយពេលរៀបចំស្រះបានល្អហើយ។

### ក. ចំពោះស្រះចាស់

បូមពង្រីងចាប់ត្រីកាចសម្អាតស្រះ និងស្ដារភក់បាតស្រះ (ទុកជម្រៅ ១៥ស.ម ឬ១តឹកកន្លះ) បាចកំបោរ





បាចកំបោរពី (៥-១០គ.ក្រ/១០០ម² ផ្ទៃស្រះ)



ដាក់ជីធម្មជាតិក្រាលបាតស្រះ



រូបបញ្ចូលទឹកក្នុងស្រះដោយប្រើតម្រង



១អាទិត្យក្រោយទឹកស្រះមានពណ៌បៃតងសម្បូរ ចំណីធម្មជាតិ ( សត្វ និងរុក្ខជាតិប្លង់តុង )

## ខ. ចំពោះស្រះថ្មី



បាចកំបោរពី១០-១៥គ.ក្រ/១០០ម² ផ្ទៃស្រះ



រូបបញ្ចូលទឹកទៅក្នុងស្រះឲ្យបាន ១ភាគ៣នៃ ជម្រៅស្រះ



ការប្រើប្រាស់កំបោរមានសារៈប្រយោជន៍ដូចខាងក្រោម:

- ជួយកែលំអគុណភាពទឹក និងគុណភាពដី ស្រះដែលមានជាតិអាស៊ីត។
- សម្លាប់ពពួកសត្វមួយចំនួនក្នុងស្រះដែលស៊ីត្រី
- កាត់បន្ថយភាពល្អក់នៃទឹកស្រះ

ដាក់ជីលាមកសត្វ ក្នុងបរិមាណដូចខាងក្រោម:

- ជីលាមកគោ-ក្របី ៦០-៨០ គ.ក្រ/១០០ម²
- ឬជីលាមកជ្រូកសើម ២០-៣០គ.ក្រ/១០០ម²
- ឬជីលាមកមាន់ ទាសើម ១០-១៥ គ.ក្រ /១០០ម² ផ្ទៃស្រះ ។
- ឬជីបៃតង ( ទន្ទ្រានខែត្រ... )២០-៣០ គ.ក្រ /១០០ម²។

## ៥- របៀបពិនិត្យចំណីធម្មជាតិក្នុងស្រះ

### គោលបំណង៖

ដើម្បីបញ្ជាក់ច្បាស់ពី

- ក្នុងស្រះមានចំណីធម្មជាតិ ជាពិសេសសត្វល្អិតប្លង់តុង មុនពេលដាក់កូនត្រីចិញ្ចឹម។
- វិធីងាយៗក្នុងការពិនិត្យចំណីធម្មជាតិក្នុងស្រះ ជាពិសេសសត្វល្អិតប្លង់តុង។

ខាងក្រោមនេះ ជារូបភាពបង្ហាញពីរបៀបងាយៗក្នុងការពិនិត្យចំណីធម្មជាតិក្នុងស្រះ (ពិសេសសត្វល្អិតប្លង់តុង) ក្រោយពេលប្រើប្រាស់ជីដាក់ក្នុងស្រះហើយ



ប្រើក្រមាជួសទឹកគែមច្រាំងស្រះ



រូបភាពសត្វល្អិតប្លង់តុងក្នុងកែវ



ឬប្រើថ្នាងជួសទឹកគែមច្រាំងស្រះ



រូបភាពសត្វល្អិតប្លង់តុងក្នុងកែវ

- ចំណីធម្មជាតិរួមមាន សត្វល្អិតប្លង់តុង រុក្ខជាតិប្លង់តុង និងសត្វស្រទាប់បាតដូចជា ខ្យង ខ្ចៅ ជន្លេន ដែលកើតមានក្រោយពីការដាក់ជី។
- ក្នុងករណីចំណីធម្មជាតិ (ពិសេសសត្វល្អិតប្លង់តុង) ពុំទាន់មាន ឬមានតិចតួច យើងក៏អាចដាក់កូនត្រីចិញ្ចឹមក្នុងស្រះបានដែរ ប៉ុន្តែត្រូវយកចិត្តទុកដាក់បន្ថែមជីលាមកសត្វតាមបច្ចេកទេស ដូចក្នុងមេរៀនទី ៤ ខាងលើ និងចាំបាច់ត្រូវដាក់ចំណីបន្ថែមឲ្យត្រីឲ្យបានរៀងរាល់ថ្ងៃ រហូតដល់ក្នុងស្រះមានចំណីធម្មជាតិគ្រប់គ្រាន់។

## ៦- ប្រភេទជីធម្មជាតិសម្រាប់ដាក់ស្រះត្រី

### គោលបំណង:

ចង់ឲ្យកសិករយល់ច្បាស់ពី :

១.ប្រភេទជីធម្មជាតិអ្វីខ្លះ ដែលមានស្រាប់នៅក្នុងភូមិ ឬក៏គ្រួសារកសិករម្នាក់ៗមានស្រាប់ក្នុងផ្ទះរបស់ខ្លួន សម្រាប់ដាក់ក្នុងស្រះចិញ្ចឹមត្រី ដើម្បីឲ្យស្រះចិញ្ចឹមត្រីមានចំណីធម្មជាតិ ដែលជាចំណីសំខាន់សម្រាប់ត្រី ជាពិសេសសត្វល្អិតប្លង់តុង មុនពេលដាក់កូនត្រីចិញ្ចឹម។

២. បរិមាណជីធម្មជាតិដែលត្រូវដាក់នៅក្នុងស្រះចិញ្ចឹមត្រី ឲ្យបានត្រឹមត្រូវតាមបច្ចេកទេស។

៣. និងវិធីសាស្ត្រនៃការប្រើប្រាស់ជីធម្មជាតិ ដើម្បីចិញ្ចឹមត្រីទទួលបានផលល្អ។

ប្រភេទលាមកសត្វខាងក្រោមនេះ មានប្រយោជន៍យ៉ាងសំខាន់សម្រាប់ដាក់ស្រះត្រី:



*លាមកគោ*



*លាមកជ្រូក*



*លាមកមាន់-ទា*



*ទន្រ្ទានខែត្រ* →



*ត្រាំក្នុងធុង ឬរណ្តៅជី១អាទិត្យ* →



*រួចបង្ហូរចូលស្រះ*

**បរិមាណជីធម្មជាតិ សម្រាប់ប្រើរៀបចំស្រះ មុនពេលដាក់កូនត្រីចិញ្ចឹម:**

- ជីលាមកគោ ក្របី — ៦០-៨០ គ.ក្រ/១០០ម$^{២}$ នៃផ្ទៃស្រះ
- ឬជីលាមកជ្រូកសើម — ២០-៣០ គ.ក្រ/១០០ម$^{២}$ នៃផ្ទៃស្រះ
- ឬជីលាមកមាន់ ទាសើម — ១០-១៥ គ.ក្រ/១០០ម$^{២}$ នៃផ្ទៃស្រះ
- ឬជីបៃតង( ទន្រ្ទានខែត្រ...) — ២០-៣០ គ.ក្រ/១០០ម$^{២}$ នៃផ្ទៃស្រះ

**ចូរចងចាំថា:**

- ការដាក់ជីជាប្រចាំ ដើម្បីឲ្យទឹកស្រះមានពណ៌បៃតង ជាកត្តាសំខាន់ណាស់ ធ្វើឲ្យត្រីធំធាត់ល្អ។
- ចៀសវាងការប្រើជីធម្មជាតិច្រើនលើសកំណត់ ដែលនាំឲ្យទឹកស្រះស្អុយ មានជាតិពុល និងអាចធ្វើឲ្យត្រីងាប់។

## ៧- ប្រភេទត្រីសមស្របសម្រាប់កសិករដាក់ចិញ្ចឹមក្នុងស្រះ

### ការជ្រើសរើសប្រភេទត្រីចិញ្ចឹមក្នុងស្រះ ត្រូវអនុវត្តតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- ស៊ីចំណីធម្មជាតិជាសំខាន់ ដែលកសិករមានស្រាប់នៅក្នុងមូលដ្ឋានដូចក្នុងមេរៀនទី១០ខាងក្រោម ដែលបានរៀបរាប់បញ្ជាក់។
- ងាយចិញ្ចឹមក្នុងស្រះ ដែលមានទឹកយ៉ាងហោចណាស់ក្នុងរយៈពេលពី ៦ ទៅ ៨ខែ ។
- ស៊ីចំណីផ្សំបន្ថែម ដូចក្នុងមេរៀនទី១០ និង ទី១១។
- ធន់នឹងជំងឺ និងងាយរកពូជដាក់ចិញ្ចឹម។

| ប្រភេទត្រីក្នុងស្រុក | | ប្រភេទត្រីក្រៅស្រុក | |
|---|---|---|---|
| រូបរាងត្រី | ឈ្មោះត្រី | រូបរាងត្រី | ឈ្មោះត្រី |
|  | ផ្តិន |  | ទីឡាព្យ៉ា |
|  | កន្ធរ |  | កាបសាមញ្ញ |
|  | បង្កង |  | កាបស |
|  | កាហែ |  | កាបឥណ្ឌា(ម្រឹហ្គាល់) |
|  | ព្រលូង |  | កាបឥណ្ឌា(រ៉ូហ៊ូ) |
|  | ប្រា |  | ទីឡាព្យ៉ាក្រហម |
|  | ត្រចៀកដំរី | | |
|  | អណ្តែង | | |
|  | ក្រាញ់ | | |

### ខាងក្រោមនេះជាលក្ខណៈជីវសាស្ត្រនៃប្រភេទត្រី ដែលអាចដាក់ចិញ្ចឹមក្នុងស្រះបាន៖

#### ក- ត្រីផ្តិន

ជាប្រភេទត្រីក្នុងស្រុក រស់នៅតាមទន្លេ ស្ទឹង បឹងបួ។ ចូលចិត្តរស់នៅស្រទាប់ទឹកខាងលើ និងកណ្តាល។ ត្រីផ្តិនអាចមានទម្ងន់ពី ២ ទៅ ៥ខាំ ក្នុងរយៈពេលចិញ្ចឹម ១ឆ្នាំ និងអាចបន្តពូជបាននៅពេលវាមានអាយុចាប់ពី ៨ ខែឡើងទៅ បើមានការគ្រប់គ្រងបានល្អ។ ត្រីផ្តិនជាប្រភេទត្រីធន់នឹងជំងឺ និងអាចចិញ្ចឹមក្នុងស្រះក៏បាន ចិញ្ចឹមក្នុងស្រែក៏បាន។

- ពេលនៅតូច វាស៊ីសត្វល្អិតតូចៗច្រើនប្រភេទដូចជា ពពួកសត្វល្អិតប្លង់តុង កណ្តៀរ កូនជន្លេនជាដើម និងស៊ីស្លឹករុក្ខជាតិជាសារាយតូចៗ ។ល។
- ពេលធំ វាចូលចិត្តស៊ីចំណី ច្រើនប្រភេទដូចជា កាកសំណល់បន្លែ ស្លឹករុក្ខជាតិ ចក ត្រកួន កណ្តៀរជាដើម ពិសេសសត្វល្អិតប្លង់តុង។
- វាអាចស៊ីចំណីបន្ថែមដូចជា កន្ទក់ ចុងអង្ករ ពោត សណ្តែក កាកសំណល់ផ្ទះបាយជាដើម។



ត្រីឆ្ពិន

## ខ- ត្រីកន្ធរ

ជាប្រភេទត្រីក្នុងស្រុក ចូលចិត្តរស់នៅក្នុងទឹកនឹងដូចជា បឹង ត្រពាំង ថ្លុក ស្រែ និងប្រឡាយ។ ចូលចិត្តរស់នៅស្រទាប់ទឹកខាងលើ និងកណ្តាល។ វាអាចរស់នៅក្នុងមជ្ឈដ្ឋានទឹក ដែលមានកម្រិតអុកស៊ីសែនទាប និងមានជាតិជូរ pH= 5.6-6។ ត្រីកន្ធរអាចមានទម្ងន់ពី ០.៥ ទៅ ១ខាំ ក្នុងរយៈពេលចិញ្ចឹម ១ឆ្នាំ និងអាចបន្តពូជក្នុងស្រះបាននៅពេលវាមានអាយុចាប់ពី ៨ខែឡើងទៅ បើមានការគ្រប់គ្រងបានល្អ។ ត្រីកន្ធរជាប្រភេទត្រីធន់នឹងជំងឺ និងអាចចិញ្ចឹមក្នុងស្រះក៏បាន ចិញ្ចឹមក្នុងស្រែក៏បាន។

- ពេលនៅតូច វាស៊ីសត្វល្អិតតូចៗច្រើនប្រភេទដូចជា ពពួកសត្វល្អិតប្លង់តុង កណ្តៀរ កូនជន្លេនជាដើម និងស៊ីស្លឹករុក្ខជាតិជាសារាយតូចៗ ។ល។
- ពេលធំ វាចូលចិត្តស៊ីចំណីច្រើនប្រភេទដូចជា កាកសំណល់បន្លែ ស្លឹករុក្ខជាតិ ចក ត្រកួន កណ្តៀរជាដើម ពិសេសសត្វល្អិតប្លង់តុង។
- វាអាចស៊ីចំណីបន្ថែមដូចជា កន្ទក់ ចុងអង្ករ ពោត សណ្តែក កាកសំណល់ផ្ទះបាយជាដើម។



ត្រីកន្ធរ

## គ- ត្រីកាបសាមញ្ញ

ជាប្រភេទត្រីក្រៅស្រុក រស់នៅក្នុងតំបន់ទឹកសាប ងាយស្រួលចិញ្ចឹម ព្រោះវាអាចរស់នៅក្នុងមជ្ឈដ្ឋានទឹក ដែលមានកម្រិតអុកស៊ីសែនទាប កម្រិតជាតិជូរ pH= 5.5- 8.5 និងអាចរស់នៅក្នុងសីតុណ្ហភាពពី ២០ ទៅ ៣០អង្សាសេ។ ចូលចិត្តរស់នៅក្នុងស្រទាប់ទឹកបាត (ស្រទាប់ទឹកខាងក្រោម)។ ក្រោយរយៈពេលចិញ្ចឹម ១ឆ្នាំ ត្រីកាបសាមញ្ញអាចមានទម្ងន់ពី ០.៥ ទៅ ១គីឡូក្រាម និងអាចបន្តពូជក្នុងស្រះបាននៅពេលវាមានអាយុចាប់ពី ១០ខែឡើងទៅ បើមានការគ្រប់គ្រងបានល្អ។ ត្រីកាបសាមញ្ញជាប្រភេទត្រីធន់នឹងជំងឺ និងអាចចិញ្ចឹមក្នុងស្រះក៏បាន ចិញ្ចឹមក្នុងស្រែក៏បាន។

- ពេលនៅតូច វាស៊ីសត្វល្អិតតូចៗច្រើនប្រភេទដូចជា ពពួកសត្វល្អិតប្លង់តុង កណ្តៀរ កូនជន្លេនជាដើម ។
- ពេលធំ វាចូលចិត្តស៊ីចំណីច្រើនប្រភេទដូចជា សត្វល្អិតប្លង់តុង កណ្តៀរ ជន្លេន កូនខ្យង កូនខ្ទៅ កូនក្តាម។
- វាអាចស៊ីចំណីបន្ថែមដូចជា កន្ទក់ ចុងអង្ករ ពោត សណ្តែក កាកសំណល់ផ្ទះបាយជាដើម។



*ត្រីកាបសាមញ្ញ*

## ឃ- ត្រីកាបឥណ្ឌា ( ម្រឹហ្គាល់ )

ជាប្រភេទត្រីក្រៅស្រុក រស់នៅក្នុងតំបន់ទឹកសាប ងាយស្រួលចិញ្ចឹម ព្រោះវាអាចរស់នៅក្នុងមជ្ឈដ្ឋានទឹក ដែលមានកម្រិតជាតិជូរ pH=5.5-8.5 និងអាចរស់នៅក្នុងសីតុណ្ហភាពពី២០ ទៅ ៣០អង្សាសេ។ ចូលចិត្តរស់នៅក្នុងស្រទាប់ទឹកបាត( ស្រទាប់ទឹកខាងក្រោម )។ ក្រោយរយៈពេលចិញ្ចឹម១ឆ្នាំ ត្រីកាបឥណ្ឌា (ម្រឹហ្គាល់) អាចមានទម្ងន់ពី០.៥ ទៅ ០.៧គីឡូក្រាម និងអាចបន្តពូជក្នុងស្រះបាននៅពេលវាមានអាយុចាប់ពី១៦ខែឡើងទៅបើមានការគ្រប់គ្រងបានល្អ។ត្រីកាបឥណ្ឌា( ម្រឹហ្គាល់) ជាប្រភេទត្រីធន់នឹងជំងឺ និងអាចចិញ្ចឹមក្នុងស្រះក៏បាន ចិញ្ចឹមក្នុងស្រែក៏បាន។

- ពេលនៅតូច វាស៊ីសត្វល្អិតតូចៗច្រើនប្រភេទ ដូចជា: ពពួកសត្វល្អិតប្លងតុង កណ្ដៀរ កូនជន្លេនជាដើម ។
- ពេលធំ វាចូលចិត្តស៊ីចំណីច្រើនប្រភេទដូចជា សត្វល្អិតប្លងតុង កណ្ដៀរ ជន្លេន កូនខ្យង កូនខ្ចៅ កូនក្ដាម ស្លឹករុក្ខជាតិ ចក។



*ត្រីកាបឥណ្ឌា (ម្រឹហ្គាល់)*

- វាអាចស៊ីចំណីបន្ថែមដូចជា កន្ទក់ ចុងអង្ករ ពោត សណ្ដែក កាកសំណល់ផ្ទះបាយជាដើម។

## ង- ត្រីទីឡាព្យ៉ា

ជាប្រភេទត្រីក្រៅស្រុក មានប្រភពមកពីប្រទេសអាហ្វ្រិកខាងជើង។ រស់នៅក្នុងតំបន់ទឹកសាប និងអាចរស់នៅក្នុងតំបន់ទឹកភ្លាវ។ ងាយស្រួលចិញ្ចឹម ព្រោះវាអាចរស់នៅក្នុងមជ្ឈដ្ឋានទឹក ដែលមានកម្រិតអុកស៊ីសែនរលាយតិច ( ៣មីលីក្រាមក្នុង១លីត្រទឹក ) កម្រិតជាតិជូរ pH=4-9 និងអាចរស់នៅក្នុង សីតុណ្ហភាពទឹកពី ១៤ ទៅ ៤០អង្សាសេ។ រស់នៅក្នុងគ្រប់ស្រទាប់ទឹក (ស្រទាប់ទឹកខាងលើ កណ្ដាល និងខាងក្រោម)។ ក្រោយរយៈពេលចិញ្ចឹម៦ខែត្រីទីឡាព្យ៉ាអាចមានទម្ងន់ពី០.១ ទៅ ០.២គីឡូក្រាម និងអាចបន្តពូជក្នុងស្រះតាមធម្មជាតិបានចំនួនពី ៦ ទៅ ១០ដងក្នុង១ឆ្នាំ បើមានការគ្រប់គ្រងបានល្អ។ត្រីទីឡាព្យ៉ាជាប្រភេទត្រីធន់នឹងជំងឺ និងអាចចិញ្ចឹម ក្នុងស្រះក៏បាន ចិញ្ចឹមក្នុងស្រែក៏បាន។

- ពេលនៅតូច វាស៊ីសត្វល្អិតតូចៗច្រើនប្រភេទ ដូចជា ពពួកសត្វល្អិតប្លងតុង កណ្ដៀរ កូនជន្លេន និងស៊ីស្លឹករុក្ខជាតិជាសារាយតូចៗជាដើម ។
- ពេលធំ វាចូលចិត្តស៊ីចំណីច្រើនប្រភេទដូចជា សត្វល្អិតប្លងតុង កណ្ដៀរ ជន្លេន កូនខ្យង កូនខ្ចៅ កូនក្ដាម ស្លឹករុក្ខជាតិ ចក។
- វាអាចស៊ីចំណីបន្ថែមដូចជា កន្ទក់ ចុងអង្ករ ពោត សណ្ដែក កាកសំណល់ផ្ទះបាយជាដើម។



*ត្រីទីឡាព្យ៉ា*

## ៨- ការដឹកជញ្ជូនកូនត្រី

### គោលបំណង៖

ដើម្បីទទួលបាន:

- កូនត្រីមានសុខភាពល្អ អត្រារស់ច្រើន នៅពេលដឹកជញ្ជូន និងក្រោយពេលដាក់កូនត្រីចិញ្ចឹម។
- ចំណេះដឹងបច្ចេកទេសការដឹកជញ្ជូនកូនត្រី។

ការដឹកជញ្ជូនកូនត្រី ត្រូវយកចិត្តទុកដាក់បច្ចេកទេសដូចខាងក្រោម :

- មធ្យោបាយដឹកជញ្ជូនកូនត្រីចំងាយផ្លូវជិតត្រូវមានម៉ូតូ កង់ ឬរ៉ឺកទៅតាមទីតាំងចំងាយផ្លូវដឹកជញ្ជូនកូនត្រី។ ចំពោះចំងាយផ្លូវឆ្ងាយត្រូវមាន ឡាន ឬម៉ូតូទៅតាមទីតាំងចំងាយផ្លូវដឹកជញ្ជូន និងបរិមាណកូនត្រីត្រូវដឹកជញ្ជូន។




មធ្យោបាយដឹកជញ្ជូនកូនត្រីផ្លូវជិត



មធ្យោបាយដឹកជញ្ជូនកូនត្រីផ្លូវឆ្ងាយ

- សម្ភារដឹកជញ្ជូនកូនត្រីចំងាយផ្លូវជិតត្រូវមាន កញ្ជេរ និងបាវ ឬស្លឹកចេក សម្រាប់ទ្រាប់កញ្ជេរដាក់ថង់កូនត្រី។ ក្នុងករណីដឹកជញ្ជូនកូនត្រីចំងាយផ្លូវជិតៗ អាចប្រើសម្ភារធុងដាក់កូនត្រី និងស្លឹកចេក ឬស្លឹកឈូក សម្រាប់ដាក់ពីលើទឹកក្នុងធុងការពារពេលដឹកកូនត្រីកុំឲ្យទឹកក្រឡុកចេញពីធុង។
- សម្ភារដឹកជញ្ជូនកូនត្រីចំងាយផ្លូវឆ្ងាយ ត្រូវមានធុងខ្យល់អុកស៊ីសែនសម្រាប់ដូរខ្យល់ ស្បោង ឬថង់ប្រកកូនត្រី និងកៅស៊ូចងថង់ សម្រាប់ផ្លាស់ប្តូរនៅពេលថង់កូនត្រីធ្លាយ ឬរហែក និងគួរមានថង់បាវអង្ករសម្រាប់ប្រកថង់កូនត្រីពីក្រៅ ដើម្បីការពារថង់កូនត្រីធ្លាយ ឬរហែក (រូបភាពខាងក្រោម)។
- ជាទូទៅថង់ប្រកកូនត្រីមានទំហំបណ្តោយ ឬកម្ពស់ ០.៨ ម៉ែត្រ និងទទឹងមាត់ថង់ ០.៦ម៉ែត្រ អាចដាក់កូនត្រីដែលមានទំហំពី ៥ ទៅ ៧ស.ម បានចំនួនពី ១០០ ទៅ ២០០ក្បាល សម្រាប់ដឹកជញ្ជូនផ្លូវឆ្ងាយ។
- ក្នុងករណីដឹកជញ្ជូនកូនត្រីចំងាយផ្លូវឆ្ងាយ អ្នកដឹកជញ្ជូនគួរចេះវិធីចងថង់កូនត្រីតាមរបៀបដូចរូបភាពខាងក្រោម នៅពេលមានថង់កូនត្រីធ្លាយ ឬរហែក។



*របៀបចងវេចខ្ចប់ថង់កូនត្រី ដោយប្រើខ្យល់អុកស៊ីសែន*

- ពេលវេលាដឹកជញ្ជូនកូនត្រី គួរដឹកនៅពេលមេឃ ឬអាកាសធាតុត្រជាក់ ដើម្បីឲ្យកូនត្រីមានសុខភាពល្អ និងដឹកជញ្ជូនបានរយៈពេលយូរ។ ក្នុងករណីដឹកជញ្ជូនកូនត្រីនៅពេលមេឃ ឬអាកាសធាតុក្តៅខ្លាំង ត្រូវរៀបចំមធ្យោបាយដឹកជញ្ជូន ឲ្យមានម្លប់ការពារកំដៅថ្ងៃ និងចៀសវាងការរៀបចំម្លប់គ្របជាទ្រុងជិតខ្យល់ចេញ-ចូលតែម្តង ព្រោះនាំឲ្យកំដៅថ្ងៃកើនឡើងក្នុងទ្រុងនោះ។ បើមានលទ្ធភាព ដឹកជញ្ជូនកូនត្រីក្នុងរថយន្តមានម៉ាស៊ីនត្រជាក់គ្រប់គ្រាន់កាន់តែប្រសើរ។



*ឡានដឹកកូនត្រីរៀបចំឲ្យមានតែដំបូល គ្របពីលើ ដើម្បីឲ្យមានខ្យល់ចេញ-ចូល*

- ក្នុងករណីដឹកជញ្ជូនកូនត្រីទៅផ្លូវឆ្ងាយ ឬដឹកជញ្ជូនកូនត្រីនៅពេលយប់ អ្នកលក់កូនត្រី ឬអ្នកវេចចងថង់កូនត្រី ត្រូវរៀបចំទុកដាក់កូនត្រីឲ្យបានល្អ នៅមុនពេល ១ថ្ងៃដឹកជញ្ជូន ដោយត្រូវចាប់កូនត្រីពីស្រះមកប្រោះទុកក្នុងអាងស៊ីម៉ង់ និងត្រូវផ្តល់ចរន្តទឹកចេញ-ចូលជាប់រហូត និងកុំផ្តល់ចំណីឲ្យត្រីស៊ី ដើម្បីឲ្យកូនត្រីមានសុខភាពល្អ ដឹកជញ្ជូនបានរយៈពេលយូរ និងកុំឲ្យកូនត្រីងាប់ច្រើន។
- ទឹកដាក់ក្នុងថង់កូនត្រី ត្រូវមានគុណភាពល្អ ចៀសវាងយកទឹកស្រះដែលល្អក់ពេក ឬទឹកស្រះមានក្លិនស្អុយ ឬយកទឹកអណ្តូងដែលមានកម្រិតខ្យល់អុកស៊ីសែនតិច ឬជាទឹកដែលអាចមានជាតិពុលផ្សេងៗ គួរយកទឹកស្រះមានកម្រិតខ្យល់អុកស៊ីសែនច្រើន ឬជាទឹកដែលគ្មានជាតិពុលមកប្រើច្រកថង់កូនត្រី។
- ក្នុងករណីត្រូវផ្លាស់ប្តូរទឹកថ្មីក្នុងថង់កូនត្រីនៅពេលដឹកជញ្ជូន គួរយកចិត្តទុកដាក់រកប្រភពទឹកដែលប្រាកដថា ល្អគ្មានជាតិពុលដើម្បីឲ្យកូនត្រីដឹកជញ្ជូនមានសុខភាពល្អ និងអត្រារស់ច្រើន។

## ៩- ការដាក់កូនត្រីចិញ្ចឹម

### គោលបំណង៖

ដើម្បីទទួលបាននូវ:

- កូនត្រីមានអត្រារស់ច្រើន ក្រោយពេលដាក់កូនត្រីចិញ្ចឹម។
- កូនត្រីមានសុខភាពល្អ និងការលូតលាស់ល្អ។

ការដាក់កូនត្រីចិញ្ចឹម ត្រូវយកចិត្តទុកដាក់បច្ចេកទេសដូចខាងក្រោម :

- នៅពេលកូនត្រីដឹកជញ្ជូនមកដល់ស្រះ ត្រូវត្រាំថង់កូនត្រីក្នុងទឹកស្រះនោះរយៈពេលពី ៣ ទៅ ៥នាទី រួចស្រាយមាត់ថង់បាចទឹកស្រះបញ្ចូលក្នុងថង់ ដើម្បីធ្វើឲ្យសីតុណ្ហភាពទឹកក្នុងថង់ និងទឹកក្នុងស្រះត្រីមានលំនឹងសីតុណ្ហភាពដូចគ្នាបន្តិចម្តងៗ ទើបអាចចាប់ផ្តើមលែងកូនត្រីចេញពីថង់ដោយសន្សឹមៗ។ ចៀសវាងការចាក់លែងកូនត្រីចេញពីថង់ ឬចេញពីធុងចូលក្នុងស្រះភ្លាមៗតែម្តង ដែលធ្វើឲ្យកូនត្រីងាយនឹងងាប់បាន ក្រោយពេលលែងចូលស្រះហើយ។

គួរអនុវត្តតាមរូបភាពដូចខាងក្រោម:





- កូនត្រីដាក់ចិញ្ចឹមក្នុងស្រះគួរមានទំហំ ៥សង់ទីម៉ែត្រ ដើម្បីឲ្យកូនត្រីមានអត្រារស់ច្រើន ក្រោយពេលដាក់កូនត្រីចិញ្ចឹមក្នុងស្រះហើយ។ ត្រូវចៀសវាងដាក់កូនត្រីចិញ្ចឹមមានទំហំតូច ដែលធ្វើឲ្យការចិញ្ចឹមត្រីក្នុងស្រះមិនទទួលបានផលល្អ ព្រោះអាចមានត្រីស្រែចាប់ស៊ីបានយ៉ាងងាយ។
- ការចិញ្ចឹមត្រីក្នុងស្រះជាលក្ខណៈគ្រួសារ កសិករអាចដាក់កូនត្រីបានតែចំនួនពី ៣ ទៅ ៥ក្បាល ក្នុង១ម៉ែត្រការេនៃផ្ទៃស្រះទាំងអស់ ។ ដើម្បីឲ្យការចិញ្ចឹមត្រីក្នុងស្រះទទួលបានផលល្អនិងបរិមាណច្រើន គួរចិញ្ចឹមត្រីក្នុងស្រះភ្ជាប់ទៅនឹងវាលស្រែ និងចាំបាច់ត្រូវផ្តល់ចំណីបន្ថែម។





*ទំហំកូនត្រី ៥ ស.ម*

- កូនត្រីដាក់ចិញ្ចឹមត្រូវមានសុខភាពល្អ គ្មានជំងឺ គ្មានមេរោគឆ្លង។ ដូចនេះគួរទិញកូនត្រីពីប្រភពដែលយើងត្រូវដឹងច្បាស់លាស់ថាគ្មានមេរោគ និងជំងឺឆ្លងផ្សេងៗ។ ម្យ៉ាងទៀតនៅលើដងខ្លួនត្រីកុំឲ្យមានស្នាមរបួស ឬដំបៅ ដងខ្លួនត្រង់ មានពណ៌សម្បុរភ្លឺថ្លា និងមានសកម្មភាពហែលរហេសរហួន។
- ដើម្បីឲ្យកូនត្រីមានអត្រារស់ច្រើន ក្រោយពេលដាក់កូនត្រីចិញ្ចឹម ត្រូវរៀបចំស្រះឲ្យមានគុណភាពទឹកល្អ មានពណ៌បៃតងខ្ចី និងគ្មានជាតិពុល។
- ម្យ៉ាងទៀត គួរចៀសវាងលែងកូនត្រីនៅពេលមេឃជិតភ្លៀង កំពុងភ្លៀង ក្រោយពេលភ្លៀង ឬលែងនៅពេលយប់ ព្រោះវាគ្មានពន្លឺថ្ងៃ ធ្វើឲ្យទឹកស្រះងាយខ្វះខ្យល់អុកស៊ីសែនបង្កើនជាតិពុលក្នុងស្រះ និងងាយធ្វើឲ្យកូនត្រីងាប់បាន។
- ចំនួនកូនត្រីដាក់ចិញ្ចឹមក្នុងស្រះជាលក្ខណៈគ្រួសារ គួរអនុវត្តដូចក្នុងតារាងខាងក្រោម៖

**តារាងទី ១៖ បរិមាណកូនត្រីដែលត្រូវដាក់ចិញ្ចឹមតាមប្រភេទត្រីនីមួយៗ (គិតជាភាគរយ)**

| ប្រភេទកូនត្រីដាក់ចិញ្ចឹម | ឆ្ពិន | ទីឡាព្យ៉ា | កាបស | កាបសាមញ្ញ/ឥណ្ឌា | ចំនួនកូនត្រីដាក់ចិញ្ចឹម |
|---|---|---|---|---|---|
| ប្រភេទត្រីឆ្ពិន ជាសំខាន់ | ៤០% | ៣០% | ២០% | ១០% | ពី៣ ទៅ ៥ក្បាល ក្នុង១ម៉ែត្រការេស្រះ |
| ប្រភេទត្រីទីឡាព្យ៉ាជាសំខាន់ | ៣០% | ៤០% | ២០% | ១០% | |
| ប្រភេទត្រីកាបសជាសំខាន់ (ស្រះត្រូវមានទឹកពណ៌បៃតងជាប់ជានិច្ច) | ៣០% | ២០% | ៤០% | ១០% | |
| ក្នុងករណីចិញ្ចឹមតែ៣ប្រភេទ | ៥០% | ៤០% | ១០% | | |
| | ៥០% | ៤០% | | ១០% | |
| | ៥០% | | ៤០% | ១០% | |
| | | ៥០% | ៤០% | ១០% | |

## ១០- ប្រភេទចំណីត្រីដែលមាននៅក្នុងមូលដ្ឋានកសិករ

### គោលបំណង:

ដើម្បីទទួលបាននូវ:

- កសិករបានយល់ដឹងច្បាស់ពីប្រភេទចំណីធម្មជាតិ ដែលមានក្នុងភូមិសម្រាប់ត្រីចិញ្ចឹមក្នុងស្រះ។
- កសិករចំណេញថវិកាមិនទិញចំណីពីផ្សារឲ្យត្រីស៊ី
- ចំណាយដើមទុនតិច កសិករបានផលត្រីហូប។

ក្រោយពេលដាក់កូនត្រីចិញ្ចឹមក្នុងស្រះ ត្រូវយកចិត្តទុកដាក់ដូចខាងក្រោម :

- ពិនិត្យចំណីធម្មជាតិរបស់ត្រីដែលមានក្នុងស្រះដូចជា សត្វល្អិតប្លងតុង រុក្ខជាតិប្លងតុង និងសត្វស្រទាប់បាតដូចជា ខ្យង ខ្ចៅ ជន្លេន។ របៀបពិនិត្យចំណីធម្មជាតិសត្វល្អិតប្លងតុង ត្រូវអនុវត្តតាមវិធីដូចក្នុងមេរៀនទី ៥ ខាងលើ។
- ក្នុងករណីចំណីធម្មជាតិ (សត្វល្អិតប្លងតុង) ពុំទាន់មាន ឬមានតិចតួចក្នុងស្រះគួរយកចិត្តទុកដាក់បន្ថែមដីលាមកសត្វតាមបច្ចេកទេសដូចក្នុងមេរៀនទី ៦ ខាងលើ។
- គួរផ្តល់ចំណីបន្ថែមដល់ត្រី នៅពេលសង្កេតឃើញថា ក្នុងស្រះគ្មាន ឬខ្វះចំណីធម្មជាតិ។
- ចំណីបន្ថែមដែលគួរដាក់ឲ្យត្រីស៊ីរួមមានដូចជា ជន្លេនដី ជន្លេនទឹក កណ្តៀរ ចកបាយទា កាកសំណល់បន្លែ កាកសំណល់ផ្ទះបាយ កន្ទក់ ជាដើម។ គួរផ្តល់ចំណីបន្ថែមឲ្យត្រីស៊ី ២ដងក្នុង១ថ្ងៃ និងគួរឲ្យត្រីស៊ីនៅពេលថ្ងៃ ងាយស្រួលតាមដានការស៊ីចំណីរបស់ត្រី។



*ជន្លេនដី*



*ជន្លេនក្រហម (ទឹក)*



*កណ្តៀរ*



*ចកបាយទា*



*កន្ទក់*



*កាកសំណល់បន្លែ*

## ១១- ប្រភេទចំណីផ្សំ

### គោលបំណង៖

ដើម្បីទទួលបាននូវ:

- កសិករបានយល់ដឹងច្បាស់ពីប្រភេទចំណីផ្សំ ដែលមានក្នុងភូមិសម្រាប់ត្រីចិញ្ចឹមក្នុងស្រះ។
- របៀបផ្សំចំណីត្រីសម្រាប់ផ្តល់ឲ្យត្រីស៊ី។
- ទិន្នផលត្រីកើនឡើង។

ក្រៅពីចំណីធម្មជាតិ យើងអាចផ្តល់ចំណីផ្សំឲ្យត្រីស៊ីតាមរបៀបដូចខាងក្រោម:

- ជាទូទៅ ចំណីផ្សំគួររៀបចំឡើងឲ្យមានសារជាតិអាហារប្រូតេអ៊ីនខ្ពស់ ដើម្បីផ្តល់ចំណីឲ្យត្រីស៊ីមានសុខភាពល្អ និងត្រីឆាប់លូតលាស់បានរហ័ស។
- ចំណីផ្សំរៀបចំសម្រាប់ផ្តល់ឲ្យត្រីស៊ីបន្ថែមពីលើចំណីធម្មជាតិដែលមានស្រាប់ក្នុងស្រះ ដោយប្រើប្រាស់ធាតុផ្សំដែលមានស្រាប់ក្នុងមូលដ្ឋានដូចជា កន្ទក់ ចុងអង្ករ សណ្តែកសៀង កាកសំណល់ ត្រីហាល ឬ ម្សៅត្រី ឬចំណីគ្រាប់ លាយផ្សំបញ្ចូលគ្នារួចចំអិនតាមរូបមន្តដូចខាងក្រោម៖

សមាសធាតុផ្សំចំណី:


ត្រីហាល

ឬ


ឬចំណីគ្រាប់២០%

ផ្សំជាមួយ


កន្ទក់៦០%

ផ្សំជាមួយ


ចុងអង្ករ ១០%


សណ្តែកសៀង ១០%


យកទៅកូរចំអិនជាមួយគ្នា


ទទួលបានចំណីផ្សំសម្រេច

រូបមន្តចំណីផ្សំ

| |
|---|
| ត្រីហាល ឬចំណីគ្រាប់ ២០% + កន្ទក់ ៦០% + ចុងអង្ករ ១០% + សណ្តែកសៀង ១០% |

- រូបមន្តផ្សំចំណីនេះ អាចផ្លាស់ប្តូរចំនួនភាគរយនៃសមាសធាតុផ្សំណាមួយក៏បាន អាស្រ័យទៅតាមលទ្ធភាពរបស់កសិករម្នាក់ៗ (ដូចក្នុងតារាងខាងក្រោម)។ ប៉ុន្តែគួររក្សាសមាសធាតុផ្សំចំណីនេះឲ្យនៅដដែលជាការល្អ ព្រោះជាសមាសធាតុផ្សំចំណីដែលមានសារជាតិប្រូតេអ៊ីនច្រើន។ ជាទូទៅសារជាតិប្រូតេអ៊ីនខ្ពស់ មាននៅក្នុងសារធាតុផ្សំចំណីម្សៅត្រី និងសណ្តែកសៀង។ ដូចនេះ ដើម្បីបង្កើនសារជាតិអាហារប្រូតេអ៊ីនខ្ពស់ គួរបង្កើនបរិមាណចំណីម្សៅត្រី ឬសណ្តែកសៀង។ កសិករគួរបង្កើនបរិមាណចំណីសណ្តែកសៀងជាការល្អ ព្រោះវាមានតម្លៃថោកជាងម្សៅត្រី។

តារាងទី ២៖ សមាសធាតុ និងបរិមាណចំណីដែលត្រូវផ្សំបញ្ចូលគ្នា

| លរ | សមាសធាតុផ្សំចំណី | បរិមាណធាតុផ្សំចំណី (គ.ក្រ ឬ ក្រាម) | | |
|---|---|---|---|---|
| | | គំរូទី ១ | គំរូទី ២ | គំរូទី ៣ |
| ១ | ម្សៅត្រី ឬចំណីគ្រាប់ប្រូតេអ៊ីនខ្ពស់(៤០%) | ២០ | ២០ | ២០ |
| ២ | សណ្តែកសៀង | ៦០ | ៤០ | ៣០ |
| ៣ | កន្ទក់ | ១០ | ៣០ | ៤០ |
| ៤ | ចុងអង្ករ | ១០ | ១០ | ១០ |
| | សរុបគិតជា (គ.ក្រ ឬ ក្រាម) | ១០០ | ១០០ | ១០០ |

- ចំណីផ្សំដោយចម្អិនជាប្រភេទចំណីស្អិត ដូចនេះគួររៀបចំចំណីស្អិតនេះពូតជាដុំដាក់ក្នុងកញ្ច្រែងចងព្យួរឲ្យត្រីស៊ីដូចរូបភាពខាងក្រោម ដើម្បីងាយស្រួលពិនិត្យមើលសកម្មភាពត្រីស៊ីចំណីផង និងដើម្បីត្រួតពិនិត្យមើលបរិមាណចំណីដែលបានដាក់ឲ្យត្រីស៊ីផង ។ ក្នុងករណីត្រីស៊ីចំណីអស់ គួរបន្ថែមបរិមាណចំណីឲ្យបានច្រើននៅពេលក្រោយ។
- ចំណីផ្សំគួររៀបចំចម្អិនឲ្យត្រីស៊ីមួយពេល ឬមួយថ្ងៃឲ្យអស់ ចៀសវាងទុកចំណីផ្សំឲ្យត្រីស៊ីនៅពេលក្រោយទៀត ព្រោះចំណីទុកយូរនឹងងាយខូចគុណភាព។





*ការដាក់ចំណីឲ្យត្រីដោយប្រើកញ្ច្រែង*

# ១២- របៀបដាក់ជីក្រោយពេលលែងកូនត្រី

## គោលបំណង:

ដើម្បីយល់ដឹងច្បាស់ពី

- ប្រភេទ និងបរិមាណជីដែលត្រូវប្រើ ក្រោយពេលដាក់កូនត្រីចិញ្ចឹម
- ពេលវេលា និងបច្ចេកទេសនៃការប្រើជី។

-ជាទូទៅ ក្រោយពេលលែងកូនត្រីចូលក្នុងស្រះហើយរយៈពេល ១សប្តាហ៍ បរិមាណចំណីធម្មជាតិ ជាពិសេស សត្វល្អិតប្លុងតុងនៅសល់តិចតួច ព្រោះកូនត្រីស៊ី ។ ប៉ុន្តែមុនពេលបង្ហូរទឹកជីធម្មជាតិលាមកសត្វពីរណ្តៅជីចូលក្នុងស្រះ ត្រូវដួសទឹកស្រះមកពិនិត្យមើលតាមវិធីសាស្ត្របានបញ្ជាក់ក្នុងមេរៀនទី ៥ខាងលើ ។

-ការបង្ហូរទឹកជីលាមកសត្វចូលក្នុងស្រះ ត្រូវបង្ហូរនៅពេលមានពន្លឺថ្ងៃគ្រប់គ្រាន់ ។ ចៀសវាងបង្ហូរទឹកជីនៅពេលមេឃជិតភ្លៀង កំពុងភ្លៀង និងក្រោយពេលភ្លៀង ឬបង្ហូរនៅពេលយប់ ព្រោះវាគ្មានពន្លឺថ្ងៃគ្រប់គ្រាន់ ធ្វើឲ្យទឹកស្រះងាយខ្វះខ្យល់អុកស៊ីសែន បង្កើនជាតិពុលក្នុងស្រះ និងងាយធ្វើឲ្យកូនត្រីងាប់បាន។

-ជាទូទៅ មុននឹងបង្ហូរទឹកជីពីរណ្តៅជីចូលក្នុងស្រះ ត្រូវពិនិត្យគុណភាពទឹកស្រះជាមុនសិន ព្រោះវាងាយធ្វើឲ្យកូនត្រីងាប់បាន។ ត្រូវចៀសវាងបង្ហូរទឹកជីនៅពេលទឹកស្រះមានក្លិនស្អុយ ឬទឹកស្រះមានពណ៌បៃតងខ្លាំង។

ចូរចងចាំថា: ការដាក់ជីជាប្រចាំ ដើម្បីឲ្យទឹកស្រះមានពណ៌បៃតងល្អតាមវិធីសាស្ត្រខាងលើ ជាកត្តាសំខាន់ណាស់ធ្វើឲ្យត្រីធំធាត់ល្អ។ ចៀសវាងការប្រើជីធម្មជាតិច្រើន ឬដាក់ជីលាមកសត្វផ្ទាល់ក្នុងស្រះចិញ្ចឹមត្រីនិងធ្វើឲ្យទឹកស្រះស្អុយ មានជាតិពុល និងអាចធ្វើឲ្យត្រីងាប់។




*កសិករអាចប្រើប្រាស់ពាងទឹក ឬកង់អណ្តូងទឹកធ្វើជារណ្តៅជីក៏បាន*

## ១៣- ការគ្រប់គ្រងស្រះចិញ្ចឹមត្រី

### គោលបំណង៖

ដើម្បីទទួលបាននូវ:

- ស្រះមានទឹកគ្រប់គ្រាន់ និងមានគុណភាពល្អ សម្បូរចំណីធម្មជាតិ។
- ត្រីមានសុខភាពល្អ អត្រារស់បានច្រើន។
- ត្រីលូតលាស់ឆាប់រហ័ស។

ក្នុងរយៈពេលចិញ្ចឹមត្រីក្នុងស្រះ ត្រូវយកចិត្តទុកដាក់សកម្មភាពសំខាន់ៗ ដូចខាងក្រោម ៖

- ចំពោះកសិករ ដែលមានលទ្ធភាពព័ទ្ធសំណាញ់នៅជុំវិញភ្លឺស្រះ ត្រូវឧស្សាហ៍ពិនិត្យមើលសំណាញ់កុំឲ្យមានធ្លុះធ្លាយ ឬរហែក ដើម្បីការពារកុំឲ្យត្រីកាច ឬកង្កែបពីខាងក្រៅលោតចូលក្នុងស្រះស៊ីកូនត្រី។
- ពិនិត្យភ្លឺស្រះឲ្យបានជាប់ជាប្រចាំ ការពារកុំឲ្យភ្លឺស្រះមានកន្លែងធ្លុះធ្លាយ ឬបាក់បែក និងគួរលើកភ្លឺស្រះឲ្យខ្ពស់ និងរឹងមាំល្អ ដើម្បីការពារកុំឲ្យស្រះលិចទឹក កូនត្រីចេញពីស្រះអស់។
- ពិនិត្យកំពស់ទឹកក្នុងស្រះកុំឲ្យស្រកចុះខ្លាំងពេក ដែលធ្វើឲ្យសីតុណ្ហភាពទឹក ឬកំដៅទឹកក្នុងស្រះកើនឡើង និងធ្វើឲ្យការលូតលាស់ត្រីមិនបានល្អ។ បើមានលទ្ធភាព គួររក្សាកំពស់ទឹកក្នុងស្រះឲ្យបានយ៉ាងហោចណាស់ជម្រៅ ១ម៉ែត្រ ដើម្បីឲ្យកូនត្រីបានលូតលាស់ឆាប់រហ័ស។
- ពិនិត្យភ្លឺស្រះឲ្យបានជាប់ជាប្រចាំ ការពារកុំឲ្យភ្លឺស្រះមានកន្លែងធ្លុះធ្លាយ ឬបាក់បែក និងគួរលើកភ្លឺស្រះឲ្យខ្ពស់ និងរឹងមាំល្អ ដើម្បីការពារកុំឲ្យស្រះលិចទឹក កូនត្រីចេញពីស្រះអស់។
- នៅពេលចង់បង្ហូរទឹក ឬបូមទឹកពីខាងក្រៅចូលក្នុងស្រះ គួរតែប្រយ័ត្នពីគុណភាពទឹកមកពីប្រភពខាងក្រៅកុំឲ្យមានជាតិពុល ឬថ្នាំគីមីដែលកសិករបានប្រើបាញ់លើដំណាំស្រូវ។
- គួរឧស្សាហ៍ផ្តល់ចំណីបន្ថែមឲ្យត្រីស៊ី និងផ្លាស់ប្តូរជីលាមកសត្វក្នុងរណ្តៅជី ដើម្បីឲ្យទឹកជីមានគុណភាពល្អនៅពេលបង្ហូរចូលក្នុងស្រែចិញ្ចឹមត្រី។
- ម្យ៉ាងទៀត ក្នុងរយៈពេលនៃការចិញ្ចឹមត្រី ត្រូវយកចិត្តទុកដាក់កុំឲ្យមានពពួកត្រីកាច និងសត្វកាចស៊ីកូនត្រីដូចជា ត្រីរ៉ស់ ត្រីអណ្តែង ត្រីក្រាញ់ ពស់ កង្កែប និងអន្ទង់ជាដើម ។ល។





- គួរចៀសវាងកុំឲ្យមានសត្វ គោ ក្របីចុះក្នុងស្រះនាំឲ្យទឹកស្រះល្អក់ ខូចគុណភាពទឹក កុំត្រាំឈើ ឬស្លឹកឈើ និងកុំបោកគក់ខោអាវ ឬលាងសម្ភារកខ្វក់ក្នុងទឹកស្រះចិញ្ចឹមត្រី ដែលងាយធ្វើឲ្យទឹកស្រះពុលងាប់កូនត្រីបាន។
- ត្រូវឧស្សាហ៍ផ្លាស់ប្តូរដីលាមកសត្វក្នុងរណ្តៅដី ដើម្បីធ្វើឲ្យរណ្តៅដីមានគុណភាពដីបានល្អសម្រាប់ដាក់ស្រះ កែលំអគុណភាពទឹកស្រះ និងធ្វើឲ្យទឹកស្រះសម្បូរចំណីធម្មជាតិ។



រណ្តៅដីត្រូវឧស្សាហ៍ផ្លាស់ប្តូរដីលាមកសត្វចាស់ចេញ



ត្រូវរក្សាគុណភាពទឹកស្រះឲ្យមានពណ៌បៃតងជានិច្ច



ត្រូវឧស្សាហ៍ត្រួតពិនិត្យសត្វល្អិតប្លងតុងក្នុងស្រះ



ទឹកស្រះត្រូវធ្វើឲ្យមានសត្វល្អិតប្លងតុងជានិច្ច

## ១៤- កត្តាសំខាន់ៗ ដែលត្រូវចៀសវាង

ក្នុងពេលចិញ្ចឹមត្រី ត្រីនឹងមានជំងឺ និងងាប់ ដោយសារបានអនុវត្តនូវសកម្មភាពដូចខាងក្រោម:



*ប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតជិតស្រះចិញ្ចឹមត្រី*



*ប្រើបង្គន់នៅពីលើស្រះចិញ្ចឹមត្រី*



*ត្រាំឈើ ឬស្លឹកត្នោតក្នុងស្រះកំពុងចិញ្ចឹមត្រី*



*ដាក់ចកអណ្តែតពេញផ្ទៃស្រះ*



*លាងធុងបាញ់ថ្នាំពុល ក្នុងស្រះកំពុងចិញ្ចឹមត្រី*



បោកគក់ខោអាវក្នុងស្រះកំពុងចិញ្ចឹមត្រី

## ១៥- គន្លឹះសំខាន់ៗមួយចំនួន សម្រាប់ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ

- ការសម្អាតស្រះមុនពេលដាក់កូនត្រីចិញ្ចឹម ជាកត្តាសំខាន់ណាស់ ធ្វើឲ្យការចិញ្ចឹមត្រីរបស់អ្នកទទួលបានជោគជ័យ
- បើមានត្រីផ្ទក់ ឬត្រីរស់តែមួយនៅក្នុងស្រះវានឹងស៊ីត្រីដែលអ្នកដាក់ចិញ្ចឹមអស់ ក្នុងរយៈពេលយ៉ាងខ្លី
- ការដាក់ជីជាប្រចាំ ដើម្បីឲ្យទឹកស្រះមានពណ៌បៃតង ជាកត្តាសំខាន់ណាស់ ធ្វើឲ្យត្រីរបស់អ្នកធំធាត់ល្អ
- ពន្លឺថ្ងៃជាកត្តាសំខាន់មួយ ធ្វើឲ្យចំណីធម្មជាតិ ឬប្លង់តុងកើតក្នុងស្រះបានល្អ ក្រោយពេលដាក់ជី
- ការចិញ្ចឹមត្រីក្នុងស្រះមានប្រឡាយភ្ជាប់ទៅស្រែ ជាវិធីមួយដ៏ល្អ ជួយឲ្យត្រីរបស់អ្នកធំធាត់ឆាប់រហ័ស
- ហើយអ្នកអាចកាត់បន្ថយការចំណាយប្រាក់ទិញចំណីត្រីទៀតផង ។







# ជំពូកទី២
# បច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែ





## ១- អត្ថប្រយោជន៍នៃការចិញ្ចឹមត្រីក្នុងស្រែ

### ចំពោះដំណាំស្រូវ



- កសិករចំណេញថវិកាមិនប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត សម្លាប់ស្មៅ និងជីគីមី ព្រោះការចិញ្ចឹមត្រីក្នុងស្រែត្រីស៊ីសត្វល្អិត និងស្មៅចង្រៃ ដែលបំផ្លាញដំណាំស្រូវ និងលាមកត្រីជាជីសម្រាប់ដំណាំស្រូវ។
- ត្រីឈ្មុសដីរកជន្លេនស៊ី ធ្វើឲ្យដីស្រែផុស និងដំណាំស្រូវលូតលាស់ល្អ។
- ទិន្នផលស្រូវកើនឡើង ដោយមិនចាំបាច់ប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត សម្លាប់ស្មៅ និងជីគីមីបង្កើនផលស្រូវក្នុងករណី៖



១. រៀបចំដាំដំណាំស្រូវ តាមគោលការណ៍បច្ចេកទេសបានល្អត្រឹមត្រូវ។

២.ទំហំផ្ទៃជម្រកត្រីក្នុងស្រែមិនតិចជាង ១ ភាគ ៥ នៃទំហំផ្ទៃស្រែសរុប ដង់ស៊ីតេដាក់កូនត្រីចិញ្ចឹមក្នុង ១ម៉ែត្រការេស្រែគឺ ១ក្បាលកូនត្រី និងអត្រារស់កូនត្រី នៅពេលប្រមូលផលមិនតិចជាង៨០%។

### ចំពោះត្រី



មិនចាំបាច់មានស្រះ កសិករក៏អាចចិញ្ចឹមត្រីបានហូបដែរ ដោយគ្រាន់តែជីកជម្រកត្រីក្នុងស្រែ។

កាត់បន្ថយការផ្តល់ចំណីបន្ថែម ក្នុងករណីចិញ្ចឹមត្រីក្នុងស្រែមានបរិមាណតិចតួច( ទំហំផ្ទៃជម្រកត្រីក្នុងស្រែមិនច្រើនជាង១ ភាគ ៥ នៃទំហំផ្ទៃស្រែសរុប និងដង់ស៊ីតេដាក់កូនត្រីចិញ្ចឹមក្នុង ១ម៉ែត្រការេស្រែគឺ ១ក្បាលកូនត្រី )។



ទិន្នផលត្រីកើនឡើង ក្នុងករណីផ្តល់ចំណីបន្ថែម និងជម្រកត្រីក្នុងស្រែមិនតិចជាង ១ ភាគ ៥ នៃទំហំផ្ទៃស្រែសរុប ដង់ស៊ីតេដាក់កូនត្រីចិញ្ចឹមក្នុង ១ម៉ែត្រការេស្រែគឺ ១ក្បាលកូនត្រី។

## ២- ការជ្រើសរើសទីតាំងស្រែចិញ្ចឹមត្រី

### គោលបំណង:

ជ្រើសរើសទីតាំងស្រែចិញ្ចឹមត្រី

- បានត្រឹមត្រូវតាមបច្ចេកទេស ដើម្បីចិញ្ចឹមត្រីទទួលបានជោគជ័យ។
- និងបង្កលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រង។

តើខ្ញុំត្រូវជ្រើសរើសទីតាំងស្រែចិញ្ចឹមត្រីយ៉ាងដូចម្តេច ?

យើងត្រូវជ្រើសរើសទីតាំងស្រែចិញ្ចឹមត្រីដូចខាងក្រោម :

- នៅជិតផ្ទះងាយស្រួលគ្រប់គ្រងមើលថែទាំ ការងារបច្ចេកទេស និងការលួចបាត់បង់ត្រី។
- ជាស្រែជម្រៅមិនលិចទឹកនៅរដូវវស្សា ឬលិចទឹកតិចតួចអាចលើកភ្លឺទប់បាន។
- ជាស្រែមានគុណភាពដីល្អ ឬដីមានជីវជាតិ ឬជាប្រភេទដីដែលអាចកែលំអបានដោយប្រើប្រាស់ជីធម្មជាតិ។
- ជាដីស្រែអាចរក្សាទឹកបានយូររយៈពេល ៦ខែ ដើម្បីឲ្យដំណាំស្រូវ និងត្រីលូតលាស់បានល្អ។
- ស្ថិតនៅទីវាលស្រឡះ គ្មានដើមឈើធំៗព័ទ្ធជុំវិញ ដែលនាំឲ្យបាំងពន្លឺព្រះអាទិត្យ។
- នៅជិតប្រភពទឹក បើសិនមានកាន់តែប្រសើរ ងាយស្រួលក្នុងការផ្លាស់ប្តូរទឹក ពេលទឹកក្នុងស្រែឡើងកំដៅខ្លាំងលើសពី ៤០អង្សាសេ និងត្រូវការបញ្ចូលទឹកក្នុងស្រែបន្ថែម នៅពេលទឹកក្នុងស្រែស្រកចុះ ដើម្បីចៀសវាងដំណាំស្រូវ និងត្រីក្នុងស្រែងាប់ ។
- នៅឆ្ងាយពីតំបន់ ដែលមានប្រើប្រាស់ថ្នាំពុលកសិកម្ម។







*មិនត្រូវជ្រើសរើសស្រែចិញ្ចឹមត្រី នៅជិតតំបន់ប្រើប្រាស់ថ្នាំពុលកសិកម្ម*

## ៣- លក្ខណៈស្រែចិញ្ចឹមត្រី

**គោលបំណង:**

ដើម្បីយល់ច្បាស់ពី

- ទ្រង់ទ្រាយ ឬរូបរាង និងទំហំស្រែដែលអាចចិញ្ចឹមត្រីបាន។
- លក្ខណៈបច្ចេកទេសនៃស្រែចិញ្ចឹមត្រី
- ការរៀបចំស្រែចិញ្ចឹមត្រី ឲ្យបានត្រឹមត្រូវតាមបច្ចេកទេសដើម្បីចិញ្ចឹមត្រីទទួលបានជោគជ័យ។



- ស្រែចិញ្ចឹមត្រីមានរូបរាងទ្រង់ទ្រាយបែបណាក៏អាចចិញ្ចឹមត្រីបានដែរ តែគួរមានរាងបួនជ្រុងទ្រវែងងាយស្រួលគ្រប់គ្រង។

ស្រែចិញ្ចឹមត្រីមានទំហំប៉ុនណាក៏អាចចិញ្ចឹមត្រីបានដែរ តែគួរមានទំហំពី ៥០០ម៉ែត្រការេឡើងទៅ សមស្របដល់ការចិញ្ចឹមត្រីបានធំធាត់ល្អ។



- ស្រែចិញ្ចឹមត្រីមានទំហំកាន់តែធំផលស្រូវ និងត្រីក៏ទទួលបានកាន់តែច្រើន ប៉ុន្តែទាមទារឲ្យមានការយកចិត្តទុកដាក់គ្រប់គ្រងឲ្យបានល្អដូចក្នុងមេរៀនទី ១៣ ខាងក្រោមបានបញ្ជាក់។
- ស្រែចិញ្ចឹមត្រីត្រូវមានភ្លឺខ្ពស់ និងមាំល្អ ដើម្បីការពារលិចទឹក និងត្រីរួចចេញពីស្រែ។
- នៅតាមភ្លឺស្រែត្រូវបង្កប់បំពង់ទឹក សម្រាប់បង្ហូរទឹកចេញពីស្រែ នៅពេលមានភ្លៀងធ្លាក់ខ្លាំងនិងសម្រាប់បង្ហូរទឹកពីក្រៅចូលស្រែវិញ នៅពេលទឹកក្នុងស្រែស្រកចុះ។



- ក្នុងស្រែចិញ្ចឹមត្រីត្រូវរៀបចំឲ្យមានជាប្រព័ន្ធប្រឡាយ ឬស្រះ ឬជីកស្រះតភ្ជាប់ទៅស្រែចិញ្ចឹមត្រី ដើម្បីជាជម្រកទឹកជ្រៅសម្រាប់ត្រីរស់នៅនៅពេលទឹកក្នុងស្រែស្រកចុះ និងងាយស្រួលនៅពេលប្រមូលផលត្រី។

- ជម្រកត្រីក្នុងស្រែអាចរៀបចំជាប្រព័ន្ធប្រឡាយ ឬស្រះក្នុងស្រែ ឬក៏ជាស្រះនៅខាងក្រៅស្រែ តែតភ្ជាប់ទៅស្រែដោយប្រឡាយ ( សូមមើលរូបភាពបញ្ជាក់ខាងក្រោម )។
- ក្នុងករណីរៀបចំប្រព័ន្ធប្រឡាយចិញ្ចឹមត្រីក្នុងស្រែគួររៀបចំឲ្យមានទទឹង ឬទំហំមាត់ប្រឡាយហោចណាស់ ១ម៉ែត្រ និងជម្រៅកន្លះម៉ែត្រ។ បើទំហំមាត់ប្រឡាយ និងជម្រៅមានទំហំធំជាងនេះកាន់តែប្រសើរ ដើម្បីឲ្យត្រីលូតលាស់បានល្អ។ ជាទូទៅ ប្រព័ន្ធប្រឡាយក្នុងស្រែចិញ្ចឹមត្រីគួរមានទំហំផ្ទៃសរុបប្រមាណ ១ ភាគ ៥ នៃផ្ទៃស្រែសរុប ឬអាចមានទំហំធំជាងនេះក៏បាន អាស្រ័យយើងចង់បាន។
- ចូរចងចាំថា  ទំហំផ្ទៃទឹកជាជម្រកត្រីកាន់តែធំ ទិន្នផលត្រីចិញ្ចឹមកាន់តែទទួលបានច្រើន ប៉ុន្តែចាំបាច់ត្រូវផ្តល់ចំណីបន្ថែមដល់ត្រី ព្រោះចំណីធម្មជាតិដែលមានក្នុងស្រែមិនគ្រប់គ្រាន់សម្រាប់ត្រីចិញ្ចឹមក្នុងស្រែ និងចាំបាច់ត្រូវបង្កើនការយកចិត្តទុកដាក់គ្រប់គ្រងបន្ថែមទៀត។
- ក្នុងករណីកសិករចង់ទទួលបានទាំងផលស្រូវ និងផលត្រី ទំហំផ្ទៃទឹកជាជម្រកត្រីមិនគួរលើសពី ១ភាគ ៥ នៃទំហំផ្ទៃដីស្រែសរុប។



ប្រព័ន្ធប្រឡាយចិញ្ចឹមត្រីក្នុងស្រែផ្សេងៗគ្នា

## ៤- របៀបជីកប្រព័ន្ធស្រែចិញ្ចឹមត្រី

### គោលបំណង:

ដើម្បីយល់ច្បាស់ពី

- ភាពផ្សេងៗគ្នានៃប្រព័ន្ធជម្រកត្រីក្នុងស្រែ ដែលមានលក្ខណៈសមស្របសម្រាប់ចិញ្ចឹមត្រី។
- របៀបជីកប្រព័ន្ធជម្រកត្រីក្នុងស្រែ។
- របៀបរៀបចំប្រព័ន្ធស្រែចិញ្ចឹមត្រីតាមលក្ខណៈបច្ចេកទេស ដើម្បីចិញ្ចឹមត្រីទទួលបានជោគជ័យ។

ប្រព័ន្ធស្រែចិញ្ចឹមត្រីអាចជីកបាន តាមរបៀបច្រើនយ៉ាងដូចខាងក្រោម : (រូបភាពក្នុងមេរៀនទី៣)

- ជីកជាប្រព័ន្ធប្រឡាយជុំវិញក្នុងស្រែចិញ្ចឹមត្រី
- ឬជីកជាប្រឡាយស្របនឹងជ្រុងភ្លឺស្រែណាមួយក៏បាន ក្នុងករណីគ្មានថវិកាគ្រប់គ្រាន់សម្រាប់ជីកប្រព័ន្ធប្រឡាយជុំវិញក្នុងស្រែ។
- បើជីកជាប្រព័ន្ធប្រឡាយខ្វែងកាត់ក្នុងស្រែក៏បាន
- ឬក៏ជីកជាកូនស្រះនៅក្នុងស្រែ ដែលមានកន្លែងទំនាបជាងគេក៏បាន ដើម្បីឲ្យទឹកក្នុងស្រែដក់ទឹកបានយូរ ជាប្រយោជន៍ដល់ការលូតលាស់របស់ត្រី។
- បើ ជីកប្រព័ន្ធប្រឡាយជុំវិញស្របនឹងភ្លឺស្រែ គួរទុកចំណីភ្លឺស្រែប្រមាណ ០.៥ម៉ែត្រ ទើបជីកប្រព័ន្ធប្រឡាយនោះ ដើម្បីការពារការហូរបាក់ដីពីភ្លឺស្រែ ចូលក្នុងប្រឡាយ ដែលនាំឲ្យទឹកប្រឡាយល្អក់ និងធ្វើឲ្យទឹកប្រឡាយរាក់ទៀតផង។





- ប្រព័ន្ធប្រឡាយ ឬជម្រកត្រីក្នុងស្រែ ត្រូវជីកឲ្យមានជើងទេរដើម្បីការពារកុំឲ្យដីធ្លាក់បាក់ចូលក្នុងប្រឡាយ ដែលនាំឲ្យទឹកស្រែល្អក់ និងប្រឡាយរាក់។
- អាចម៍ដីដែលជីកបាន ត្រូវយកមករៀបចំធ្វើជាទំនប់ភ្លឺស្រែកំពស់០.៥ម៉ែត្រ (ឬមានកំពស់ខ្ពស់ជាងនេះក៏បានអាស្រ័យនឹងកំពស់ទឹកជំនន់) ខ្នងលើស្រែប្រវែង០.៨ម៉ែត្រទៅ១ម៉ែត្រ រួចដាំស្មៅដើម្បីឲ្យទំនប់ភ្លឺស្រែរឹងមាំល្អ និងការពារទឹកជំនន់លិចស្រែចិញ្ចឹមត្រី។
- ប្រព័ន្ធប្រឡាយ ឬជម្រកត្រីក្នុងស្រែគួរជីកនៅជាប់ផ្លូវ ឬជាប់ភ្លឺស្រែដែលចេញ-ចូល ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង ឬក៏អាចជីកទៅតាមជម្រាលដីវាលស្រែជាក់ស្តែងក៏បាន។ ជាទូទៅ ប្រព័ន្ធប្រឡាយ ឬជម្រក

ត្រីក្នុងស្រែ គួរជីកនៅកន្លែងដែលមានជម្រាលទាបជាងគេ ដើម្បីឲ្យទឹកក្នុងស្រែដក់បានយូរនៅកន្លែងជម្រាលនោះ ម្យ៉ាងទៀតដើម្បីបង្កលក្ខណៈងាយស្រួលនៅពេលប្រមូលផលត្រី។

- ការជីកប្រព័ន្ធប្រឡាយ ឬជម្រកត្រីក្នុងស្រែ គួរចាប់ផ្តើមធ្វើនៅមុនពេលរដូវភ្លៀងធ្លាក់ និងក្រោយពេលភ្ជួររាស់ដាស់ដីស្រែរួចរាល់ហើយ ដើម្បីចៀសវាងការជីកប្រព័ន្ធប្រឡាយ ឬជម្រកត្រីក្នុងស្រែមិនបានល្អ។
- ម្យ៉ាងទៀត យើងអាចចិញ្ចឹមត្រីក្នុងស្រះជាមួយវាលស្រែបានដោយតភ្ជាប់ស្រះ និងវាលស្រែ ដោយជីកជាប្រឡាយ។ ករណីនេះ ធ្វើឲ្យទិន្នផលត្រីចិញ្ចឹមក្នុងស្រះកើនឡើង ដោយសារត្រីចិញ្ចឹមក្នុងស្រះចេញទៅវាលស្រែស្វែងរកស៊ីចំណីបានច្រើនក្នុងវាលស្រែដូចជា សត្វល្អិត និងស្មៅចង្រៃរបស់ដំណាំស្រូវ និងត្រូវផ្តល់ចំណីបន្ថែមដល់ត្រី។




គំរូរបៀបជីកប្រព័ន្ធប្រឡាយចិញ្ចឹមត្រីក្នុងស្រែ

## ៥- ការរៀបចំស្រែមុនពេលដាក់កូនត្រីចិញ្ចឹម

### គោលបំណងៈ

ដើម្បីទទួលបាននូវ

- កូនត្រីមានអត្រារស់ច្រើន ក្រោយពេលដាក់កូនត្រីចិញ្ចឹម។
- មិនប៉ះពាល់ដល់ដំណាំស្រូវ នៅមុនពេល ឬក្រោយពេលដាក់កូនត្រីចិញ្ចឹម។
- កូនត្រីមានការលូតលាស់ល្អ។
- ក្នុងស្រែគ្មានស្មៅ និងសត្វល្អិតបំផ្លាញដំណាំស្រូវ។

មុនពេលដាក់កូនត្រីចិញ្ចឹមក្នុងស្រែ គួររៀបចំដូចខាងក្រោមៈ

- វាលស្រែត្រូវភ្ជួររាស់ដាស់ដីឲ្យបានរៀបចំស្មើល្អ និងអាចប្រើប្រាស់ជីធម្មជាតិដាក់ក្នុងស្រែបានតាមបច្ចេកទេសនៃការរៀបចំស្រែ (គួរចៀសវាងការប្រើប្រាស់ជីគីមី ប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងសម្លាប់ស្មៅចង្រៃ ព្រោះនាំឲ្យពុលដល់កូនត្រីក្រោយពេលដាក់ចិញ្ចឹម និងខាតបង់ថវិកាថែមទៀតផង)។
- លុបរន្ធក្ដាម ពស់ កង្កែបនៅតាមភ្លឺស្រែ។



- នៅក្នុងប្រព័ន្ធប្រឡាយ ឬស្រះ ដែលជាជម្រកត្រីក្នុងស្រែ អាចបាចកំបោរសក្នុងបរិមាណពី ៥ ទៅ ៨គីឡូក្រាមក្នុងផ្ទៃដីជម្រកត្រីក្នុងស្រែ ១០០ម៉ែត្រការ រួចបញ្ចូលទឹកកន្លះម៉ែត្រ និងទុករយៈពេលពី ២ ទៅ ៣ថ្ងៃ រួចដាក់ជីលាមកសត្វក្នុងបរិមាណដូចខាងក្រោមៈ
  - ជីលាមក គោ ក្របីសើម ៦០- ៨០ គ.ក្រ/ ១០០ ម៉ែត្រការនៃផ្ទៃជម្រកត្រីក្នុងស្រែ
  - ឬជីលាមក ជ្រូកសើម ២០- ៣០ គ.ក្រ/ ១០០ ម៉ែត្រការនៃផ្ទៃជម្រកត្រីក្នុងស្រែ
  - ឬជីលាមក មាន់ ទាសើម ១០- ១៥ គ.ក្រ/ ១០០ ម៉ែត្រការនៃផ្ទៃជម្រកត្រីក្នុងស្រែ
  - ឬជីរុក្ខជាតិបៃតងទន្រ្ទានខែត្រ ២០- ៣០ គ.ក្រ/ ១០០ម៉ែត្រការនៃផ្ទៃជម្រកត្រីក្នុងស្រែ

  បន្ទាប់មកទុករយៈពេល ១សប្តាហ៍ ដើម្បីឲ្យជីលាមកសត្វរលាយសព្វបានល្អក្នុងទឹកប្រឡាយ។
- បន្ទាប់មក នៅលើផ្ទៃដីវាលស្រែ ក្រោយពេលរៀបចំភ្ជួររាស់ និងដាក់ជីធម្មជាតិហើយ អាចចាប់ផ្តើមស្ទូង ឬព្រោះគ្រាប់ស្រូវតាមបច្ចេកទេសនៃដំណាំស្រូវ។
- ចំពោះស្រែដែលស្ទូងតាមវិធីព្រោះគ្រាប់ស្រូវ ត្រូវព្រោះគ្រាប់ស្រូវឲ្យហើយក្នុងរយៈពេលពី ៤ទៅ ៥សប្តាហ៍ ដើម្បីឲ្យសន្ទូងដុះចាប់ឬសបានល្អ មុនពេលដាក់កូនត្រីចិញ្ចឹម។
- ចំពោះស្រែដែលស្ទូងតាមវិធីដាំសំណាប ត្រូវស្ទូងឲ្យហើយក្នុងរយៈពេល ២ ទៅ ៣សប្តាហ៍ ដើម្បីឲ្យសន្ទូងដុះចាប់ឬសបានល្អ មុនពេលដាក់កូនត្រីចិញ្ចឹម។
- ក្នុងស្រែកសិករគួរស្ទូងស្រូវជាជួរ និងឲ្យមានគម្លាតពីគ្នាចំងាយពី ២០ ទៅ ២៥សង់ទីម៉ែត្រ ដើម្បីឲ្យត្រីហែលចេញ ចូលក្នុងស្រែរកចំណីបានស្រួល។
- ចំពោះស្រែដាំស្រូវពង្រោះ កសិករគួរព្រោះគ្រាប់ស្រូវឲ្យពង្រាយ ឬឲ្យគន្លាតពីគ្នា និងគួរព្រោះគ្រាប់ស្រូវជា

ផ្លូវ ដោយទុកចន្លោះក្នុងផ្លូវនីមួយៗពី ២០ ទៅ ២៥សង់ទីម៉ែត្រ ដើម្បីឲ្យត្រីហែលចេញ-ចូលក្នុងស្រែរកចំណីបានស្រួល។

- បើកសិករដែលមានលទ្ធភាព គួរព័ទ្ធសំណាញ់ជុំវិញស្រែនៅពីលើភ្លឺស្រែ នៅមុនពេលបញ្ចូលទឹកក្នុងស្រែ ដើម្បីការពារកុំឲ្យត្រីស្រែ ឬកង្កែបលោតចូលក្នុងស្រែស៊ីកូនត្រី និងការពារទឹកជំនន់លិចចូលក្នុងស្រែផង (សូមមើលរូបភាពខាងក្រោម)។
- ចំពោះការបញ្ចូលទឹកក្នុងស្រែ ត្រូវប្រើតម្រងចងស្បៃនៅខាងចុងទុយោផ្នែកប្រភពទឹកបូម ឬបង្ហូរចូលស្រែ ដើម្បីការពារកុំឲ្យត្រីស្រែចូលក្នុងស្រែ នៅក្រោយពេលស្រែបានរៀបចំល្អហើយ ឬនៅមុនពេលដាក់កូនត្រីចិញ្ចឹមបានរយៈពេល ២ខែ។
- ត្រូវប្រាកដថា ប្រភពទឹកបញ្ចូលស្រែមានគុណភាពល្អ គ្មានជាតិពុល និងសារធាតុគីមីផ្សេងៗ ដែលនាំឲ្យកូនត្រីស្លាប់បាន។
- ក្រៅពីនេះ ត្រូវរៀបចំរណ្ដៅជីលាមកសត្វឲ្យនៅជាប់នឹងភ្លឺស្រែ ដើម្បីងាយស្រួលបង្ហូរទឹកជីចូលក្នុងស្រែចិញ្ចឹមត្រី ក្រោយពេលដាក់កូនត្រីចិញ្ចឹមហើយ ។ គួរចៀសវាងការដាក់ជីលាមកសត្វផ្ទាល់ក្នុងស្រែចិញ្ចឹមត្រី នៅក្រោយពេលដាក់កូនត្រីចិញ្ចឹមហើយ ព្រោះវាបណ្ដាលឲ្យកូនត្រីពុលងាប់យ៉ាងងាយ។រណ្ដៅជីគួរជីកដីទំហំបណ្ដោយប្រវែង ២ម៉ែត្រ ទទឹងប្រវែង ១ម៉ែត្រ ជម្រៅ ១ម៉ែត្រ ឬអាចជីកទំហំធំជាងនេះក៏បានអាស្រ័យនឹងទំហំស្រែដែលចិញ្ចឹមត្រី។សម្អាតបាតរណ្ដៅជី រួចក្រាលកម្រាលកៅស៊ូប្លាស្ទិក ដើម្បីការពារទឹកជីលាមកសត្វជ្រាបចូលក្នុងដី។ យើងអាចប្រើពាងទឹកធ្វើជារណ្ដៅជី ត្រាំជីលាមកសត្វក៏បាន ឬប្រើកង់អណ្ដូងរៀបធ្វើជារណ្ដៅជីក៏បានអាស្រ័យទៅនឹងលទ្ធភាពកសិករ។



*ព័ទ្ធសំណាញ់ជុំវិញភ្លឺស្រែ នៅមុនពេលបញ្ចូលទឹកក្នុងស្រែ*



*ការរៀបចំរណ្ដៅជីលាមកសត្វឲ្យនៅជាប់នឹងភ្លឺស្រែ នៅមុនពេលដាក់កូនត្រីចិញ្ចឹម*



## ៦- របៀបពិនិត្យចំណីធម្មជាតិនៅក្នុងស្រែ

### គោលបំណង:

ដើម្បីបញ្ជាក់ច្បាស់ពី

- ក្នុងស្រែមានចំណីធម្មជាតិ ជាពិសេសសត្វល្អិតប្លុងតុង មុនពេលដាក់កូនត្រីចិញ្ចឹម។
- វិធីងាយៗក្នុងការពិនិត្យចំណីធម្មជាតិក្នុងស្រែ ជាពិសេសសត្វល្អិតប្លុងតុង។
- កូនត្រីមានការលូតលាស់ល្អ ក្រោយពេលដាក់កូនត្រីចិញ្ចឹម។

ខាងក្រោមនេះ ជារូបភាពបង្ហាញពីរបៀបងាយៗក្នុងការពិនិត្យចំណីធម្មជាតិក្នុងស្រែ (ពិសេសសត្វល្អិតប្លុងតុង) ក្រោយពេលប្រើប្រាស់ជីដាក់ក្នុងស្រែហើយ។



*ប្រើក្រមាដួសទឹកគែមផ្រុងស្រែ*



*រូបភាពសត្វល្អិតប្លុងតុងក្នុងកែវ*



*ឬប្រើថ្នុងដួសទឹកគែមផ្រុងស្រែ*



*រូបភាពសត្វល្អិតប្លុងតុងក្នុងកែវ*

- ចំណីធម្មជាតិរួមមានសត្វល្អិតប្លុងតុង រុក្ខជាតិប្លុងតុង និងសត្វស្រទាប់បាតដូចជា ខ្យង ខ្ទៅ ជន្លេន ដែលកើតមានក្រោយពីការដាក់ជី។
- ក្នុងករណីចំណីធម្មជាតិ (ពិសេសសត្វល្អិតប្លុងតុង) ពុំទាន់មាន ឬមានតិចតួច យើងក៏អាចដាក់កូនត្រីចិញ្ចឹមក្នុងស្រែបានដែរ ប៉ុន្តែត្រូវយកចិត្តទុកដាក់បន្ថែម ជីលាមកសត្វតាមបច្ចេកទេស ដូចក្នុងមេរៀនទី៥ ខាងលើ និងចាំបាច់ត្រូវដាក់ចំណីបន្ថែមឲ្យត្រីឲ្យបានរៀងរាល់ថ្ងៃ រហូតដល់ក្នុងស្រែមានចំណីធម្មជាតិគ្រប់គ្រាន់។

## ៧- ប្រភេទត្រីសមស្របសម្រាប់ដាក់ចិញ្ចឹមក្នុងស្រែ

**គោលបំណង:**

ដើម្បីយល់ដឹងច្បាស់ពី

- ប្រភេទត្រីសមស្របដែលស៊ីចំណីធម្មជាតិ និង មានស្រាប់ក្នុងស្រែ ដូចជា សត្វល្អិត ស្មៅ ជាដើម ។
- ប្រភេទត្រីដែលអាចចិញ្ចឹមក្នុងស្រែបានក្នុងរយៈពេល មានទឹកពី ៤ ទៅ ៦ខែ។

ជារួមការជ្រើសរើសប្រភេទត្រីចិញ្ចឹមក្នុងស្រែ ត្រូវអនុវត្តតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម:

- ស៊ីចំណីធម្មជាតិដែលមានស្រាប់នៅក្នុងស្រែ ជាពិសេសស៊ីស្មៅ សត្វល្អិតចង្រៃបំផ្លាញដំណាំ ស្រូវ។
- ចៀសវាងចិញ្ចឹមប្រភេទ ត្រីដែលស៊ីស្មៅជាអាហារ ដូចជាប្រភេទត្រីកាបស៊ីស្មៅ ព្រោះវាស៊ីដំណាំ ស្រូវ។
- ចិញ្ចឹមឆាប់ធំក្នុងរយៈពេលខ្លី ( យូរបំផុតរយៈ ពេល ៦ខែ)។
- រស់នៅ និងធំធាត់ទឹករាក់ៗបាន
- ធន់នឹងជំងឺ។

## ប្រភេទត្រីក្រៅស្រុក


ត្រីទីឡាព្យ៉ា


ត្រីកាបសាមញ្ញ


ត្រីទីឡាព្យ៉ាក្រហម

## ប្រភេទត្រីក្នុងស្រុក


ត្រីឆ្ពិន


ត្រីអណ្ដែង


ត្រីក្រាញ់


ត្រីកន្ធរ


បង្កង



*ត្រីកាបឥណ្ឌា (ម្រីហ្គាល់)*



*ត្រីកាបឥណ្ឌា(រ៉ូហ៊ូ)*

## ខាងក្រោមនេះជាលក្ខណៈជីវសាស្ត្រនៃប្រភេទត្រី ដែលអាចដាក់ចិញ្ចឹមក្នុងស្រែបាន៖

### ក- ត្រីឆ្ពិន

ជាប្រភេទត្រីក្នុងស្រុក រស់នៅតាមទន្លេ ស្ទឹង បឹង បួរ។ ចូលចិត្តរស់នៅស្រទាប់ទឹកខាងលើ និងកណ្តាល។ ត្រីឆ្ពិនអាចមានទម្ងន់ពី ២ ទៅ ៥ខាំ ក្នុងរយៈពេលចិញ្ចឹម ១ឆ្នាំ និងអាចបន្តពូជបាននៅពេលវាមានអាយុចាប់ពី៨ខែ ឡើងទៅ បើមានការគ្រប់គ្រងបានល្អ។ ត្រីឆ្ពិនជាប្រភេទត្រីធន់នឹងជំងឺ និងអាចចិញ្ចឹមក្នុងស្រះក៏បាន ចិញ្ចឹមក្នុងស្រែក៏បាន។

- ពេលនៅតូច វាស៊ីសត្វល្អិតតូចៗច្រើនប្រភេទ ដូចជា ពពួកសត្វល្អិតប្លងគុង កណ្តៀរ កូនជន្លេន ជាដើម និងស៊ីស្លឹករុក្ខជាតិជាសារាយតូចៗ។ល។
- ពេលធំ វាស៊ីចំណីដូចជា កាកសំណល់បន្លែ ស្លឹករុក្ខជាតិ ចក ត្រកួនជាដើម។
- វាអាចស៊ីចំណីបន្ថែមដូចជា កន្ទក់ ចុងអង្ករ ពោត សណ្តែក កាកសំណល់ផ្ទះបាយជាដើម។



*ត្រីឆ្ពិន*

### ខ- ត្រីកន្ធរ

ជាប្រភេទត្រីក្នុងស្រុក ចូលចិត្តរស់នៅក្នុងទឹកនឹង ដូចជា បឹង ត្រពាំង ថ្លុក ស្រែ និងប្រឡាយ។ ចូលចិត្តរស់នៅស្រទាប់ទឹកខាងលើ និងកណ្តាល។អាចរស់នៅក្នុងមជ្ឈដ្ឋានទឹក ដែលមានកម្រិតអុកស៊ីសែនទាប និងមានជាតិជូរ pH= 5.6-6។ ត្រីកន្ធរអាចមានទម្ងន់ពី ០.៥ ទៅ ១ខាំ ក្នុងរយៈពេលចិញ្ចឹម ១ឆ្នាំ និងអាចបន្តពូជក្នុងស្រះបាននៅពេលវាមានអាយុចាប់ពី ៨ខែឡើងទៅ បើមានការគ្រប់គ្រងបានល្អ។ ត្រីកន្ធរជាប្រភេទត្រីធន់នឹងជំងឺ និងអាចចិញ្ចឹមក្នុងស្រះក៏បាន ចិញ្ចឹមក្នុងស្រែក៏បាន។

- ពេលនៅតូច វាស៊ីសត្វល្អិតតូចៗច្រើនប្រភេទ ដូចជា ពពួកសត្វល្អិតប្លងគុង កណ្តៀរ កូនជន្លេន ជាដើម និងស៊ីស្លឹករុក្ខជាតិជាសារាយតូចៗ ។ល។
- ពេលធំ វាចូលចិត្តស៊ីចំណីច្រើនប្រភេទដូចជា កាកសំណល់បន្លែ ស្លឹករុក្ខជាតិ ចក ត្រកួន កណ្តៀរជាដើម ពិសេសសត្វល្អិតប្លងគុង។
- វាអាចស៊ីចំណីបន្ថែមដូចជា កន្ទក់ ចុងអង្ករ ពោត សណ្តែក កាកសំណល់ផ្ទះបាយជាដើម។



*ត្រីកន្ធរ*

### គ- ត្រីកាបសាមញ្ញ

ជាប្រភេទត្រីក្រៅស្រុក រស់នៅក្នុងតំបន់ទឹកសាប ងាយស្រួលចិញ្ចឹម ព្រោះវាអាចរស់នៅក្នុងមជ្ឈដ្ឋានទឹក

ដែលមានកម្រិតអុកស៊ីសែនទាប កម្រិតជាតិជូរ pH= 5.5 - 8.5 និងអាចរស់នៅក្នុងសីតុណ្ហភាពពី ២០ ទៅ ៣០ អង្សាសេ។ ចូលចិត្តរស់នៅក្នុងស្រទាប់ទឹកបាត (ស្រទាប់ទឹកខាងក្រោម)។ក្រោយរយៈពេលចិញ្ចឹម១ឆ្នាំ ត្រីកាបសាមញ្ញអាចមានទម្ងន់ពី ០.៥ទៅ១គីឡូក្រាម និងអាចបន្តពូជក្នុងស្រះបាន នៅពេលវាមានអាយុចាប់ពី ១០ខែឡើងទៅ បើមានការគ្រប់គ្រងបានល្អ។ត្រីកាបសាមញ្ញជាប្រភេទត្រីធន់នឹងជំងឺ និងអាចចិញ្ចឹមក្នុងស្រះក៏បាន ចិញ្ចឹមក្នុងស្រែក៏បាន។

- ពេលនៅតូច វាស៊ីសត្វល្អិតតូចៗច្រើនប្រភេទ ដូចជា ពពួកសត្វល្អិតប្លុងតុង កណ្ដៀរ កូនជន្លេនជាដើម ។
- ពេលធំ វាចូលចិត្តស៊ីចំណីច្រើនប្រភេទដូចជា សត្វល្អិតប្លុងតុង កណ្ដៀរ ជន្លេន កូនខ្យង កូនខ្ចៅ កូនក្ដាម។
- វាអាចស៊ីចំណីបន្ថែមដូចជា កន្ទក់ ចុងអង្ករ ពោត សណ្ដែកកាកសំណល់ផ្ទះបាយជាដើម។



*ត្រីកាបសាមញ្ញ*

## ឃ- ត្រីកាបឥណ្ឌា (ម្រីហ្គាល់)

ជាប្រភេទត្រីក្រៅស្រុក រស់នៅក្នុងតំបន់ទឹកសាប ងាយស្រួលចិញ្ចឹម ព្រោះវាអាចរស់នៅក្នុងមជ្ឈដ្ឋានទឹកដែលមានកម្រិតជាតិជូរ pH= 5.5- 8.5 និងអាចរស់នៅក្នុងសីតុណ្ហភាពពី២០ទៅ៣០អង្សាសេ។ចូលចិត្តរស់នៅក្នុងស្រទាប់ទឹកបាត (ស្រទាប់ទឹកខាងក្រោម)។ ក្រោយរយៈពេលចិញ្ចឹម ១ឆ្នាំ ត្រីកាបឥណ្ឌា (ម្រីហ្គាល់) អាចមានទម្ងន់ពី ០.៥ ទៅ ០.៧គីឡូក្រាម និងអាចបន្តពូជក្នុងស្រះបាននៅពេលវាមានអាយុចាប់ពី ១៦ខែឡើងទៅ បើមានការគ្រប់គ្រងបានល្អ។ ត្រីកាបឥណ្ឌា (ម្រីហ្គាល់) ជាប្រភេទត្រីធន់នឹងជំងឺ និងអាចចិញ្ចឹមក្នុងស្រះក៏បាន ចិញ្ចឹមក្នុងស្រែក៏បាន។

- ពេលនៅតូច វាស៊ីសត្វល្អិតតូចៗច្រើនប្រភេទ ដូចជា ពពួកសត្វល្អិតប្លុងតុង កណ្ដៀរ កូនជន្លេន ជាដើម ។
- ពេលធំ វាចូលចិត្តស៊ីចំណីច្រើនប្រភេទដូចជា សត្វល្អិតប្លុងតុង កណ្ដៀរ ជន្លេន កូនខ្យង កូនខ្ចៅ កូនក្ដាម ស្លឹករុក្ខជាតិ ចក។
- វាអាចស៊ីចំណីបន្ថែមដូចជា កន្ទក់ ចុងអង្ករ ពោត សណ្ដែក កាកសំណល់ផ្ទះបាយជាដើម។



*ត្រីកាបឥណ្ឌា (ម្រីហ្គាល់)*

## ង- ត្រីទីឡាព្យ៉ា

ជាប្រភេទត្រីក្រៅស្រុក មានប្រភពមកពីប្រទេសអាហ្វ្រិកខាងជើង។ រស់នៅក្នុងតំបន់ទឹកសាប និងអាចរស់នៅក្នុងតំបន់ទឹកភ្លាវ។ ងាយស្រួលចិញ្ចឹម ព្រោះវាអាចរស់នៅក្នុងមជ្ឈដ្ឋាន ទឹកដែលមានកម្រិតអុកស៊ីសែនរលាយតិច (៣មីលីក្រាមក្នុង១លីត្រទឹក) កម្រិតជាតិជូរ pH= 4 - 9 និងអាចរស់នៅក្នុងសីតុណ្ហភាពពី ១៤ ទៅ ៤០អង្សាសេ។ រស់នៅក្នុងគ្រប់ស្រទាប់ទឹក (ស្រទាប់ទឹកខាងលើ កណ្ដាល និងខាងក្រោម)។ ក្រោយរយៈពេលចិញ្ចឹម ៦ខែ ត្រីទីឡាព្យ៉ាអាចមានទម្ងន់ពី ០.១ ទៅ ០.២ គីឡូក្រាម និងអាចបន្តពូជក្នុងស្រះតាមធម្មជាតិបានចំនួនពី ៦ ទៅ ១០ដងក្នុង១ឆ្នាំ បើមានការគ្រប់គ្រងបានល្អ។ ត្រីទីឡាព្យ៉ា ជាប្រភេទត្រីធន់នឹងជំងឺ និងអាចចិញ្ចឹមក្នុងស្រះក៏បាន ចិញ្ចឹមក្នុងស្រែក៏បាន។

- ពេលនៅតូច វាស៊ីសត្វល្អិតតូចៗច្រើនប្រភេទ ដូចជា ពពួកសត្វល្អិតប្លុងតុង កណ្ដៀរ កូនជន្លេន និងស៊ីស្លឹករុក្ខជាតិជាសារាយតូចៗជាដើម ។

- ពេលធំ វាចូលចិត្តស៊ីចំណីច្រើនប្រភេទដូចជា សត្វល្អិតប្លុងគុង កណ្ដៀរ ជន្លេន កូនខ្យង កូនខ្ចៅ កូនក្ដាម ស្លឹករុក្ខជាតិ ចក។
- វាអាចស៊ីចំណីបន្ថែមដូចជា កន្ទក់ ចុងអង្ករ ពោត សណ្ដែក កាកសំណល់ផ្ទះបាយជាដើម។



ត្រីទីឡាព្យ៉ា



## ៨- ការដឹកជញ្ជូនកូនត្រី

### គោលបំណង:

ដើម្បីទទួលបាន

- កូនត្រីមានសុខភាពល្អ អត្រារស់ច្រើន នៅពេលដឹកជញ្ជូន និងក្រោយពេលដាក់កូនត្រីចិញ្ចឹម។
- ចំណេះដឹងបច្ចេកទេសការដឹកជញ្ជូនកូនត្រី។

ការដឹកជញ្ជូនកូនត្រី ត្រូវយកចិត្តទុកដាក់បច្ចេកទេសដូចខាងក្រោម ៖

- មធ្យោបាយដឹកជញ្ជូនកូនត្រីចំងាយផ្លូវជិត ត្រូវមានម៉ូតូ ឬកង់ ឬរ៉ឺកទៅតាមទីតាំងចំងាយផ្លូវដឹកជញ្ជូនកូនត្រី។ ចំពោះចំងាយផ្លូវឆ្ងាយត្រូវមាន ឡាន ឬម៉ូតូ ទៅតាមទីតាំងចំងាយផ្លូវដឹកជញ្ជូន និងបរិមាណកូនត្រីត្រូវដឹកជញ្ជូន។
- សម្ភារដឹកជញ្ជូនកូនត្រីចំងាយផ្លូវជិតត្រូវមាន កញ្ជេរ និងបាវ ឬស្លឹកចេក សម្រាប់ទ្រាប់កញ្ជេរដាក់ចង់កូនត្រី។ ក្នុងករណីដឹកជញ្ជូនកូនត្រីចំងាយផ្លូវជិតៗ អាចប្រើសម្ភារធុងដាក់កូនត្រី និងស្លឹកចេក ឬស្លឹកឈូក សម្រាប់ដាក់ពីលើទឹកក្នុងធុងការពារពេលដឹកកូនត្រីកុំឲ្យទឹកក្រឡុកចេញពីធុង។





មធ្យោបាយដឹកជញ្ជូនកូនត្រីផ្លូវជិត



មធ្យោបាយដឹកជញ្ជូនកូនត្រីផ្លូវឆ្ងាយ

- សម្ភារដឹកជញ្ជូនកូនត្រីចំងាយផ្លូវឆ្ងាយ ត្រូវមានធុងខ្យល់អុកស៊ីសែនសម្រាប់ដូរខ្យល់ ស្បោង ឬថង់ច្រកកូនត្រី និងកៅស៊ូចងថង់ សម្រាប់ផ្លាស់ប្តូរនៅពេលថង់កូនត្រីធ្លាយ ឬរហែក និងគួរមានថង់បាវអង្ករសម្រាប់ច្រកថង់កូនត្រីពីក្រៅ ដើម្បីការពារថង់កូនត្រីធ្លាយ ឬរហែក (រូបភាពខាងក្រោម)។
- ជាទូទៅថង់ច្រកកូនត្រីមានទំហំបណ្តោយ ឬកំពស់ ០.៨ម៉ែត្រ និងទទឹងមាត់ថង់ ០.៦ម៉ែត្រ អាចដាក់កូនត្រីដែលមានទំហំពី ៥ ទៅ ៧ស.ម បានចំនួនពី ១០០ ទៅ ២០០ក្បាល សម្រាប់ដឹកជញ្ជូនផ្លូវឆ្ងាយ។
- ក្នុងករណីដឹកជញ្ជូនកូនត្រីចំងាយផ្លូវឆ្ងាយ អ្នកដឹកជញ្ជូនគួរចេះវិធីចងថង់កូនត្រី តាមរបៀបដូចរូបភាពខាងក្រោម នៅពេលមានថង់កូនត្រីធ្លាយ ឬរហែក។



*របៀបចងវេចខ្ចប់ថង់កូនត្រី ដោយប្រើខ្យល់អុកស៊ីសែន*

- ពេលវេលាដឹកជញ្ជូនកូនត្រី គួរដឹកនៅពេលមេឃ ឬអាកាសធាតុត្រជាក់ ដើម្បីឲ្យកូនត្រីមានសុខភាពល្អ និងដឹកជញ្ជូនបានរយៈពេលយូរ។ ក្នុងករណីដឹកជញ្ជូនកូនត្រីនៅពេលមេឃ ឬអាកាសធាតុក្តៅខ្លាំង ត្រូវរៀបចំមធ្យោបាយដឹកជញ្ជូនឲ្យមានម្លប់ការពារកម្តៅថ្ងៃ និងចៀសវាងការរៀបចំម្លប់គ្របជាទ្រុងជិតខ្យល់ចេញ ចូលតែម្តង ព្រោះនាំឲ្យកម្តៅថ្ងៃកើនឡើងក្នុងទ្រុងនោះ។ បើមានលទ្ធភាពដឹកជញ្ជូនកូនត្រីក្នុងរថយន្តមានម៉ាស៊ីនត្រជាក់គ្រប់គ្រាន់កាន់តែប្រសើរ។
- ក្នុងករណីដឹកជញ្ជូនកូនត្រីទៅផ្លូវឆ្ងាយ ឬដឹកជញ្ជូនកូនត្រីនៅពេលយប់ អ្នកលក់កូនត្រី ឬអ្នកវេចចងថង់កូនត្រី ត្រូវរៀបចំទុកដាក់កូនត្រីឲ្យបានល្អនៅមុនពេល មួយថ្ងៃដឹកជញ្ជូន ដោយត្រូវចាប់កូនត្រីពីស្រះមកប្រោះទុកក្នុងអាងស៊ីម៉ង់ និងត្រូវផ្តល់ចរន្តទឹកចេញ ចូលជាប់រហូត និងកុំផ្តល់ចំណីឲ្យត្រីស៊ី ដើម្បីឲ្យកូនត្រីមានសុខភាពល្អដឹកជញ្ជូនបានរយៈពេលយូរ និងកុំឲ្យកូនត្រីងាប់ច្រើន។

- ទឹកដាក់ក្នុងថង់កូនត្រី ត្រូវមានគុណភាពល្អ ចៀសវាងយកទឹកស្រះដែលល្អក់ពេក ឬទឹកស្រះមានក្លិនស្អុយ ឬយកទឹកអណ្តូងដែលមានកម្រិតខ្យល់អុកស៊ីសែនតិច ឬជាទឹកដែលអាចមានជាតិពុលផ្សេងៗ គួរយកទឹកស្រះមានកម្រិតខ្យល់អុកស៊ីសែនច្រើន ឬជាទឹកដែលគ្មានជាតិពុលមកប្រើច្រកថង់កូនត្រី។
- ក្នុងករណីត្រូវផ្លាស់ប្តូរទឹកថ្មីក្នុងថង់កូនត្រីនៅពេលដឹកជញ្ជូន គួរយកចិត្តទុកដាក់រកប្រភពទឹកដែលប្រាកដថា ល្អគ្មានជាតិពុលដើម្បីឲ្យកូនត្រីដឹកជញ្ជូនមានសុខភាពល្អ ឬនិងអត្រារស់ច្រើន។



*ឡានដឹកកូនត្រីរៀបចំឲ្យមានតែដំបូលគ្របពីលើ ដើម្បីឲ្យមានខ្យល់ចេញ-ចូល*

## ៩- ការដាក់កូនត្រីចិញ្ចឹមក្នុងស្រែ

**គោលបំណង:**

ដើម្បីទទួលបាននូវ

- កូនត្រីមានអត្រារស់ច្រើន ក្រោយពេលដាក់កូនត្រីចិញ្ចឹម។
- កូនត្រីមានសុខភាពល្អ និងការលូតលាស់ល្អ។

ការដាក់កូនត្រីចិញ្ចឹម ត្រូវយកចិត្តទុកដាក់បច្ចេកទេសដូចខាងក្រោម :

- នៅពេលកូនត្រីដឹកជញ្ជូនមកដល់ស្រែ ត្រូវត្រាំថង់កូនត្រីក្នុងទឹកស្រែនោះរយៈពេលពី ៣ ទៅ ៥នាទី រួចស្រាយមាត់ថង់បាចទឹកស្រែបញ្ចូលក្នុងថង់ ដើម្បីធ្វើឲ្យសីតុណ្ហភាពទឹកក្នុងថង់ និងទឹកក្នុងស្រែត្រីមានលំនឹងសីតុណ្ហភាពដូចគ្នាបន្តិចម្តងៗ ទើបអាចចាប់ផ្តើមលែងកូនត្រីចេញពីថង់ដោយសន្សឹមៗ។ ចៀសវាងការចាក់លែងកូនត្រីចេញពីថង់ ឬចេញពីធុងចូលក្នុងស្រែភ្លាមៗតែម្តង ដែលធ្វើឲ្យកូនត្រីងាយនឹងងាប់បានក្រោយពេលលែងចូលស្រែហើយ។

គួរអនុវត្តតាមរូបភាពដូចខាងក្រោម:







- កូនត្រីដាក់ចិញ្ចឹមក្នុងស្រែ គួរមានទំហំ ៥សង់ទីម៉ែត្រ ដើម្បីឲ្យកូនត្រីមានអត្រារស់ច្រើន ក្រោយពេលដាក់កូនត្រីចិញ្ចឹមក្នុងស្រែហើយ។ ត្រូវចៀសវាងដាក់កូនត្រីចិញ្ចឹមមានទំហំតូច ដែលធ្វើឲ្យការចិញ្ចឹមត្រីក្នុងស្រែមិនទទួលបានផលល្អ ព្រោះអាចមានត្រីស្រែចាប់ស៊ីបានយ៉ាងងាយ។
- ការចិញ្ចឹមត្រីក្នុងស្រែ កសិករអាចដាក់កូនត្រីបានតែចំនួនពី១ក្បាល ក្នុង១ម៉ែត្រការេ នៃផ្ទៃស្រែ ទាំងអស់។ ដើម្បីឲ្យការចិញ្ចឹមត្រីក្នុងស្រែទទួលបានផលល្អ និងបរិមាណច្រើន គួរចិញ្ចឹមត្រីក្នុងស្រះភ្ជាប់ទៅនឹងវាលស្រែ និងចាំបាច់ត្រូវផ្តល់ចំណីបន្ថែម។



ទំហំកូនត្រី ៥ ស.ម



- កូនត្រីដាក់ចិញ្ចឹមត្រូវមានសុខភាពល្អ គ្មានជំងឺ គ្មានមេរោគឆ្លង។ ដូចនេះគួរទិញកូនត្រីពីប្រភពដែលយើងត្រូវដឹងច្បាស់លាស់ថាគ្មានមេរោគ និងជំងឺឆ្លងផ្សេងៗ។ ម្យ៉ាងទៀត នៅលើដងខ្លួនត្រីកុំឲ្យមានស្នាមរបួស ឬដំបៅ ដងខ្លួនត្រង់មានពណ៌សម្បុរភ្លឺថ្លា និងមានសកម្មភាពហែលរហ័សរហួន។
- ដើម្បីឲ្យកូនត្រីមានអត្រារស់ច្រើន ក្រោយពេលដាក់កូនត្រីចិញ្ចឹម ត្រូវរៀបចំស្រែឲ្យមានគុណភាពទឹកល្អ មានពណ៌បៃតងខ្ចី និងគ្មានជាតិពុល។
- ម្យ៉ាងទៀត គួរចៀសវាងលែងកូនត្រីនៅពេលមេឃជិតភ្លៀង កំពុងភ្លៀង ក្រោយពេលភ្លៀង ឬលែងនៅពេលយប់ ព្រោះវាគ្មានពន្លឺថ្ងៃធ្វើឲ្យទឹកស្រែងាយខ្វះខ្យល់អុកស៊ីសែន បង្កើនជាតិពុលក្នុងស្រែ និងងាយធ្វើឲ្យកូនត្រីងាប់បាន។

- ចំនួនកូនត្រីដាក់ចិញ្ចឹមក្នុងស្រែ គួរអនុវត្តដូចក្នុងតារាងខាងក្រោម៖

តារាងទី ១៖ បរិមាណកូនត្រីដែលត្រូវដាក់ចិញ្ចឹមតាមប្រភេទត្រីនីមួយៗ (គិតជាភាគរយ)

| ប្រភេទកូនត្រីដាក់ចិញ្ចឹម | ឆ្ពិន | ទីឡាព្យ៉ា | កាបសាមញ្ញ ឬ កាបឥណ្ឌា |
|---|---|---|---|
| ប្រភេទត្រីឆ្ពិន ជាសំខាន់ | ៥០% | ៣០% | ២០% |
| ប្រភេទត្រីទីឡាព្យ៉ា ជាសំខាន់ | ៣០% | ៥០% | ២០% |

## ១០- ប្រភេទចំណីធម្មជាតិសម្រាប់ត្រីចិញ្ចឹមក្នុងស្រែ

### គោលបំណង:

ដើម្បីទទួលបាននូវ

- កសិករបានយល់ដឹងច្បាស់ពីប្រភេទចំណីធម្មជាតិ ដែលមានក្នុងភូមិសម្រាប់ត្រីចិញ្ចឹមក្នុងស្រែ។
- កសិករចំណេញថវិកាមិនទិញចំណីពីផ្សារឲ្យត្រីស៊ី។
- ចំណាយដើមទុនតិច កសិករបានផលត្រីហូប។

ក្រោយពេលដាក់កូនត្រីចិញ្ចឹមក្នុងស្រែ ត្រូវយកចិត្តទុកដាក់ដូចខាងក្រោម :

- ពិនិត្យចំណីធម្មជាតិរបស់ត្រីដែលមានក្នុងស្រែដូចជា សត្វល្អិតប្លង់តុង រុក្ខជាតិប្លង់តុង និងសត្វស្រទាប់បាត ដូចជា ខ្យង ខ្ចៅ ជន្លេន ជាពិសេសស្មៅ និងសត្វល្អិតបំផ្លាញដំណាំស្រូវ។ របៀបពិនិត្យចំណីធម្មជាតិ សត្វល្អិតប្លង់តុង ត្រូវអនុវត្តតាមវិធីដូចក្នុងមេរៀនទី ៦ខាងលើ។
- ក្នុងករណីចំណីធម្មជាតិ ( សត្វល្អិតប្លង់តុង ) ពុំទាន់មាន ឬមានតិចតួចក្នុងស្រែ គួរយកចិត្តទុកដាក់បន្ថែម ជីលាមកសត្វតាមបច្ចេកទេសដូចក្នុងមេរៀនទី ៥ខាងលើ។
- គួរផ្តល់ចំណីបន្ថែមដល់ត្រី នៅពេលសង្កេតឃើញថា ក្នុងស្រែគ្មានស្មៅ និងសត្វល្អិតបំផ្លាញដំណាំស្រូវ។
- ចំណីបន្ថែមដែលគួរដាក់ឲ្យត្រីស៊ីរួមមានដូចជា ជន្លេនដី ជន្លេនទឹក កណ្ដៀរ ចកបាយទា កាកសំណល់បន្លែ កាកសំណល់ផ្ទះបាយ កន្ទក់ ជាដើម។ គួរផ្តល់ចំណីបន្ថែមឲ្យត្រីស៊ី ២ដង ក្នុង ១ថ្ងៃ និងគួរឲ្យត្រីស៊ីនៅពេលថ្ងៃ ងាយស្រួលតាមដានការស៊ីចំណីរបស់ត្រី។



ជន្លេនដី



ជន្លេនក្រហម( ទឹក )



កណ្ដៀរ



ចកបាយទា



កន្ទក់



កាកសំណល់បន្លែ

# ១១- ប្រភេទចំណីផ្សំ

## គោលបំណង៖

ដើម្បីទទួលបាននូវ

- កសិករបានយល់ដឹងច្បាស់ពីប្រភេទចំណីផ្សំ ដែលមានក្នុងភូមិសម្រាប់ត្រីចិញ្ចឹមក្នុងស្រែ។
- របៀបផ្សំចំណីត្រីសម្រាប់ផ្តល់ឲ្យត្រីស៊ី។
- ទិន្នផលត្រីកើនឡើង។

ក្រៅពីចំណីធម្មជាតិ យើងអាចផ្តល់ចំណីផ្សំឲ្យត្រីស៊ីតាមរបៀបដូចខាងក្រោម៖

- ជាទូទៅ ចំណីផ្សំគួររៀបចំឡើងឲ្យមានសារជាតិអាហារប្រូតេអ៊ីនខ្ពស់ដើម្បីផ្តល់ចំណីឲ្យត្រីស៊ីមានសុខភាពល្អ និងត្រីឆាប់លូតលាស់បានរហ័ស។
- ចំណីផ្សំរៀបចំសម្រាប់ផ្តល់ឲ្យត្រីស៊ីបន្ថែមពីលើចំណីធម្មជាតិ ដែលមានស្រាប់ក្នុងស្រែ ដោយប្រើប្រាស់ធាតុផ្សំដែលមានស្រាប់ក្នុងមូលដ្ឋានដូចជា កន្ទក់ ចុងអង្ករ សណ្តែកសៀង កាកសំណល់ត្រីហាល ឬម្សៅត្រី ឬចំណីគ្រាប់លាយផ្សំបញ្ចូលគ្នា រួចចម្អិនតាមរូបមន្តដូចខាងក្រោម៖

សមាសធាតុផ្សំចំណី


ត្រីហាល

ឬ


ឬចំណីគ្រាប់ ២០%

ផ្សំជាមួយ


កន្ទក់ ៦០%

ផ្សំជាមួយ


ចុងអង្ករ ១០%


សណ្តែកសៀង ១០%


យកទៅកូរចម្អិនជាមួយគ្នា


ទទួលបានចំណីផ្សំសម្រេច

រូបមន្តចំណីផ្សំ

ត្រីហាល ឬចំណីគ្រាប់ ២០% + កន្ទក់ ៦០% + ចុងអង្ករ ១០% + សណ្តែកសៀង ១០%

- រូបមន្តផ្សំចំណីនេះ អាចផ្លាស់ប្តូរចំនួនភាគរយនៃសមាសធាតុផ្សំណាមួយក៏បាន អាស្រ័យទៅតាមលទ្ធភាពរបស់កសិករម្នាក់ៗ (ដូចក្នុងតារាងខាងក្រោម)។ ប៉ុន្តែគួររក្សាសមាសធាតុផ្សំចំណីនេះ ឲ្យនៅដដែលជាការល្អ ព្រោះជាសមាសធាតុផ្សំចំណីដែលមានសារជាតិប្រូតេអ៊ីនច្រើន។ ជាទូទៅ សារជាតិប្រូតេអ៊ីនខ្ពស់មាននៅក្នុងសារធាតុផ្សំចំណីម្សៅត្រី និងសណ្តែកសៀង។ ដូចនេះ ដើម្បីបង្កើនសារជាតិអាហារប្រូតេអ៊ីនខ្ពស់គួរបង្កើនបរិមាណចំណីម្សៅត្រី ឬសណ្តែកសៀង។ កសិករគួរបង្កើនបរិមាណចំណីសណ្តែកសៀងជាការល្អ ព្រោះវាមានតម្លៃថោកជាងម្សៅត្រី។

តារាងទី ២៖ សមាសធាតុ និងបរិមាណចំណីដែលត្រូវផ្សំបញ្ចូលគ្នា

| លរ | សមាសធាតុផ្សំចំណី | បរិមាណធាតុផ្សំចំណី (គ.ក្រ ឬ ក្រាម) | | |
|---|---|---|---|---|
| | | គំរូទី ១ | គំរូទី ២ | គំរូទី ៣ |
| ១ | ម្សៅត្រី ឬចំណីគ្រាប់ប្រូតេអ៊ីនខ្ពស់ (៤០%) | ២០ | ២០ | ២០ |
| ២ | សណ្តែកសៀង | ៦០ | ៤០ | ៣០ |
| ៣ | កន្ទក់ | ១០ | ៣០ | ៤០ |
| ៤ | ចុងអង្ករ | ១០ | ១០ | ១០ |
| | សរុបគិតជា (គ.ក្រ ឬ ក្រាម) | ១០០ | ១០០ | ១០០ |

- ចំណីផ្សំដោយចម្អិនជាប្រភេទចំណីស្អិត ដូចនេះគួររៀបចំចំណីស្អិតនេះពូតជាដុំដាក់ក្នុងកញ្ច្រែង ចងព្យួរឲ្យត្រីស៊ី ដូចរូបភាពខាងក្រោម ដើម្បីងាយស្រួលពិនិត្យមើលសកម្មភាពត្រីស៊ីចំណីផង និងដើម្បីត្រួតពិនិត្យមើលបរិមាណចំណី ដែលបានដាក់ឲ្យត្រីស៊ីផង។ ក្នុងករណីត្រីស៊ីចំណីអស់គួរបន្ថែមបរិមាណចំណីឲ្យបានច្រើននៅពេលក្រោយ។
- ចំណីផ្សំគួររៀបចំចម្អិនឲ្យត្រីស៊ីមួយពេល ឬមួយថ្ងៃឲ្យអស់ ចៀសវាងទុកចំណីផ្សំឲ្យត្រីស៊ីនៅពេលក្រោយទៀត ព្រោះចំណីទុកយូរនឹងងាយខូចគុណភាព។



គួរប្រើស៊ុមដាក់ចំណីត្រី

## ១២- របៀបដាក់ជីក្រោយពេលលែងកូនត្រីក្នុងស្រែ

**គោលបំណង៖**

ដើម្បីយល់ដឹងច្បាស់ពី

- ប្រភេទ និងបរិមាណជីដែលត្រូវប្រើ ក្រោយពេលដាក់កូនត្រីចិញ្ចឹម។
- ពេលវេលា និងបច្ចេកទេសនៃការប្រើជី។

- ជាទូទៅ ក្រោយពេលលែងកូនត្រីចូលក្នុងស្រែហើយរយៈពេល ១សប្តាហ៍ បរិមាណចំណីធម្មជាតិ ជាពិសេសសត្វល្អិតប្លងគុងនៅសល់តិចតួច ព្រោះកូនត្រីស៊ី។ ប៉ុន្តែមុនពេលប្រើជីធម្មជាតិលាមកសត្វពីរណ្តៅជីដាក់ចូលក្នុងស្រែ ត្រូវដួសទឹកស្រែមកពិនិត្យមើលតាមវិធីសាស្ត្របានបញ្ជាក់ក្នុងមេរៀនទី ៦ ខាងលើ។
- ដើម្បីដាក់ជីលាមកសត្វបានល្អចូលក្នុងស្រែ គួរដួសទឹកជីលាមកសត្វពីរណ្តៅជី ដែលបានត្រាំទុករយៈពេល ១សប្តាហ៍ ហើយមកបាចចូលក្នុងស្រែឲ្យបានច្រើនកន្លែងនៅតាមប្រឡាយ ឬជម្រកត្រី។ ប៉ុន្តែត្រូវយកចិត្តទុកដាក់អនុវត្តតាមវិធីដូចខាងក្រោម៖
  - ត្រូវបាចទឹកជីនេះក្នុងបរិមាណតិចតួចសិន ចៀសវាងការបាចទឹកជីច្រើនពេកនាំឲ្យកូនត្រីងាប់។ ក្នុងករណីទឹកស្រែមិនទាន់មានពណ៌បៃតង ទើបយើងអាចបាចទឹកជីនេះក្នុងបរិមាណតិចតួចបន្ថែមទៀត។
  - ម្យ៉ាងទៀត ត្រូវបាចទឹកជីនេះនៅពេលមានពន្លឺថ្ងៃគ្រប់គ្រាន់។ ចៀសវាងបាចទឹកជីនៅពេលមេឃជិតភ្លៀង កំពុងភ្លៀង និងក្រោយពេលភ្លៀង ឬបាចទឹកជីនៅពេលយប់ ព្រោះវាគ្មានពន្លឺថ្ងៃគ្រប់គ្រាន់ ធ្វើឲ្យទឹកស្រះងាយខ្វះខ្យល់អុកស៊ីសែន បង្កើនជាតិពុលក្នុងស្រែ និងងាយធ្វើឲ្យកូនត្រីងាប់បាន។
- ជាទូទៅ មុននឹងបាចទឹកជីពីរណ្តៅជីចូលក្នុងស្រែ ត្រូវពិនិត្យគុណភាពទឹកស្រែជាមុនសិនព្រោះវាងាយធ្វើឲ្យកូនត្រីងាប់បាន។ ត្រូវចៀសវាងបង្ហូរទឹកជីនៅពេលទឹកស្រែមានក្លិនស្អុយ ឬទឹកស្រែមានពណ៌បៃតងខ្លាំង។

**ចូរចងចាំថា:** ការដាក់ជីជាប្រចាំដើម្បីឲ្យទឹកស្រែមានពណ៌បៃតងល្អតាមវិធីសាស្ត្រខាងលើ ជាកត្តាសំខាន់ណាស់ធ្វើឲ្យត្រីធំធាត់ល្អ។ ចៀសវាងការប្រើជីធម្មជាតិច្រើន ឬដាក់ជីលាមកសត្វផ្ទាល់ក្នុងស្រែចិញ្ចឹមត្រី និងធ្វើឲ្យទឹកស្រះស្អុយ មានជាតិពុល និងអាចធ្វើឲ្យត្រីងាប់។





## ១៣- ការគ្រប់គ្រងស្រែចិញ្ចឹមត្រី

### គោលបំណង:

ដើម្បីទទួលបាននូវ

- ស្រែមានទឹកគ្រប់គ្រាន់ និងទឹកមានគុណភាពល្អ សម្បូរចំណីធម្មជាតិ។
- ត្រីមានសុខភាពល្អ អត្រារស់បានច្រើន។
- ត្រីលូតលាស់ឆាប់រហ័ស។

ក្នុងរយៈពេលចិញ្ចឹមត្រីក្នុងស្រែ ត្រូវយកចិត្តទុកដាក់សកម្មភាពសំខាន់ៗដូចខាងក្រោម :

- ពិនិត្យកម្ពស់ទឹកក្នុងស្រែ កុំឲ្យស្រកចុះខ្លាំងពេកដែលធ្វើឲ្យសីតុណ្ហភាពទឹក ឬកម្តៅទឹកក្នុងស្រែកើនឡើង និងនាំឲ្យកូនត្រីពិបាកចេញទៅរកចំណីស៊ីក្នុងស្រែបាន។ ម្យ៉ាងទៀត ធ្វើឲ្យការលូតលាស់ត្រី និងដំណាំស្រូវមិនបានល្អ។ បើមានលទ្ធភាពគួររក្សាកម្ពស់ទឹកក្នុងស្រែឲ្យបាន ២០ ទៅ ៣០សង់ទីម៉ែត្រ ដើម្បីឲ្យកូនត្រីបានលូតលាស់ឆាប់រហ័ស។
- ពិនិត្យភ្លឺស្រែឲ្យបានជាប់ជាប្រចាំ ការពារកុំឲ្យភ្លឺស្រែមានកន្លែងធ្លុះធ្លាយ ឬបាក់បែក និងគួរលើកភ្លឺស្រែឲ្យខ្ពស់ និងរឹងមាំល្អ ដើម្បីការពារកុំឲ្យស្រែលិចទឹក កូនត្រីចេញពីស្រែអស់។
- នៅពេលចង់បង្ហូរទឹក ឬបូមទឹកពីខាងក្រៅចូលក្នុងស្រែ គួរតែប្រយ័ត្នពីគុណភាពទឹកមកពីប្រភពខាងក្រៅ កុំឲ្យមានជាតិពុល ឬថ្នាំគីមី ដែលកសិករបានប្រើបាញ់លើដំណាំស្រូវ។
- ចំពោះកសិករដែលមានលទ្ធភាពព័ទ្ធសំណាញ់នៅលើភ្លឺជុំវិញវាលស្រែ ត្រូវឧស្សាហ៍ពិនិត្យមើលសំណាញ់កុំឲ្យមានធ្លុះធ្លាយ ឬរហែក ដើម្បីការពារកុំឲ្យត្រីកាច ឬកង្កែបពីខាងក្រៅលោតចូលក្នុងស្រែស៊ីកូនត្រី។
- គួរឧស្សាហ៍ផ្តល់ចំណីបន្ថែមឲ្យត្រីស៊ី និងផ្លាស់ប្តូរជីលាមកសត្វក្នុងរណ្តៅជី ដើម្បីឲ្យទឹកជីមានគុណភាពល្អ នៅពេលបង្ហូរចូលក្នុងស្រែចិញ្ចឹមត្រី។
- គួរចៀសវាងកុំឲ្យមានសត្វ គោ ក្របី ចុះក្នុងស្រែនាំឲ្យទឹកស្រែល្អក់ ខូចគុណភាពទឹក កុំត្រាំឈើ ឬស្លឹកឈើ និងកុំបោកគក់ខោអាវ ឬលាងសម្ភារកខ្វក់ក្នុងទឹកស្រែចិញ្ចឹមត្រី ដែលងាយធ្វើឲ្យទឹកស្រែពុល ងាប់កូនត្រីបាន។



*រណ្តៅជីត្រូវឧស្សាហ៍ផ្លាស់ប្តូរជីលាមកសត្វចាស់ចេញ*



*ត្រូវឧស្សាហ៍ផ្តល់ចំណីបន្ថែមឲ្យត្រីស៊ី*

## ១៤- កត្តាសំខាន់ៗមួយចំនួនដែលត្រូវយកចិត្តទុកដាក់

**ការចិញ្ចឹមត្រីក្នុងស្រែ កសិករត្រូវយកចិត្តទុកដាក់នូវសកម្មភាពសំខាន់ៗដូចខាងក្រោម:**

- ត្រូវចៀសវាងការដាក់កូនត្រីចិញ្ចឹមមានទំហំតូច ព្រោះក្នុងស្រែមានត្រីកាច និងសត្វកាចផ្សេងទៀត ដូចជា កង្កែប ពស់ ជាដើម។
- ហាមប្រើថ្នាំសម្លាប់សត្វល្អិត ឬលាងសម្ភារ ប្រើប្រាស់ថ្នាំពុលផ្សេងៗក្នុងទឹកស្រែ ព្រោះវាធ្វើឲ្យត្រីងាប់ ។
- បើមានស្រែអ្នកជិតខាងប្រើថ្នាំគីមីសម្លាប់ដង្កូវស៊ីស្រូវ ឬកម្ចាត់ស្មៅក្នុងស្រែ យើងត្រូវប្រយ័ត្នកុំឲ្យទឹកក្នុងស្រែនោះហូរចូលក្នុងស្រែដែលកំពុងចិញ្ចឹមត្រី ដោយត្រូវលើកភ្លឺស្រែឲ្យខ្ពស់ និងរឹងមាំ ដើម្បីកុំឲ្យភ្លឺស្រែធ្លុះធ្លាយ។
- កុំប្រើប្រភពទឹកដែលសង្ស័យថា មិនល្អបញ្ចូលស្រែ ព្រោះវាអាចមានជាតិពុល ដោយការប្រើប្រាស់ថ្នាំគីមី ។
- មិនត្រូវប្រើប្រភេទជីគីមីគ្រាប់ បាចផ្ទាល់ទៅក្នុងស្រែតែម្តងទេ ព្រោះត្រីអាចចាប់យកគ្រាប់ជីទាំងនោះជាចំណីរបស់វា ដែលនឹងធ្វើឲ្យវាងាប់យ៉ាងឆាប់រហ័ស។
- កុំប្រើប្រាស់ជីនៅពេលមេឃជិតភ្លៀង កំពុងភ្លៀង និងក្រោយពេលភ្លៀង។ ម្យ៉ាងទៀត កុំប្រើជីនៅពេលយប់ ឬប្រើនៅពេលមេឃគ្មានពន្លឺថ្ងៃគ្រប់គ្រាន់ ព្រោះវាអាចធ្វើឲ្យកូនត្រីពុលងាប់បាន។
- ពេលស្ទូងស្រូវ កសិករគួរស្ទូងដើមស្រូវឲ្យមានចន្លោះឃ្លាតពីគ្នា ពី ២០ ទៅ ២៥សង់ទីម៉ែត្រ ដើម្បីឲ្យត្រីអាចហែលចេញ ចូលក្នុងដើមស្រូវរកចំណីស៊ីបាន នៅពេលដើមស្រូវដុះរីកបែកគុម្ព។
- កុំចិញ្ចឹមប្រភេទត្រីកាបស៊ីស្មៅនៅក្នុងស្រែ ព្រោះវាអាចស៊ីដើមស្រូវរបស់លោកអ្នក។





សន្ទូង ឬ ការស្ទូងស្រូវត្រូវឃ្លាតពីគ្នា ២០ ទៅ ២៥ សង់ទីម៉ែត្រ

X3 bound
Copy ... 54 ->
20.100+ 1.6k

# ជំពូកទី៣

# បច្ចេកទេសចិញ្ចឹមត្រីអណ្តែងជាលក្ខណៈគ្រួសារ ក្នុងស្រះក្រាលកម្រាលកៅស៊ូប្លាស្ទិក





## ១.ការជ្រើសរើសទីតាំងជីកស្រះចិញ្ចឹមត្រី

**គោលបំណង៖**

ជ្រើសរើសទីតាំងជីកស្រះចិញ្ចឹមត្រីអណ្តែង

* បានត្រឹមត្រូវតាមបច្ចេកទេស ដើម្បីចិញ្ចឹមត្រីទទួលបានជោគជ័យ។
* និងបង្កលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រង។

គួរជ្រើសរើសទីតាំងសម្រាប់ជីកស្រះចិញ្ចឹមត្រី ឲ្យមានលក្ខណៈល្អសមស្របតាមបច្ចេកទេស ឬស្របទៅនឹងលក្ខណៈជីវសាស្ត្រប្រភេទត្រីដែលយើងចង់ចិញ្ចឹម។ ដោយឡែក ចំពោះប្រភេទត្រីអណ្តែង ដើម្បីងាយស្រួលក្នុងការចិញ្ចឹម និងទទួលបានជោគជ័យ យើងគួរតែជ្រើសរើសទីតាំងសម្រាប់ជីកស្រះឲ្យមានលក្ខណៈល្អសមស្របដោយគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោមនេះ :

* នៅជិតផ្ទះងាយស្រួលគ្រប់គ្រងដូចជា ការផ្តល់ចំណី ការគ្រប់គ្រងគុណភាពទឹក និងមើលថែទាំ តាមដានសកម្មភាព និងសុខភាពត្រី ។
* មានទីតាំងស្ថិតនៅទីវាលខ្ពស់ស្រឡះ មិនលិចទឹកនៅរដូវវស្សា ហើយមានខ្យល់ និងពន្លឺអាចចេញ-ចូលបានល្អគ្រប់គ្រាន់ ។
* ជាពិសេសបើអាចធ្វើបាន គួរជ្រើសរើសទីតាំងជីកស្រះនៅជិតប្រភពទឹក ដើម្បីផ្តល់ភាពងាយស្រួលក្នុងការផ្លាស់ប្តូរទឹកថ្មីក្នុងករណីចាំបាច់ ពិសេសនៅពេលត្រីពុល និងមានជំងឺ។ ម្យ៉ាងទៀតក្នុងករណីយើងអាចធ្វើការផ្លាស់ប្តូរទឹកថ្មីបានញឹកញាប់ ជាពិសេសនៅពេលទឹកស្រះមានក្លិនស្អុយ ឬកខ្វក់ នូវកម្រិតបរិមាណទឹកពីមួយភាគបី ( ១/៣ ) ទៅពាក់កណ្តាល ( ៥០% ) នៃបរិមាណទឹកសរុបទាំងអស់ក្នុងស្រះនោះនឹងធ្វើឲ្យត្រីធំធាត់លឿន អាចជៀសផុតពីជំងឺបាន និងទទួលបានទិន្នផលត្រីខ្ពស់។ ប្រភពទឹកទាំងនេះរួមមាន៖ ទន្លេ បឹងបួរ ត្រពាំង ស្រះ ប្រឡាយ និងអណ្តូង ជាដើម ។ល។ ដែលជាប្រភពទឹកស្អាត និងគ្មានជាតិពុល ។



*ទីតាំងដែលមានប្រភពទឹកអាចជីកស្រះចិញ្ចឹមត្រីបាន*



*ជីកស្រះជិតផ្ទះងាយស្រួលគ្រប់គ្រង*

## ២. លក្ខណៈស្រះចិញ្ចឹមត្រី

**គោលបំណង:**

ដើម្បីយល់ច្បាស់ពី

- ទ្រង់ទ្រាយ ឬរូបរាង និងទំហំស្រះ ដែលអាចចិញ្ចឹមត្រីអណ្តែងបាន។
- លក្ខណៈបច្ចេកទេសនៃស្រះចិញ្ចឹមត្រីអណ្តែង។
- ការរៀបចំស្រះចិញ្ចឹមត្រីអណ្តែងឲ្យបានត្រឹមត្រូវតាមបច្ចេកទេស ដើម្បីចិញ្ចឹមត្រីទទួលបានជោគជ័យ។

ជាទូទៅស្រះចិញ្ចឹមត្រីអណ្តែងជាលក្ខណៈគ្រួសារ ដោយក្រាលកម្រាលកៅស៊ូប្លាស្ទិកមានលក្ខណៈដូចខាងក្រោម:

- មានរាងជាចតុកោណកែង ភាគច្រើនមានទំហំតូច អាស្រ័យដោយកសិករម្នាក់ៗដែលមានលទ្ធភាពជីក។ ទំហំស្រះទាំងនោះមានដូចខាងក្រោម៖
  - បណ្តោយ ៦ ម៉ែត្រ ទទឹង ៤ ម៉ែត្រ ជម្រៅ ១ ម៉ែត្រ = ផ្ទៃសរុប ២៤ ម៉ែត្រការេ
  - បណ្តោយ ៦ ម៉ែត្រ ទទឹង ៣ ម៉ែត្រ ជម្រៅ ១ ម៉ែត្រ = ផ្ទៃសរុប ១៨ ម៉ែត្រការេ
  - បណ្តោយ ៤ ម៉ែត្រ ទទឹង ២ ម៉ែត្រ ជម្រៅ ០.៨ ម៉ែត្រ= ផ្ទៃសរុប ៨ ម៉ែត្រការេ
  - បណ្តោយ ៣ ម៉ែត្រ ទទឹង ២ ម៉ែត្រ ជម្រៅ ០.៨ ម៉ែត្រ= ផ្ទៃសរុប ៦ ម៉ែត្រការេ។
- ស្រះចិញ្ចឹមត្រីអណ្តែងជាលក្ខណៈគ្រួសារ ដោយក្រាលកម្រាលកៅស៊ូប្លាស្ទិក មានទំហំប៉ុណ្ណាក៏អាចចិញ្ចឹមត្រីបានដែរ អាស្រ័យទៅតាមលទ្ធភាពរបស់កសិករម្នាក់ៗ។ ជាទូទៅ កសិករជីកស្រះមានទំហំប៉ុនទំហំស្រះខាងលើ ពីព្រោះងាយស្រួលរកទំហំកម្រាលកៅស៊ូប្លាស្ទិកក្រាលពីលើស្រះ។
- ស្រះត្រូវរៀបចំឲ្យមានទំនប់ ឬភ្លឺស្រះ ដើម្បីទប់សង្កត់កម្រាលកៅស៊ូប្លាស្ទិកដែលក្រាលក្នុងបាតស្រះ និងការពារកុំឲ្យទឹកលិចស្រះ នៅពេលមានភ្លៀងធ្លាក់ខ្លាំង។
- បើកសិករមានលទ្ធភាព គួរព័ទ្ធសំណាញ់ជុំវិញស្រះចិញ្ចឹមត្រីកាន់តែប្រសើរ ដើម្បីការពារកុំឲ្យទឹកលិចស្រះនៅពេលមានភ្លៀងធ្លាក់ខ្លាំង។
- ម្យ៉ាងទៀត ត្រូវរៀបចំបង្កប់ទុយោបង្ហូរទឹកសម្រាប់បញ្ចេញបញ្ចូលទឹកពីស្រះ ជាពិសេសការពារទឹកលិចស្រះ នៅពេលមានភ្លៀងធ្លាក់ខ្លាំង។





## ៣. របៀបជីកស្រះចិញ្ចឹមត្រី

**គោលបំណង:**

ដើម្បីយល់ច្បាស់ពី

- របៀបជីកស្រះក្រាលកម្រាលកៅស៊ូប្លាស្ទិក សម្រាប់ចិញ្ចឹមត្រីអណ្តែង ។
- របៀបរៀបចំស្រះចិញ្ចឹមត្រី តាមលក្ខណៈបច្ចេកទេសដើម្បីចិញ្ចឹមត្រីទទួលបានជោគជ័យ។

ស្រះចិញ្ចឹមត្រីអណ្តែងអាចជីកបាន តាមរបៀបដូចខាងក្រោម :

- ដំបូងយើងត្រូវវាស់ប្រវែងបណ្តោយ និងទទឹងស្រះដែលត្រូវជីក ដោយបោះបង្គោលនៅជ្រុងទាំង ៤ នៃស្រះ រួចចងខ្សែព័ទ្ធជុំវិញ។
- បន្ទាប់មក ចាប់ផ្តើមជីកស្រះឲ្យមានជើងទេរ ដើម្បីការពារកុំឲ្យដីបាក់ធ្លាក់ពីជញ្ជាំងស្រះចូលក្នុងបាតស្រះ។
- រួចវាស់ជម្រៅបាតស្រះដែលបានជីក ឲ្យមានជម្រៅដូចនឹងជម្រៅស្រះដែលចង់ជីក។
- បន្ទាប់មកត្រូវរំលីង ឬសម្អាតបាតស្រះ និងជញ្ជាំងស្រះកុំឲ្យមានចំណាំង ឬកម្ទេចឈើ ឬដុំថ្ម ដើម្បីការពារកុំឲ្យធ្លាយរហែកកម្រាលកៅស៊ូប្លាស្ទិក។
- រួចចាប់ផ្តើមក្រាលកម្រាលកៅស៊ូប្លាស្ទិកពីលើស្រះដែលបានជីកហើយ ដោយយកខ្សាច់ មកក្រាលសង្កត់ពីលើជ្រុងទាំង ៤នៃបាតស្រះ ដើម្បីកុំឲ្យកម្រាលកៅស៊ូប្លាស្ទិកប៉ើងពីបាតស្រះនៅពេលបង្ហូរទឹកចូល។ រួចយកអាចម៍ដីមកសង្កត់ពីលើជ្រុងទាំង ៤នៃគែមមាត់ស្រះ ដើម្បីកុំឲ្យកម្រាលកៅស៊ូប្លាស្ទិករបើកចេញ។





*របៀបជីកស្រះ និងរៀបចំស្រះក្រាលកម្រាលកៅស៊ូប្លាស្ទិក*

## ៤. ការរៀបចំស្រះមុនពេលដាក់កូនត្រីចិញ្ចឹម

### គោលបំណង:

ដើម្បីទទួលបាននូវ

- ទឹកក្នុងស្រះមានគុណភាពល្អ មុនពេលដាក់កូនត្រីចិញ្ចឹម។
- កូនត្រីមានអត្រារស់ច្រើន ក្រោយពេលដាក់កូនត្រីចិញ្ចឹម។
- កូនត្រីមានការលូតលាស់ល្អ។

ដើម្បីដាក់កូនត្រីចិញ្ចឹមមានអត្រារស់ច្រើន និងកូនត្រីលូតលាស់ល្អ ចាំបាច់យើងត្រូវរៀបចំស្រះឲ្យបានស្អាតល្អជាមុនសិន។ បច្ចេកទេសនៃការរៀបចំស្រះ គួរអនុវត្តដូចខាងក្រោមនេះ :

- ចំពោះស្រះថ្មី ក្រោយពីជីករួច ត្រូវសម្អាតបាតស្រះ និងជញ្ជាំងស្រះឲ្យបានរលីងស្អាត ដើម្បីកុំឲ្យមានដុំថ្ម អំបែងកែវ មែកឈើ ឬសឈើ ឬដែក ដែលអាចឲ្យមានបញ្ហាដល់ការធ្លុះធ្លាយកម្រាលកៅស៊ូប្លាស្ទិក ក្រោយពេលក្រាល និងបញ្ចូលទឹករួច ។
- ចំពោះស្រះចាស់វិញ ក្រោយពីប្រមូលផលត្រីរួច យើងត្រូវបូមទឹកពង្រីងឲ្យអស់ពីស្រះ រួចត្រូវលាងសម្អាតកម្រាលកៅស៊ូប្លាស្ទិកឲ្យបានស្អាត និងត្រូវពិនិត្យមើលកម្រាលកៅស៊ូប្លាស្ទិក កុំឲ្យមានស្នាមរហែក ឬធ្លាយមុននឹងក្រាលរៀបចំដាក់កូនត្រីចិញ្ចឹមឡើងវិញ។ បន្ទាប់មក ការពារកុំឲ្យមានដុំថ្ម អំបែងកែវ មែកឈើ ឬសឈើ ឬដែក ធ្លាក់ចូលក្នុងបាតស្រះ ដែលអាចធ្វើឲ្យធ្លុះធ្លាយកម្រាលកៅស៊ូប្លាស្ទិក ក្រោយពេលក្រាល និងបញ្ចូលទឹកថ្មីរួច ។
- បន្ទាប់មក ត្រូវរៀបចំភ្លឺស្រះ ដែលមានទទឹងឲ្យបាន០.៥ម៉ែត្រ កម្ពស់ពី ០.២ ទៅ ០.៣ម៉ែត្រ និងមានបណ្តោយជុំវិញស្រះ ដើម្បីការពារកុំឲ្យស្រះលិចទឹក និងត្រីអណ្តែងវារចេញពីស្រះបាន នៅពេលមានភ្លៀងធ្លាក់ ។
- បន្ទាប់ពីបានក្រាលកម្រាលកៅស៊ូប្លាស្ទិករួច យើងគប្បីយកភក់បាតត្រពាំង ឬបឹងមកក្រាលពីលើបាតស្រះឲ្យមានកម្រាស់ប្រហែលពី ០.៥តឹក រួចបន្ថែមលាមកសត្វស្ងួតដូចជា លាមកគោ ក្របី ជ្រូក មាន់ ឬទា បាចពង្រាយនៅបាតស្រះ នូវកម្រិតបរិមាណ ០.៥គីឡូក្រាម ក្នុង ១ម៉ែត្រការេស្រះ រួចបញ្ចូលទឹកនៅដំណាក់កាលដំបូងនេះជម្រៅពី ០.២-០.៤ម៉ែត្រ ហើយត្រាំវាទុកក្នុងរយៈពេលពី ៣ ទៅ ៥ថ្ងៃ ដើម្បីឲ្យលាមកសត្វមានប្រតិកម្មរលាយសព្វ កែប្រែគុណភាពទឹកបានល្អ មានពណ៌ត្រួយចេកខ្ចី ដែលធ្វើឲ្យចំណីធម្មជាតិកើតលូតលាស់មានឡើងច្រើន សម្រាប់កូនត្រីស៊ីបន្ទាប់ពីលែងចូលស្រះដំបូង ។
- បន្ទាប់ពីបានបញ្ចូលទឹករយៈពេលពី ៣ ទៅ ៥ថ្ងៃរួច យើងត្រូវបញ្ចូលទឹកបន្ថែមរហូតដល់ជិតពេញដល់មាត់ស្រះដោយប្រើតម្រងស្បៃច្រោះ រួចយកដើមកំប្លោកមកគ្រាំបណ្តែតលើផ្ទៃទឹកប្រមាណ ១ ភាគ ៣ នៃផ្ទៃទឹកស្រះនោះ សម្រាប់ជាប្រយោជន៍ដល់កូនត្រីចូលជ្រក នៅពេលអាកាសធាតុក្តៅ ជាពិសេសពេលថ្ងៃត្រង់ ។
- បន្ទាប់ពីបានបញ្ចប់នូវរាល់កិច្ចការសំខាន់ៗខាងលើនោះ យើងគួរគប្បីធ្វើរបង ឬរបាំង ដោយប្រើប្រាស់ស្បៃហាប៉ា និងព្រួលឬស្សីព័ទ្ធជុំវិញនៅពីលើភ្លឺស្រះ សម្រាប់ការពារត្រីអណ្តែងវារចេញ និងការពារមាន់ ទា ជ្រូក ឬគោ ក្របី ចូលជាន់កៅស៊ូប្លាស្ទិករហែក ។

- ម្យ៉ាងទៀត កសិករគួររៀបចំជាទ្រៀងដំណាំពីលើស្រះចិញ្ចឹមត្រីប្រមាណពាក់កណ្ដាល នៃផ្ទៃស្រះទាំងមូល ដើម្បីជាប្រយោជន៍កាត់បន្ថយការរំហួតទឹកស្រះ នៅពេលអាកាសធាតុក្ដៅខ្លាំង។ ប៉ុន្តែកុំគប្បីធ្វើទ្រៀងដំណាំគ្របពីលើផ្ទៃស្រះទាំងមូល ព្រោះបាំងពន្លឺថ្ងៃព្រះអាទិត្យ។





## ៥. ការលែងកូនត្រីចូលស្រះចិញ្ចឹម

**គោលបំណង:**

ដើម្បីទទួលបាននូវ

- កូនត្រីមានអត្រារស់ច្រើន ក្រោយពេលដាក់កូនត្រីចិញ្ចឹម។
- កូនត្រីមានសុខភាពល្អ និងការលូតលាស់ល្អ។

បន្ទាប់ពីបានរៀបចំស្រះបានល្អតាមបច្ចេកទេសដូចបានជម្រាបជូនខាងលើ យើងអាចលែងកូនត្រីអណ្ដែងចូលស្រះចិញ្ចឹមបានតាមវិធីដូចខាងក្រោម៖

- ត្រូវត្រាំថង់កូនត្រីនៅក្នុងទឹកស្រះជាមុនសិនរយៈពេលពី ៣ ទៅ ៥នាទី ដើម្បីធ្វើឲ្យសីតុណ្ហភាពទឹកក្នុងស្រះ និងក្នុងថង់មានកម្រិតប្រហាក់ប្រហែលគ្នា។ ម្យ៉ាងទៀត កូនត្រីបានសម្រាកកាត់បន្ថយការនឿយហត់ ក្រោយពេលដឹកជញ្ជូន។
- បន្ទាប់មក យើងអាចលែងកូនត្រីចូលស្រះចិញ្ចឹមបាន ដោយស្រាយមាត់ថង់ បាចទឹកស្រះចូលក្នុងថង់ រួចយកដៃកូរទឹកក្នុងស្រះឲ្យមានកម្ដៅប្រហាក់ប្រហែលគ្នានៅគ្រប់ស្រទាប់ទឹក រួចលែងកូនត្រីចូលស្រះសន្សឹមៗ ។
- យើងគួរលែងកូនត្រីចូលស្រះ នៅពេលអាកាសធាតុត្រជាក់ ជាពិសេសនៅពេលព្រឹកម៉ោង ៨:០០ទៅម៉ោង ១០:០០ ពេលមានពន្លឺព្រះអាទិត្យគ្រប់គ្រាន់ និងនៅពេលរសៀលមេឃត្រជាក់ម៉ោង ៣:០០ ទៅ ម៉ោង ៤:០០ ដែលជាពេលវេលាមានបរិមាណអុកស៊ីសែនរលាយគ្រប់គ្រាន់នៅក្នុងទឹក ។





របៀបលែងកូនត្រី ចូលក្នុងស្រះចិញ្ចឹមត្រី

## ៦. កម្រិតដង់ស៊ីតេ ឬចំនួនកូនត្រីដាក់ចិញ្ចឹម

**គោលបំណង:**

ដើម្បីបានយល់ដឹងច្បាស់អំពី

- បរិមាណ និងទំហំកូនត្រីអណ្តែងសមស្របសម្រាប់ដាក់ចិញ្ចឹម។
- កូនត្រីមានអត្រារស់ច្រើន ក្រោយពេលដាក់កូនត្រីចិញ្ចឹម។
- កូនត្រីមានសុខភាពល្អ និងការលូតលាស់ល្អ។

ចំនួនកូនត្រី ឬដង់ស៊ីតេកូនត្រីដាក់ចិញ្ចឹម វាជាកត្តាសំខាន់ និងកំណត់នៃការលូតលាស់ ធំធាត់ និងអត្រាគង់វង្ស ឬអត្រារស់របស់ត្រី ហើយវាក៏ជាកត្តាមួយបង្កឲ្យកម្រិតកខ្វក់នៃទឹក កើតឡើង ដែលជាបុព្វហេតុបង្កឲ្យត្រីមានជំងឺ។ អាស្រ័យហេតុនេះ យើងគួរដាក់កូនត្រីចូលស្រះចិញ្ចឹមដោយអនុវត្ត តាមបច្ចេកទេសដូចខាងក្រោម៖

- ត្រីអណ្តែងជាប្រភេទត្រីអាចរស់នៅ និងធំធាត់បាននៅក្នុងមជ្ឈដ្ឋានទឹកចង្អៀតដែលមានកម្រិត ឬបរិមាណខ្យល់អុកស៊ីសែនរលាយតិចតួចក្នុងស្រះ។ ដូចនេះ យើងអាចដាក់ចំនួនកូនត្រីចិញ្ចឹមបានច្រើនក្បាលក្នុង ១ម៉ែត្រ នៃផ្ទៃស្រះសរុបបានច្រើនជាងប្រភេទត្រីផ្សេងៗទៀត។ ដង់ស៊ីតេ ឬចំនួនកូនត្រីដាក់ចិញ្ចឹម អាចដាក់បានពី ៤០ ទៅ ៥០ក្បាល ក្នុង ១ម៉ែត្រការេស្រះ ដូចនេះចំពោះស្រះចិញ្ចឹមដែលមានទំហំទទឹង ២ម៉ែត្រ បណ្តោយ ៥ម៉ែត្រ ស្មើ ១០ម៉ែត្រការេ នោះស្មើនឹងចំនួនកូនត្រីត្រូវដាក់ចិញ្ចឹម ៥០០ក្បាល ក្នុងករណីយើងដាក់កូនត្រីចិញ្ចឹមចំនួន ៥០ក្បាល ក្នុង ១ម៉ែត្រការេ។
- ទោះជាយ៉ាងនេះក៏ដោយ ក៏យើងមិនអាចដាក់កូនត្រីអណ្តែងចិញ្ចឹមក្នុងស្រះ ដែលមានទំហំតូចមានចំនួនច្រើនជាងពី ៤០ ទៅ ៥០ក្បាល ក្នុង ១ម៉ែត្រការេស្រះបានទេ ព្រោះវាអាចធ្វើឲ្យកូនត្រីអណ្តែងមិនលូតលាស់បានល្អ ពុលទឹក មិនស៊ីចំណី និងវាអាចងាប់បានឆាប់រហ័ស។ ប៉ុន្តែ កសិករអាចដាក់កូនត្រីអណ្តែងចិញ្ចឹមមានចំនួនតិចជាងនេះកាន់តែប្រសើរ ក្នុងករណីកសិករពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់ចំណីឲ្យត្រីស៊ី និងផ្លាស់ប្តូរទឹកក្នុងរយៈពេលចិញ្ចឹម។
- ចំពោះទំហំកូនត្រីដាក់ចិញ្ចឹម គួរជ្រើសរើសយកកូនត្រីដែលមានទំហំពី ៤ ទៅ ៦សង់ទីម៉ែត្រ ឬមានប្រវែងប្រហែល ៣ថ្នាំងចង្អុលដៃ ដើម្បីឲ្យកូនត្រីមានអត្រារស់បានច្រើន ក្រោយពេលកូនត្រីបានដាក់ចិញ្ចឹមហើយ។
- ម្យ៉ាងទៀត កសិករត្រូវយកចិត្តទុកដាក់ចំពោះពូជកូនត្រីដែលត្រូវទិញមកដាក់ចិញ្ចឹម។ គួរចៀសវាងទិញកូនត្រីពូជពីកន្លែងដែលមានប្រភពពូជមិនល្អ ព្រោះវាអាចងាយនឹងចម្លងជំងឺ ឬត្រីចិញ្ចឹមមិនធំធាត់ និងវាអាចងាប់បានក្នុងរយៈពេលចិញ្ចឹម។

## ៧. ប្រភេទចំណី និងការផ្តល់ចំណី

### គោលបំណង:

ដើម្បីទទួលបាននូវ

- កសិករបានយល់ដឹងច្បាស់ពីប្រភេទចំណីដែលមានក្នុងធម្មជាតិ និងចំណីផ្សំ សម្រាប់ត្រីអណ្តែងទៅតាមទំហំ ឬការលូតលាស់របស់កូនត្រីអណ្តែង និងរបៀបផ្តល់ចំណី។

ប្រភេទចំណី:

នៅក្នុងធម្មជាតិ កូនត្រីអណ្តែងក្រោយពេលញាស់រយៈពេលបីថ្ងៃវាបានប្រើប្រាស់អស់អាហារបម្រុងនោះវានឹងចាប់ផ្តើមស្វែងរកចំណីអាហារនៅខាងក្រៅ ។ ចំណីអាហារនៅខាងក្រៅក្នុងធម្មជាតិដែលវាចូលចិត្តស៊ីរួមមាន ចៃទឹក ប្រភេទកូនសត្វល្អិតៗក្នុងទឹកដទៃទៀតដូចជាដាប់ញ៉ា ម៉ូយណា គូបប៉េប៉ូដា ជន្លេនក្រហម និងពពួកសត្វល្អិតផ្សេងៗទៀតដែលរស់នៅបាតស្រះ។ នៅពេលវាធំពេញវ័យ ចូលចិត្តស៊ីចំណីចម្រុះ ហើយស៊ីសាច់ជាអាហារសំខាន់។

ដោយឡែក ចំពោះចំណីផ្សំសម្រាប់ត្រីអណ្តែងចិញ្ចឹម អាចផ្សំពីរុក្ខជាតិរួមមានច្រើនប្រភេទដូចជា ត្រកួន ពោតស្លឹកដំឡូងផ្វា សណ្តែកសៀង និងសមាសធាតុផ្សំផ្សេងៗទៀតដូចជា កន្ទក់ ចុងអង្ករ កាកសំណល់ផ្ទះបាយ លាយផ្សំជាមួយម្សៅត្រី ឬត្រីជី ។ល។ រាល់សមាសធាតុចំណីទាំងនេះ យើងអាចលាយផ្សំបញ្ចូលគ្នា រួចចម្អិនឲ្យឆ្អិនទុកឲ្យត្រជាក់មុនពេលដាក់ឲ្យត្រីស៊ី ។

ចំពោះចំណីប្រូតេអ៊ីនពីជាតិសាច់រួមមានដូចជា ពោះវៀនមាន់ ពោះវៀនត្រី កណ្តៀរ អង្រ្កង ជន្លេន កាកសំណល់ទីសត្តឃាត និងចំណីគ្រាប់ ។ល។



ជន្លេនដី



ជន្លេនទឹកក្រហម



កណ្តៀរ



កាកសំណល់ត្រីហាល



ចំណីគ្រាប់

ការផ្តល់ចំណី:

ដើម្បីថែរក្សាសុខភាពកូនត្រីឲ្យបានល្អ យើងមិនត្រូវផ្តល់ចំណីឲ្យកូនត្រីស៊ីភ្លាមៗ ទេបន្ទាប់ពីដឹកជញ្ជូននិងលែងកូនត្រីចូលស្រះដាក់ចិញ្ចឹម។ យើងអាចផ្តល់ចំណីឲ្យវាស៊ីបាន នៅពេលបន្ទាប់ពីលែងកូនត្រីចូលស្រះចូលស្រះរយៈពេលពី ២-៣ម៉ោង នូវបរិមាណចំណីតិចតួចបំផុត ។

- នៅថ្ងៃបន្ទាប់យើងអាចចាប់ផ្តើមដាក់ចំណីឲ្យកូនត្រីស៊ីតាមបច្ចេកទេសធម្មតាបាន នូវបរិមាណចំណីពី ៣-៥ភាគរយ ធៀបទៅនឹងទម្ងន់ដងខ្លួនត្រីសរុបទាំងអស់នៅក្នុងស្រះ ដោយផ្តល់ឲ្យវាស៊ីចំនួនពី ២ ទៅ ៣ដង ក្នុង ១ថ្ងៃ នៅពេលព្រឹកម៉ោង ៨:០០ និងរសៀលម៉ោង ៤:០០ ។
- ត្រូវផ្តល់ចំណីឲ្យត្រីស៊ីបានគ្រប់គ្រាន់ និងទៀងទាត់ពេលវេលា។
- គួរបង្ហាត់ត្រីឲ្យចេះស៊ីចំណី ដោយគោះ ឬកូរទឹកធ្វើជាសញ្ញាឲ្យត្រីចំណាំឡើងមករកចំណី។
- គួរដាក់ចំណីឲ្យត្រីស៊ីបានច្រើនកន្លែង ឬច្រើនទីតាំងនៅក្នុងស្រះតែមួយ ដើម្បីឲ្យត្រីបានស៊ីឆ្អែតគ្រប់ៗគ្នា។ គួរចៀសវាងការផ្តល់ចំណីឲ្យត្រីអណ្តែងស៊ីមិនគ្រប់គ្រាន់ នាំឲ្យវាអាចស៊ីគ្នាវា ត្រីកើតជំងឺ និងកូនត្រីមានអត្រារស់តិច ។



## ៨. ការតាមដាន និងគ្រប់គ្រងស្រះចិញ្ចឹមត្រី

- ក្នុងរយៈពេលចិញ្ចឹមត្រី ចាំបាច់ត្រូវយកចិត្តទុកដាក់តាមដាន និងអនុវត្តនូវរាល់សកម្មភាពសំខាន់ៗមួយចំនួនដូចខាងក្រោម ដើម្បីធានាឲ្យការចិញ្ចឹមត្រីទទួលបានជោគជ័យ។
- ត្រូវឧស្សាហ៍ត្រួតពិនិត្យមើលគុណភាពទឹកក្នុងស្រះចិញ្ចឹមត្រី។ ក្នុងករណីទឹកក្នុងស្រះមានពណ៌បៃតងខ្លាំង ឬមានពណ៌ខ្មៅ ឬមានក្លិនស្អុយ ត្រូវផ្លាស់ប្តូរទឹកកខ្វក់នេះចេញប្រមាណពី ៣០ ទៅ ៥០ភាគរយ នៃបរិមាណទឹកស្រះសរុប ទៅតាមលទ្ធភាពរបស់កសិករម្នាក់ៗ ដោយបូមយកទឹកកខ្វក់នេះពីបាតស្រះចេញ។
- ជាទូទៅ ក្រោយពីដាក់កូនត្រីចិញ្ចឹមបានរយៈពេល ១ខែ កសិករគួរយកចិត្តទុកដាក់ធ្វើការផ្លាស់ប្តូរទឹកកខ្វក់ពីក្នុងស្រះចេញ ដើម្បីឲ្យកូនត្រីមានការលូតលាស់លឿន និងមានសុខភាពល្អ។ ត្រូវប្រាកដថា ទឹកផ្លាស់ប្តូរថ្មីនេះ ជាប្រភពទឹកស្អាតល្អ គ្មានជាតិពុល។
- យកចិត្តទុកដាក់ពិនិត្យសកម្មភាពត្រីស៊ីចំណីរៀងរាល់ថ្ងៃ។ ក្នុងករណីត្រីឈប់ស៊ីចំណី ត្រូវឈប់ផ្តល់ចំណីឲ្យត្រីស៊ី។ ក្នុងករណីពិនិត្យឃើញថា មានកាកសំណល់ចំណីនៅសល់ច្រើនធ្លាក់ក្នុងបាតស្រះ ត្រូវប្រញាប់បូមយកកាកសំណល់ចំណីនេះចេញ ដើម្បីកុំឲ្យទឹកស្រះឆាប់កខ្វក់ មានក្លិនស្អុយ ត្រីងាយកើតជំងឺ និងខាតបង់ថវិកាទិញចំណីឲ្យត្រីស៊ី។
- ត្រូវការពារកុំឲ្យមានសត្វគោ ក្របី ជ្រូក ឬក្មេងចុះក្នុងស្រះចិញ្ចឹមត្រី ដើម្បីកុំឲ្យកម្រាលកៅស៊ូប្លាស្ទិកធ្លុះធ្លាយ រហែក។
- ត្រូវការពារកុំឲ្យដើមកំប្លោកដុះច្រើនក្នុងស្រះលើសពី ១ភាគ៣ នៃផ្ទៃស្រះទាំងមូល។



## ៩. វិធីការពារជំងឺ

ទប់ស្កាត់ជំងឺ គឺជាប្រការមួយដ៏ប្រសើរបំផុត ដូចពាក្យចាស់បានពោលថា « ការការពារវាប្រសើរជាងការព្យាបាល »។ អាស្រ័យហេតុនេះ ដើម្បីការពារជាមុន និងចៀសវាងបានពីបញ្ហាដែលបង្កឲ្យត្រីមានជំងឺនោះ យើងត្រូវធ្វើការមើលថែទាំ និងតាមដានសកម្មភាពត្រីជាប្រចាំ។ ចំណុចសំខាន់ៗជាគន្លឹះមួយចំនួន ដែលយើងត្រូវតែអនុវត្តធ្វើតាមដូចបានបង្ហាញជូនខាងក្រោមនេះ:

- ជាពិសេស នៅពេលផ្តល់ចំណីត្រីម្តងៗ យើងត្រូវចៀសវាងកុំឲ្យចំណីសល់ច្រើននៅបាតស្រះ ដែលបង្កឲ្យទឹកស្រះខូចគុណភាព ទៅជាស្អុយ ហើយបង្កបញ្ហាឲ្យត្រីកើតជំងឺបាន។ ម៉្យាងទៀត ក៏យើងត្រូវចៀសវាងផងដែរ ការផ្តល់ចំណីដល់ត្រីស៊ីមិនគ្រប់គ្រាន់ នោះនឹងធ្វើឲ្យត្រីខ្វះចំណី ដែលបណ្តាលឲ្យត្រីចឹក ឬស៊ី គ្នាវាបង្កស្នាមរបួស ដំបៅ ហើយបណ្តាលឲ្យត្រីកើតជំងឺ ។
- ត្រូវតាមដាន និងគ្រប់គ្រងគុណភាពទឹកស្រះជាប្រចាំ ដើម្បីធានាឲ្យបានគុណភាពទឹកល្អជានិច្ច។
- ត្រូវតាមដាន និងការពារកុំឲ្យមានកាកសំណល់ទឹកមិនល្អហូរចូលស្រះ។
- គួរប្រើទឹកមេបំបែ ឬអ៊ីអឹម ផ្សំពីផ្លែឈើលាយបាចចូលស្រះត្រីនូវកម្រិតបរិមាណ ១០មីលីលីត្រ ក្នុង ១ ម៉ែត្រគូបទឹក ដើម្បីកែប្រែគុណភាពទឹក និងជួយសម្លាប់ពពួកបាក់តេរីចង្រៃពីក្នុងទឹកស្រះ បន្ថយជាតិស្អុយនៃទឹកក្នុងស្រះចិញ្ចឹមត្រី ។
- ត្រូវត្រួតពិនិត្យផងដែរ គុណភាពកូនត្រីពូជ ( សុខភាពកូនត្រីល្អ គ្មានស្នាមរបួស និងស្គាល់ប្រភពកូនត្រីនោះពិតប្រាកដ ) មុនពេលលែងចូលស្រះចិញ្ចឹម ។ ត្រូវយកចិត្តទុកដាក់ចំណុចសំខាន់ៗមួយចំនួនផ្សេងទៀត ដូចបានបង្ហាញជូនស្រាប់នៅក្នុងចំណុចមេរៀនទី ៨ អំពីការតាមដាន និងគ្រប់គ្រងស្រះចិញ្ចឹមត្រី





*ការរៀបចំដាក់មេអ៊ីអឹមសម្អាតគុណភាពទឹកស្រះ និងសម្លាប់មេរោគ*

## ១០. ការប្រមូលផល

### ១០-១. ការប្រមូលផលរំលស់

ជាទូទៅ ការចិញ្ចឹមត្រីអណ្ដែងនៅក្នុងស្រះក្រាលកម្រាលកៅស៊ូប្លាស្ទិកនៅក្នុងប្រទេសកម្ពុជាយើង នាពេលបច្ចុប្បន្ននេះកសិករចិញ្ចឹមតែក្នុងរយៈពេលខ្លីពី ២ ទៅ ៤ខែប៉ុណ្ណោះនឹងត្រូវប្រមូលផលត្រីយកទៅលក់នៅទីផ្សារ និងប្រើប្រាស់សម្រាប់ការហូបចុកក្នុងគ្រួសារ ។

ចំពោះការប្រមូលផលរំលស់ គឺគួរចាប់ផ្ដើមដំណើរការបន្ទាប់ពីបានចិញ្ចឹមរយៈពេលពី ២ ទៅ ៣ខែជាបណ្ដើរៗ ដោយចាប់រំលស់យកចេញនូវរាល់ត្រីណាដែលមានទំហំធំជាងគេ សម្រាប់ហូបក្នុងគ្រួសារ និងលក់ទៅទីផ្សារ ហើយរក្សាទុកចិញ្ចឹមបន្តត្រីដែលមានទំហំតូចៗ ដើម្បីឲ្យមានការលូតលាស់ ធំធាត់លឿនជាងមុន ខណៈពេលដែលទីធ្លាក្នុងទឹកស្រះចិញ្ចឹមមានលក្ខណៈទូលាយជាងមុន ។

### ១០-២. ការប្រមូលផលសរុប

ចំពោះការប្រមូលផលសរុប យើងគួរចាប់ផ្ដើមដំណើរការចិញ្ចឹមរយៈពេលពី ៣ ទៅ ៤ខែ ដែលខណៈពេលនោះ ត្រីមានទំហំកាន់តែធំ ជាមធ្យមទម្ងន់ចាប់ពី ២០០ក្រាម ទៅ ៣០០ក្រាម ក្នុងមួយក្បាល អាចយកទៅលក់លើទីផ្សារបាន ហើយមានតម្លៃសេដ្ឋកិច្ចខ្ពស់ ។ ការប្រមូលផលសរុបនេះ ដើម្បីទទួលបាននូវអត្ថប្រយោជន៍ និងកម្រៃច្រើននោះ យើងគួរធ្វើឡើងនៅពេល :

- ត្រីចិញ្ចឹមបានរយៈពេលពី ២ ទៅ ៤ខែ
- ត្រីទម្ងន់ចាប់ពី ១០០ ទៅ ៣០០ក្រាម ក្នុង ១ក្បាល
- ប្រមូលផលត្រីនៅរដូវខ្សត់ត្រី ឬបិទនេសាទ ឬរដូវប្រាំងខ្សត់ត្រី ករណីនៅតាមជនបទឆ្ងាយពីដែននេសាទត្រីធម្មជាតិ។ ជាពិសេស នៅពេលដែលតម្លៃត្រីនៅលើទីផ្សារឡើងដល់កម្រិតខ្ពស់ ។



*ការប្រមូលផលត្រីអណ្ដែងសរុប*

## ១១. ការកត់ត្រាទិន្នន័យ

កសិករ វារីវប្បករ ឬអ្នកចិញ្ចឹមត្រីទាំងអស់ ពិសេសកសិករចិញ្ចឹមត្រីអណ្តែង គួរគប្បីឧស្សាហ៍ព្យាយាមក្នុងការតាមដាន មើលថែទាំ គ្រប់គ្រងសកម្មភាពចិញ្ចឹមត្រី និងកត់ត្រាទិន្នន័យជាប្រចាំ ដើម្បីជាប្រយោជន៍ដ៏មានសារៈសំខាន់សម្រាប់យើងទាំងអស់គ្នា ពីព្រោះថាវានឹងធ្វើឲ្យយើងមានការចងចាំនូវអ្វីដែលយើងបានធ្វើ និងបានអនុវត្តនៅក្នុងសកម្មភាពចិញ្ចឹមត្រី ជាពិសេសការចំណាយ- ចំណូល ដែលទាំងនេះធ្វើឲ្យយើងទទួលបាននូវបទពិសោធន៍ដ៏ល្អៗសម្រាប់កែលំអឲ្យប្រសើរឡើងថែមទៀត នៅពេលចិញ្ចឹមត្រីលើកក្រោយៗទៀត ដើម្បីទទួលបានទិន្នផលត្រីកាន់តែខ្ពស់ ។

### តារាងគំរូសម្រាប់កត់ត្រាទិន្នន័យ

១. ការទិញកូនត្រីដាក់ចិញ្ចឹម

ប្រភពកូនត្រីពូជ :

ក្នុងមូលដ្ឋាន □ ក្រៅមូលដ្ឋាន □ ឃុំ ......................... ស្រុក ............... ខេត្ត ..............................

ក្រៅស្រុក □ ប្រទេស : ..............................................................................................................

តារាងទី ០១ : ការទិញកូនត្រីដាក់ចិញ្ចឹម

| ល.រ | ថ្ងៃ ខែ ឆ្នាំ ទិញកូនត្រី | ប្រភេទកូនត្រី | ចំនួនកូនត្រី ( ក្បាល ) | ទំហំកូនត្រី ( ស.ម ) | តម្លៃកូនត្រី ( ៛/ក្បាល ) | តម្លៃសរុប ( ៛ ) |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| | សរុប | | | | | |

២. ការចំណាយ ក្នុងការចិញ្ចឹមត្រី

តារាងទី ០២ : ការចំណាយក្នុងការចិញ្ចឹមត្រី

| ល.រ | ថ្ងៃ ខែ ឆ្នាំ បានចំណាយប្រាក់ | មុខចំណាយ | ឯកត្តា | តម្លៃរាយ ( ៛ ) | តម្លៃសរុប ( ៛ ) |
|---|---|---|---|---|---|
| ១ | | កូនត្រីពូជ | ក្បាល | | |
| ២ | | ថ្លៃដឹកជញ្ជូនកូនត្រី | | | |
| ៣ | | សាំងបូមទឹករៀបចំស្រះ | លីត្រ | | |
| ៤ | | កម្រាលកៅស៊ូប្លាស្ទិក | ម៉ែត្រ | | |
| ៥ | | ស្បៃហាប៉ាសម្រាប់ធ្វើរបាំង | ម៉ែត្រ | | |
| ៦ | | ចំណី ( ករណីទិញ ) | គ.ក្រ | | |
| ៧ | | ចំណាយផ្សេងៗ | | | |
| | សរុប | | | | |

### ៣. ការប្រមូលផលត្រីសរុប

តារាងទី ០៣ : ការប្រមូលផលត្រី

| ថ្ងៃ ខែ ឆ្នាំ | ប្រភេទត្រី | ទម្ងន់ត្រីជាមធ្យម ( ក្រាម/ក្បាល ) | ទម្ងន់ត្រីសរុប ( គ.ក្រ ) | តម្លៃរាយ ( រ ) | តម្លៃសរុប ( រ ) |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | សរុប | | | | |

### ៤. ការចំណូល ក្នុងការចិញ្ចឹមត្រី

តារាងទី ០៤ : ប្រាក់ចំណូលបានពីការចិញ្ចឹមត្រី

| ល.រ | ថ្ងៃ ខែ ឆ្នាំ | មុខចំណូល | ឯកត្តា | តម្លៃរាយ ( រ ) | តម្លៃសរុប ( រ ) |
|---|---|---|---|---|---|
| ១ | | ត្រីបានចាប់ហូបក្នុងគ្រួសារ | គ.ក្រ | | |
| ២ | | ត្រីបានចាប់លក់ | គ.ក្រ | | |
| ៣ | | ត្រីបានចាប់ចែកជូនអ្នកជិតខាង | គ.ក្រ | | |
| សរុប | | | | | |





# ឯកសារយោង


- អ៊ូច ឡង់ ១៩៩៥ បច្ចេកទេសផលិតកូនត្រីពូជ អណ្តែងកូនកាត់ (សារណាបទបញ្ចប់ការសិក្សាថ្នាក់ បរិញ្ញាប័ត្រ) មហាវិទ្យាល័យវារីវប្បកម្ម នៃសាកលវិទ្យាល័យផលផលញ៉ាត្រាងទីក្រុងញ៉ាត្រាង ប្រទេសវៀតណាម។
- អ៊ូច ឡង់ ២០០៥ មេរៀនទ្រឹស្តី ស្តីពី បច្ចេកទេសចិញ្ចឹមត្រីអណ្តែងកូនកាត់ជាលក្ខណៈគ្រួសារ
- សៀវភៅបច្ចេកទេសស្តីពី សារប្រយោជន៍នៃសត្វប្លងតុងសម្រាប់ការបំប៉នកូនត្រី ២០០៩ (FAIEX 1)-JICA
- សៀវភៅផ្សព្វផ្សាយបច្ចេកទេសផលិតកូនត្រីពូជនៅទីជនបទប្រទេសកម្ពុជា ២០១២ (FAIEX 1)-JICA
- **OUCH Lang**, 2008. Technical Information of Hybrid Catfish culture has been using in Cambodia, Phnom Penh, Cambodia.
- **Bach Thi Quynh Mai, 1994. Ky Thuat nuoi ca tre vang lai, Nha Xuat Ban Nong Nghiep, Vietnam**
- **Ngo Trong Lu & Le Dang Khuyen, 2006. Ky Thuat nuoi ca tre, luon, giun dat, Nha Xuat Ban Nong Nghiep, Ha Noi, Vietnam Nguyen Duy Khoat, 2005. Ky Thuat nuoi ca tre lai, ech dong, ba ba, Nha Xuat Ban Nong Nghiep, Ha Noi, Vietnam**
- **A Hatchery Manual for common, chirese and Indian major carps-1985 V.G. Jhingoan and R.S.V. Pullin**

# ជំពូកទី៤
# ការកត់ត្រាទិន្នន័យ និងវិភាគព័ត៌មាន

# តារាងប្រមូលទិន្នន័យប្រចាំខែ របស់កសិករចិញ្ចឹមត្រីម្នាក់ៗ ឆ្នាំ........

ឈ្មោះកសិករ........................................ ភេទ...................... អាយុ.......................ឆ្នាំ

ឈ្មោះប្តី/ ប្រពន្ធ........................................

ចំនួនសមាជិកក្នុងគ្រួសារ........................... កូនប្រុស.................. កូនស្រី.....................

ភូមិ................................................... ឃុំ.......................... ស្រុក........................ ខេត្ត.......................

| ល.រ | សកម្មភាពអនុវត្ត | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ចំនួនស្រះ | | | | | | | | | | | | |
| ២ | ទំហំស្រះសរុប (ម២) | | | | | | | | | | | | |
| ៣ | ទំហំស្រះជាប់ស្រែ (ម២) | | | | | | | | | | | | |
| | (១) ទំហំប្រឡាយក្នុងស្រែ (ម២) | | | | | | | | | | | | |
| | (២) ទំហំស្រះក្នុងស្រែ (ម២) | | | | | | | | | | | | |
| ៤ | ការរៀបចំស្រះ | | | | | | | | | | | | |
| | (១) ចំណុះប្រេងបូមទឹក (លីត្រ) | | | | | | | | | | | | |
| | (២) បរិមាណកំបោរ (គ.ក្រ) | | | | | | | | | | | | |
| | (៣) បរិ.លាមកគោ (គ.ក្រ) | | | | | | | | | | | | |
| | (៤) បរិ.លាមកជ្រូក (គ.ក្រ) | | | | | | | | | | | | |
| | (៥) បរិ.ជីកំប៉ុស្ត (គ.ក្រ) | | | | | | | | | | | | |
| | (៦) បរិ.ជីបៃតង (គ.ក្រ) | | | | | | | | | | | | |
| | (៧) បរិ.ជីអ៊ុយរ៉េ (គ.ក្រ) | | | | | | | | | | | | |
| | (៨) បរិ.ជីដេអាប៉េ (គ.ក្រ) | | | | | | | | | | | | |
| | (៩) ផ្សេងៗ | | | | | | | | | | | | |
| ៥ | ថ្ងៃ ខែ ឆ្នាំ ដាក់កូនត្រីចិញ្ចឹម | | | | | | | | | | | | |
| | (១) ត្រី ឆ្ពិន | | | | | | | | | | | | |
| | (២) ត្រី ទីឡាព្យ៉ា | | | | | | | | | | | | |
| | (៣) ត្រី កាបសាមញ្ញ | | | | | | | | | | | | |
| | (៤) ត្រី កាបឥណ្ឌា | | | | | | | | | | | | |
| | (៥) ត្រី កាបស | | | | | | | | | | | | |
| | (៦) ត្រី ប្រា | | | | | | | | | | | | |
| | (៧) ត្រី អណ្តែង | | | | | | | | | | | | |
| | (៨) ផ្សេងៗ | | | | | | | | | | | | |
| ៦ | ទំហំកូនត្រីដាក់ចិញ្ចឹម (គិតជា ស.ម ឬគិតជា ក្រាម)/ក្បាល | | | | | | | | | | | | |
| | (១) ត្រី ឆ្ពិន | | | | | | | | | | | | |
| | (២) ត្រី ទីឡាព្យ៉ា | | | | | | | | | | | | |
| | (៣) ត្រី កាបសាមញ្ញ | | | | | | | | | | | | |
| | (៤) ត្រី កាបឥណ្ឌា | | | | | | | | | | | | |
| | (៥) ត្រី កាបស | | | | | | | | | | | | |
| | (៦) ត្រី ប្រា | | | | | | | | | | | | |
| | (៧) ត្រី អណ្តែង | | | | | | | | | | | | |
| | (៨) ផ្សេងៗ | | | | | | | | | | | | |
| ៧ | បរិមាណជីប្រើក្រោយដាក់កូនត្រីចិញ្ចឹម (គ.ក្រ) | | | | | | | | | | | | |

| លរ | សកម្មភាពអនុវត្ត | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | (១) បរិ.លាមកគោ | | | | | | | | | | | | |
| | (២) បរិ.លាមកជ្រូក | | | | | | | | | | | | |
| | (៣) បរិ.ជីកំប៉ុស្ត | | | | | | | | | | | | |
| | (៤) បរិ.ជីបៃតង | | | | | | | | | | | | |
| | (៥) បរិ.ជីអ៊ុយរ៉េ | | | | | | | | | | | | |
| | (៦) បរិ.ជីដេអាប៉េ | | | | | | | | | | | | |
| | (៧) ផ្សេងៗ | | | | | | | | | | | | |
| ៨ | បរិមាណចំណីប្រើក្រោយដាក់កូនត្រីចិញ្ចឹម (គក្រ) | | | | | | | | | | | | |
| | (១) បរិ.កន្ទក់ | | | | | | | | | | | | |
| | (២) បរិ.ចំណីគ្រាប់ | | | | | | | | | | | | |
| | (៣) បរិ.ចំណីចំអិន | | | | | | | | | | | | |
| | (៤) បរិ.កណ្ដៀរ | | | | | | | | | | | | |
| | (៥) បរិ.ចក | | | | | | | | | | | | |
| | (៦) បរិ.ជន្លេន | | | | | | | | | | | | |
| | (៧) បរិ.កាកសំណល់បន្លែ | | | | | | | | | | | | |
| | (៨) បរិ.កាកសំណល់ផ្ទះបាយ | | | | | | | | | | | | |
| | (៩) ផ្សេងៗ | | | | | | | | | | | | |
| ៩ | កម្រិតកម្ពស់ទឹកក្នុងស្រះ (ម៉ែត្រ) | | | | | | | | | | | | |
| ១០ | ចំនួនដងបូមទឹកបញ្ចូលក្នុងស្រះ | | | | | | | | | | | | |
| ១១ | ចំណុះទឹកបូមបញ្ចូលក្នុងស្រះ (ម៉ែត្រ) | | | | | | | | | | | | |
| ១២ | កម្រិតគុណភាពទឹកស្រះ | | | | | | | | | | | | |
| | (១) បៃតងថ្លា | | | | | | | | | | | | |
| | (២) បៃតងចាស់ | | | | | | | | | | | | |
| | (៣) ល្អក់តិចតួច | | | | | | | | | | | | |
| | (៤) ល្អក់ខ្លាំង | | | | | | | | | | | | |
| ១៣ | បញ្ហាជួបប្រទះ | | | | | | | | | | | | |
| ១៤ | ដំណោះស្រាយបញ្ហា | | | | | | | | | | | | |
| ១៥ | អ្នកមើលថែទាំស្រះចិញ្ចឹមត្រី | | | | | | | | | | | | |
| | (១) ប្ដី | | | | | | | | | | | | |
| | (២) ប្រពន្ធ | | | | | | | | | | | | |
| | (៣) កូន | | | | | | | | | | | | |
| | (៤) អ្នកដទៃ | | | | | | | | | | | | |
| ១៧ | ទម្ងន់ត្រីប្រមូលផលសរុប (គ.ក្រ) | | | | | | | | | | | | |
| | (១) ត្រី ឆ្ពិន | | | | | | | | | | | | |
| | (២) ត្រី ទីឡាព្យ៉ា | | | | | | | | | | | | |
| | (៣) ត្រី កាបសាមញ្ញ | | | | | | | | | | | | |
| | (៤) ត្រី កាបឥណ្ឌា | | | | | | | | | | | | |
| | (៥) ត្រី កាបស | | | | | | | | | | | | |
| | (៦) ត្រី ប្រា | | | | | | | | | | | | |
| | (៧) ត្រី អណ្ដែង | | | | | | | | | | | | |
| | (៨) ផ្សេងៗ | | | | | | | | | | | | |

| លរ | សកម្មភាពអនុវត្ត | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១៨ | ទម្ងន់ត្រីបានហូបសរុប (គ.ក្រ) | | | | | | | | | | | | |
| | (១) ត្រី ឆ្ពិន | | | | | | | | | | | | |
| | (២) ត្រី ទីឡាព្យ៉ា | | | | | | | | | | | | |
| | (៣) ត្រី កាបសាមញ្ញ | | | | | | | | | | | | |
| | (៤) ត្រី កាបឥណ្ឌា | | | | | | | | | | | | |
| | (៥) ត្រី កាបស | | | | | | | | | | | | |
| | (៦) ត្រី ប្រា | | | | | | | | | | | | |
| | (៧) ត្រី អណ្តែង | | | | | | | | | | | | |
| | (៨) ផ្សេងៗ | | | | | | | | | | | | |
| ១៩ | ទម្ងន់ត្រីបានលក់សរុប (គ.ក្រ) | | | | | | | | | | | | |
| | (១) ត្រី ឆ្ពិន | | | | | | | | | | | | |
| | (២) ត្រី ទីឡាព្យ៉ា | | | | | | | | | | | | |
| | (៣) ត្រី កាបសាមញ្ញ | | | | | | | | | | | | |
| | (៤) ត្រី កាបឥណ្ឌា | | | | | | | | | | | | |
| | (៥) ត្រី កាបស | | | | | | | | | | | | |
| | (៦) ត្រី ប្រា | | | | | | | | | | | | |
| | (៧) ត្រី អណ្តែង | | | | | | | | | | | | |
| | (៨) ផ្សេងៗ | | | | | | | | | | | | |
| ២០ | ប្រាក់ចំណូលពីផលត្រីចិញ្ចឹមសរុប (គ.ក្រ) | | | | | | | | | | | | |
| | (១) ត្រី ឆ្ពិន | | | | | | | | | | | | |
| | (២) ត្រី ទីឡាព្យ៉ា | | | | | | | | | | | | |
| | (៣) ត្រី កាបសាមញ្ញ | | | | | | | | | | | | |
| | (៤) ត្រី កាបឥណ្ឌា | | | | | | | | | | | | |
| | (៥) ត្រី កាបស | | | | | | | | | | | | |
| | (៦) ត្រី ប្រា | | | | | | | | | | | | |
| | (៧) ត្រី អណ្តែង | | | | | | | | | | | | |
| | (៨) ផ្សេងៗ | | | | | | | | | | | | |
| ២១ | ប្រាក់ចំណាយសរុបលើការចិញ្ចឹមត្រី (គ.ក្រ) | | | | | | | | | | | | |
| | (១) ការរៀបចំស្រះ | | | | | | | | | | | | |
| | (២) ការដាក់កូនត្រីចិញ្ចឹម | | | | | | | | | | | | |
| | (៣) ការដាក់ចំណី | | | | | | | | | | | | |
| | (៤) ការដាក់ជី | | | | | | | | | | | | |
| | (៥) ការចំណាយរំលោះ | | | | | | | | | | | | |
| | (៦) ផ្សេងៗ | | | | | | | | | | | | |
| ២២ | តើអ្នកពេញចិត្តនឹងការចិញ្ចឹមត្រីដែរឬទេ ? | | | | | | | | | | | | |
| ២៣ | តើអ្នកពេញចិត្តនឹងផលត្រីចិញ្ចឹមដែរឬទេ ? | | | | | | | | | | | | |
| ២៤ | តើអ្នកមានផែនការដាក់កូនត្រីចិញ្ចឹមបន្តដែរឬទេ ? | | | | | | | | | | | | |
| ២៥ | តើអ្នកមានផែនការជីកស្រះថ្មីបន្ថែម ចិញ្ចឹមត្រីដែរឬទេ ? | | | | | | | | | | | | |
| ២៦ | តើអ្នកមានផែនការចង់ផលិតកូនត្រីពូជដែរឬទេ ? | | | | | | | | | | | | |
| ២៧ | តើអ្នកបានផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រីដល់កសិករដទៃទៀតដែរឬទេ ? | | | | | | | | | | | | |
| ២៨ | តើមានកសិករប៉ុន្មាននាក់បានដាក់កូនត្រីចិញ្ចឹមដោយការផ្សព្វផ្សាយរបស់អ្នក ? | | | | | | | | | | | | |

# ចំណីរបស់ខ្ញុំ

១- ខ្ញុំជាមច្ឆា អាណិតមេត្តា ផ្តល់ចំណីផង
ខ្ញុំស្រេកឃ្លានណាស់ ដូចគ្នានឹងបង ហូបបាយ ៣ ដង
ក្នុងពេល ១ ថ្ងៃ ។

២- ខ្ញុំស៊ីចំណី បន្លែសត្វ[១]ក្តី ស៊ីបានទាំងអស់
សូមតែលោកបង ជួយឲ្យស៊ីផង នេះជាបំណង
ខ្ញុំជាមច្ឆា ។

៣- កាកស្លឹកបន្លែ សូមបងជួយថៃ ប្រមូលទុកដាក់
កុំបោះវាចោល នាំឲ្យបង់ប្រាក់ ព្រោះវាឆ្ងាញ់ណាស់
សម្រាប់ខ្ញុំជាត្រី។

៤- ដាក់វាក្នុងស៊ុម អណ្តែតកកផ្តុំ នៅលើទឹកស្រះ
កុំឲ្យស្វះខ្យល់ ដង្ហើមខ្ញុំណាស់ អនាម័យទឹកស្រះ
ខ្ញុំលូតលាស់ល្អ។

៥- ជន្លេន កណ្តៀរ និងចកបាយទា មេភ្លៀង[២] អង្រ្កង
សុទ្ធតែជានំ ខ្ញុំឆ្ងាញ់ណាស់បង សូមជួយរកផង
ខ្ញុំអរគុណណាស់។

៦- បងញ៉ាំបាយសល់ កុំចង្អៀតចង្អល់ ឲ្យខ្ញុំស៊ីផង
កុំបោះវាចោល ខ្ញុំស្តាយណាស់បង នេះជាបំណង
ខ្ញុំជាមច្ឆា។

៧-បើបងឧស្សាហ៍ ចំអិនអាហារ ឲ្យខ្ញុំហូបផង
មានតែកន្ទក់[៣] ម្សៅត្រី[៤] ណាបង ចុងអង្ករ[៥]ផង
ពិតជាឆ្ងាញ់ណាស់។

៨- ចំណីមួយទៀត បងគ្រាន់តែឈ្លូត ប្រើលាមកសត្វ
និងទន្លៀងខេត្រ ត្រាំក្នុងពាងបាត់ ប្រាំពីរថ្ងៃប្រាប់
បាចក្នុងទឹកស្រះ។

៩- គឺសត្វប្លុងតុង កើតចេញពីក្នុង ទឹកស្រះដាក់ត្រី
ក្រោយពីបាចជី ៣ ថ្ងៃ ណាថ្លៃ នេះជាចំណី
ពិសេសណាបង។

១០- ចំណីទាំងអស់ ខ្ញុំពិតជាស្មោះ សូមអង្វរបង
ផ្តល់វាឲ្យខ្ញុំ កុំឲ្យរំលង មួយគ្រាណាម្តង
ណាបងណា។

១១- ខ្ញុំហូបគ្រប់គ្រាន់ ធំធាត់មាំទាំ គ្មានកើតជំងឺ
ដូចនេះខ្ញុំធំ ខ្ញុំធាត់គ្មានឈឺ ជីវភាពបងក្តី
ក៏ដោយសារខ្ញុំ។

**កំណត់សំគាល់៖**

- សត្វ [១] ៖ សត្វល្អិត
- មេភ្លៀង[២]៖ សត្វមេភ្លៀង
- កន្ទក់ [៣]៖ កន្ទក់ ៦០%
- ម្សៅត្រី [៤]៖ ម្សៅត្រី ៣០%
- ចុងអង្ករ[៥]៖ ចុងអង្ករ ១០%

*រៀបរៀងដោយលោក ជិន ដា អនុប្រធាននាយកដ្ឋានអភិវឌ្ឍវារីវប្បកម្ម*

## រៀបរៀងដោយ


## នាយកដ្ឋានអភិវឌ្ឍវារីវប្បកម្ម នៃរដ្ឋបាលជលផល

អាសយដ្ឋានលេខ ១៨៦ មហាវិថីព្រះនរោត្តម ប្រអប់សំបុត្រលេខ ៨៣៥

រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារ ( ៨៥៥ ) ២៣ ៩៩៦ ៣៨០



## ឧបត្ថម្ភថវិកាបោះពុម្ពដោយ

គម្រោងបង្កើនផលិតភាព និងផ្សព្វផ្សាយវារីវប្បកម្មទឹកសាប

ដំណាក់កាលទី២ (FAIEX-2 )



រក្សាសិទ្ធិគ្រប់យ៉ាងដោយ រដ្ឋបាលជលផល នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ